# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Drot et des Sciences Économiques**

**Royal University of Law and Economics**


## សារណាបញ្ចប់ការសិក្សា

# បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា ដាំ ដាវ៉ាន់**

**កញ្ញា ដានី លាន់**

ណែនាំដោយ

លោកគ្រូ **គង់ សុភ័ក្ត្រ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៩ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ជាំ ជាវ៉ាន់** និងឈ្មោះ **ដានី លាន់** ជានិស្សិតថ្នាក់អាហារូបករណ៍ជំនាន់ទី២៩ ផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ សូមធ្វើការសូមធ្វើការថ្លែងអំណរគុណ និងដឹងគុណដ៏ជ្រាលជ្រៅដែលមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណរបស់យើងខ្ញុំទាំងពីរនាក់ លោកឪពុកឈ្មោះ **ឡើនវ៉ា ជាំ** និងអ្នកម្តាយឈ្មោះ **ត្រុង សាវ៉េត** លោកឪពុកឈ្មោះ **ឈាន ដានី** និងអ្នកម្តាយឈ្មោះ **ចាំ ពួច** ជាទីគោរព។ ដែលបានផ្តល់កំណើតដល់រូបយើងខ្ញុំ លះបង់នូវកម្លាំងកាយចិត្ត ពុះពារគ្រប់ឧបសគ្គដោយពុំគិតពីការនឿយហត់ និងបានចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌គឺមេត្តា ករុណា ដែលប្រកបដោយសុជីវធម៌ បង្រៀនឱ្យកូនចេះស្រឡាញ់ ចេះជួយអ្នកដទៃ និងចូលរួមសកម្មភាពសង្គមជាតិក្នុងនាមជាចំណែកមួយនៃប្រទេស។ ព្រមទាំងបានផ្គត់ផ្គង់គ្រប់បែបយ៉ាងទាំងការស្នាក់នៅ ការរៀនសូត្រតាំងពីបឋមសិក្សារហូតដល់កម្រិតថ្នាក់បរិញ្ញាបត្រ ដែលជាការប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត លះបង់គ្រប់បែបយ៉ាងដើម្បីឱ្យកូនក្លាយជាអ្នកមានចំណេះដឹង ជំនាញមួយរូបរស់នៅក្នុងសង្គមជាការលះបង់មួយយ៉ាងធំធេងនេះណាស់។

យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ **ឯកឧត្តម លុយ ចន្ថា** ដែលជាសាកលវិទ្យាធិការ និងលោក-លោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់នូវការអប់រំ ចំណេះដឹង ព្រមទាំងក្រមសីលធម៌ដល់រូបយើងខ្ញុំក្នុងអំឡុងសិក្សារៀនសូត្ររយៈពេល០៤ ឆ្នាំកន្លងមកនេះ។ លើសពីនេះទៀតយើងខ្ញុំទាំងពីរសូមថ្លែងអំណរអរគុណជូនចំពោះ **ក្រសួងអប់រំ យុវជន និងកីឡា** ដែលបានឧបត្ថម្ភផ្តល់ជាអាហារូបករណ៍បង់ថ្លៃសាលាដល់រូបយើងខ្ញុំទាំងពីរនាក់បានសិក្សាអស់រយៈពេល ០៤ឆ្នាំនេះដោយឥតគិតថ្លៃ។ ជាពិសេសយើងខ្ញុំទាំងពីរនាក់ក៏មិនភ្លេចនូវការសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកគ្រូ **គង់ សុភ័ក្រ្ត** ដែលជាគ្រូប្រកបដោយគតិបណ្ឌិត ប្រកបដោយប្រសិទ្ធភាព លើកទឹកចិត្តដល់យើងខ្ញុំទាំងពីរនាក់រហូត ផ្តល់កិត្តិយសក្នុងការចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំជ្រោមជ្រែងសម្របសម្រួលកែសម្រួលខ្លឹមសារ និងផ្តល់ជាគំនិតយោបល់ល្អៗក៏ដូចជាបង្ហាញផ្លូវក្នុងការជួយឱ្យការសរសេរសារណាក្រុមយើងខ្ញុំបានសម្រេចជាលទ្ធផលមួយដ៏ល្អប្រសើរដោយជោគជ័យ។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងពួងលើលោកនេះឱ្យជួយតាមថែរក្សាដល់លោកអ្នកមានគុណ ថ្នាក់ដឹកនាំសាលា លោកគ្រូ អ្នកគ្រូ សាស្ត្រចារ្យគ្រប់រូប ជាពិសេសលោកគ្រូដឹកនាំ បងប្អូន រៀមច្បង មិត្តរួមជំនាន់ទាំងអស់ឱ្យជួបតែសេចក្តីសុខសេចក្តីចម្រើនគ្រប់ពេលវេលានូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត និងទទួលបាននូវជោគជ័យគ្រប់ភារកិច្ច។

# អារម្ភកថា

បន្ទាប់ពីបានឆ្លងកាត់ការសិក្សារៀនសូត្រក្រេបជញ្ជក់នូវពុទ្ធិ ចំណេះដឹង និងពុទ្ធិល្អៗនៅថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ០៤ឆ្នាំកន្លងមកនេះ យើងខ្ញុំទាំងពីររូបពិតជាមានសេចក្ដីសោមនស្សរីករាយក្រៃលែង ដែលទទួលបានឱកាសក្នុងការសរសេរសារណា បញ្ចប់ការសិក្សា។ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះយើងខ្ញុំទាំងពីរនាក់មានគោលបំណងគឺ ដើម្បីអភិវឌ្ឍន៍ចំណេះដឹងបន្ថែមលើអ្វីដែលបានសិក្សាកន្លងមក ព្រមទាំងចងក្រងបន្សល់ជាស្នាដៃមួយទុក សម្រាប់ឱ្យនិស្សិតជំនាន់ក្រោយសិក្សាស្វែងយល់ និងស្រាវជ្រាវបន្ថែមក្នុងការសិក្សា។ ហេតុដូចនេះ ទើបយើងខ្ញុំ ទាំងពីរនាក់បានសម្រេចចិត្តជ្រើសរើសលើកយកប្រធានបទមួយគឺ **បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ដើម្បីធ្វើការស្រាវជ្រាវ និងតាក់តែងធ្វើសារណាបញ្ចប់ការសិក្សា។ ដើម្បីចងក្រងនូវសារណានេះឡើងយើងខ្ញុំ ទាំងពីរនាក់បានខិតខំប្រឹងប្រែងក្នុងការស្វែងរកនូវប្រភពឯកសារដែលពាក់ព័ន្ធពីគ្រប់មជ្ឈដ្ឋាន ដូចជាស្រាវជ្រាវ ចេញពីបណ្ណាល័យ សៀវភៅសាស្ត្រាចារ្យ ក្រមនីតិវិធីរដ្ឋប្បវេណី សេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណី សេចក្ដី កំណត់ក្រមនីតិវិធីរដ្ឋប្បវេណី និងបានចូលរួមសិក្ខាសាលាដើម្បីធ្វើជាមូលដ្ឋាន និងជាអំណះអំណាងមួយក្នុងការ សរសេរប្រធានបទនេះឡើងឱ្យមានភាពក្បោះក្បាយលម្អិត និងមានភាពត្រឹមត្រូវ។ ឆ្លងតាមរយៈការសិក្សា ស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំសង្កេតឃើញថាឯកសារជំនួយស្មារតី ដែលពាក់ព័ន្ធនឹងប្រធានបទនេះហាក់ពុំ សូវមានឯកសារគ្រប់គ្រាន់ ឬមានទូលំទូលាយនោះទេ ហើយយើងខ្ញុំក៏មិនហ៊ានធានាថាការស្រាវជ្រាវនេះមាន ភាពល្អឥតខ្ចោះមួយរយភាគរយនោះដែរ។ ប៉ុន្តែទោះបីជាមានការលំបាក ក្នុងការស្វែងរកទាំងនោះឯកសារ យ៉ាងណាក៏ដោយ ដោយសារតែការប្ដេជ្ញាចិត្ត និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់យើងខ្ញុំពីរនាក់ ព្រមទាំងមានការណែនាំពីសំណាក់លោកគ្រូដឹកនាំទៀតផងនោះ ដែលជាលទ្ធផលសារណាបញ្ចប់ការសិក្សាមួយ នេះបានលេចឡើងជារូបរាង និងមានបញ្ចូលនូវខ្លឹមសារល្អប្រសើរជាច្រើន។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមយ៉ាងមុតមាំថាស្នាដៃមួយនេះនឹងទទួលបានលទ្ធផលល្អ ហើយ អាចប្រែក្លាយទៅជាឯកសារជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវបន្ថែមរបស់មិត្តនិស្សិត សិស្សប្អូនជំនន់ក្រោយ និងអ្នកសិក្សាស្រាវជ្រាវបន្តទៀតដើម្បីឱ្យមានភាពងាយស្រួល ក្នុងការសិក្សាក្រេបយកចំណេះដឹងពីមួយ ជំនាន់ទៅមួយជំនាន់។ ម្យ៉ាងវិញទៀត ចំពោះរាល់កំហុសខុសឆ្គងដែលមានកើតឡើងពីយើងខ្ញុំទាំងពីរដោយ អចេតនាពាក់ព័ន្ធទៅនឹងការប្រើប្រាស់ពាក្យសម្ដី អក្ខរាវិរុទ្ធ និងខ្លឹមសារទាំងឡាយ យើងខ្ញុំសូមធ្វើការខន្តីអភ័យទោស ពីសំណាក់ អ្នកសិក្សា អ្នកអានគ្រប់ៗរូប ជាពិសេសលោកគ្រូ អ្នកគ្រូ ហើយយើងខ្ញុំនឹងរងចាំទទួលនូវរាល់ការ រិះគន់ទាំងអស់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ មិត្តនិស្សិត ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវ ទាំងអស់ដោយសេចក្ដីសោមនស្សរីករាយ និងគោរពរាប់អានដ៏ជ្រាលជ្រៅពីយើងខ្ញុំទាំងពីរនាក់។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

## ជំពូកទី១

## សញ្ញាណទូទៅនៃនីតិវិធីជំនុំជម្រះសាជាថ្មី

**១.១. ការវិវត្តនៃនីតិវិធីជំនុំជម្រះសាជាថ្មី** ........ ៣

**១.២. បណ្តឹងទាមទារឱ្យជម្រះសាជាថ្មី និងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់** ........ ៣

**១.៣. លក្ខខណ្ឌនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ........ ៦

១.៣.១. ភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ........ ៦

១.៣.២. មូលហេតុនៃការជំនុំជម្រះសាជាថ្មី ........ ៩

១.៣.៣. កម្មវត្ថុនៃការជម្រះសាជាថ្មី ........ ១៩

១.៣.៤. ការដាក់ពាក្យបណ្តឹង ........ ២២

**១.៤. អានុភាពនៃការទាមទារជំនុំជម្រះសាជាថ្មី** ........ ៣០

១.៤.១. ការផ្អាកការអនុវត្តដោយបង្ខំដោយការជំនុំជម្រះសាជាថ្មី ........ ៣០

១.៤.២. ការដកពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ........ ៣២

## ជំពូកទី២

## នីតិវិធីនៃការវិនិច្ឆ័យ និងការសម្រេចសេចក្តី

**២.១. នីតិវិធីនៃការវិនិច្ឆ័យលើបណ្តឹង** ........ ៣៣

២.១.១. ភាពបង្គ្រប់នៃបណ្តឹងទាមទារជម្រះសាជាថ្មី ........ ៣៣

២.១.២. សេចក្តីសម្រេចទទួលស្គាល់ ឬមិនទទួលស្គាល់ការទាមទារ ........ ៣៥

**២.២. ការវិនិច្ឆ័យអំពីអង្គសេចក្តី** ........ ៣៨

**២.៣. ការសម្រេចសេចក្តីលើអង្គសេចក្តី** ........ ៤០

២.៣.១. ការសម្រេចសេចក្តីលុបចោលសេចក្តីសម្រេចដើម ........ ៤០

២.៣.២. ការទទួលស្គាល់សេចក្តីសម្រេចដើម ........ ៤១

## ជំពូកទី៣

## បញ្ហាប្រឈម និងដំណោះស្រាយ

**៣.១. បញ្ហាប្រឈមនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី** ........ ៤៣

៣.១.១. ការអូសបន្លាយពេលវេលា ........ ៤៣

៣.១.២. ខាតបង់សោហ៊ុយ ........ ៤៣

៣.១.៣. បង្កភាពស្មុគស្មាញដល់ភាគីពាក់ព័ន្ធក្នុងសំណុំរឿង ........ ៤៤

៣.១.៤. បង្កភាពស្មុគស្មាញដល់តុលាការ ........ ៤៥

៣.១.៥. ពន្យារពេលអនុវត្តដោយការដាក់ពាក្យបណ្តឹងដែលគ្មានមូលហេតុ ........ ៤៥

៣.១.៦. បង្កការស្មុគស្មាញដល់ការធ្វើបដិទាននូវស្ថានភាពដើម ........ ៤៦

៣.១.៧. មានការវាយតម្លៃលើសេចក្តីសម្រេចរបស់តុលាការពីសាធារណៈជន ........ ៤៧

**៣.២. ដំណោះស្រាយ** ........ ៤៧

៣.២.១. ចំពោះតុលាការ ........ ៣៧

៣.២.២. ចំពោះភាគី ........ ៤៨

៣.២.៣. បញ្ហាច្បាប់ ........ ៤៨

៣.២.៣. ការពង្រឹងប្រព័ន្ធផ្សព្វផ្សាយ ........ ៤៩

**សេចក្តីសន្និដ្ឋាន** ........ ៥០

**អនុសាសន៍** ........ ៥១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ក.ចំណោទបញ្ហា

វិវាទបុគ្គលជាលក្ខណៈឯកជនដែលមិនអាចដោះស្រាយក្រៅប្រព័ន្ធតុលាការត្រូវដោះស្រាយដោយតុលាការតាមរយៈសេចក្តីសម្រេចដូចជាសាលក្រមជាដើម។ គ្រប់សាលក្រមទាំងអស់ដែលត្រូវបានវិនិច្ឆ័យត្រូវមានអានុភាពអាជ្ញាអស់ជំនុំក្រោយចូលជាស្ថាពរ។ មានន័យថាភាគីមិនអាចធ្វើការប្តឹងតវ៉ាទៀតបានទេ លើកលែងតែមានមូលហេតុជាក់លាក់មួយចំនួនដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ដូចជាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីជាដើម។

ការជំនុំជម្រះសាជាថ្មី គឺជាមធ្យោបាយពិសេស មួយប្រភេទដែលមានសារៈសំខាន់ចំពោះភាគី ឬតតិយជនដែលមានផលប្រយោជន៍ ហើយរងភាពអយុត្តិធម៌ដោយការចាញ់ក្តីទាំងស្រុង ឬមួយផ្នែក ហើយអនុញ្ញាតឱ្យភាគីឬតតិយជននោះធ្វើការប្តឹងទាមទារឱ្យតុលាការដែលបានចេញសាលក្រម ឬសាលដីកាដែលមានវិការៈនោះធ្វើការវិនិច្ឆ័យក៏ដូចជាជំនុំជម្រះសាជាថ្មីម្តងទៀត ដោយសេចក្តីសម្រេចថ្មីនោះមានអានុភាពលុបចោល ឬកែប្រែសេចក្តីសម្រេចដើម បើសិនជាពាក្យសុំទាមទារជំនុំជម្រះសាជាថ្មីត្រូវបានទទួលស្គាល់ថាសមហេតុផលហើយមានមូលហេតុច្បាស់លាស់។

## ខ. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាទៅលើប្រធានបទ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះឱ្យកាន់តែស៊ីជម្រៅ និងកាន់តែច្បាស់លាស់ យើងខ្ញុំបានលើកឡើងនូវចំណោទបញ្ហាគតិយុត្តមួយដើម្បីយកមកធ្វើការដោះស្រាយដែលចំណោទបញ្ហាគតិយុត្តនោះរួមមាន ៖ ១.តើអ្វីជាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី? ២.តើមូលហេតុនៃការជំនុំជម្រះសាជាថ្មីមានអ្វីខ្លះ? ៣.តើបុគ្គលណាខ្លះដែលមានសិទ្ធិក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន? ៤.តើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានដំណើរការ ក៏ដូចជាលក្ខខណ្ឌវិនិច្ឆ័យបែបណាខ្លះ?

## គ. គោលបំណងនៃការស្រាវជ្រាវ

មូលហេតុដែលក្រុមយើងខ្ញុំបានជ្រើសរើសយកប្រធានបទមួយនេះ មកធ្វើជាប្រធានបទសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះ ព្រោះតែក្រុមយើងខ្ញុំមានគោលបំណងចង់សិក្សាឈ្វេងយល់ ថាអ្វីជាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី សិក្សាអំពីមូលហេតុនីមួយៗដែលជាលក្ខខណ្ឌនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយសិក្សាទៅលើបុគ្គលណាខ្លះដែលមានសិទ្ធិក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន និងជាពិសេសចង់យល់ឱ្យកាន់តែច្បាស់អំពីដំណើរការ ឬការវិនិច្ឆ័យលើសំណុំរឿងនេះទាំងមូល។ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីគឺជានីតិវិធីពិសេសមួយដែលយើងគ្រប់គ្នាត្រូវដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការតវ៉ាដែលជាច្រកមួយដោះស្រាយទៅលើបញ្ហាដែលបានកើតឡើងដោយបំពានសិទ្ធិរបស់យើង។ ការសិក្សាស្រាវជ្រាវនេះ គឺដើម្បីជាប្រយោជន៍

មួយភាគដល់ការសិក្សារបស់សិស្សនិស្សិត និងប្រជាពលរដ្ឋគ្រប់រូបឱ្យពួកគាត់ទទួលបានចំណេះដឹង ឬក៏ជាពុទ្ធិបន្ថែមផ្អែកទៅលើប្រធានបទនីតិវិធីជំនុំជម្រះសាជាថ្មីនេះ។

## ឃ. ទំហំនៃការស្រាវជ្រាវ

ប្រធានបទបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ គឺក្រុមយើងខ្ញុំបានសិក្សាស្រាវជ្រាវលម្អិតតែទៅលើបញ្ញត្តិនៃមាត្រា៣០៧ រហូតដល់មាត្រា៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលនិយាយអំពីការដាក់ពាក្យបណ្ដឹងដំណាក់កាលវិនិច្ឆ័យរហូតដល់អានុភាពនៃសេចក្ដីសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មីតែប៉ុណ្ណោះ។

## ង. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះជាការចែករំលែកទៅដល់អ្នកសិក្សាស្រាវជ្រាវ ដើម្បីពង្រឹងចំណេះដឹងបន្ថែម ក៏ដូចជាមានភាពងាយស្រួលក្នុងការអាន ងាយយល់ងាយចាំពាក់ព័ន្ធទៅនឹងនីតិជនឯកជនដែលបានបញ្ញត្តិក្នុងគន្ថីទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ជាធរមានរបស់ប្រទេសកម្ពុជា។

## ច. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ក្រុមយើងខ្ញុំផ្អែកលើឯកសារភាសាខ្មែរដូចជាសៀវភៅ ឯកសារសិក្ខាសាលា និងបណ្ដាញInternet។ ជាពិសេស ក្រមនីតិវិធីរដ្ឋប្បវេណីជាគោលដែលកំពុងតែមានជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាឯកសារជំនួយស្មារតីផ្នែកច្បាប់ដែលបានសរសេរពីបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយត្រូវបានរៀបចំ និងចងក្រងដោយអ្នកជំនាញការផ្នែកច្បាប់នានានៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការសហការណ៍ជាមួយក្រុមការងារជប៉ុនក្នុងការធ្វើឱ្យឯកសារទាំងនោះមានភាពត្រឹមត្រូវ ច្បាស់លាស់ ហើយមានតម្លៃដែលអាចយកមកប្រើប្រាស់បាន។ ការសិក្សាស្រាវជ្រាវប្រធានបទនេះយើងក៏បានធ្វើការប្រមូលយកព័ត៌មានតាមរយៈការសាកសួរអ្នកវិជ្ជាជីវៈច្បាប់ ដែលកំពុងអនុវត្តដោយផ្ទាល់ដូចជាមេធាវី ចៅក្រមចំពោះបញ្ហានានាដែលកើតមានឡើង ហើយពុំបានបញ្ញត្តិ ឬបញ្ញត្តិមិនច្បាស់លាស់នៅក្នុងច្បាប់។

## ឆ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជុំវិញបញ្ហាប្រធានបទនៃសារណាមួយនេះ និងដើម្បីឆ្លើយតបទៅនឹងបញ្ហាគតិយុត្តដែលបានចោទឡើងខាងលើ ឱ្យបានកាន់តែក្បោះក្បាយ ស៊ីជម្រៅ និងកាន់តែងាយស្រួលក្នុងការស្វែងយល់ យើងខ្ញុំបានធ្វើការសិក្សាយ៉ាងលម្អិតទៅលើលំហូរនៃនីតិវិធីនៃការជំនុំជម្រះសាជាថ្មី ដោយធ្វើការបែងចែកជា ៣ជំពូកដូចតទៅ ៖

- **ជំពូកទី១៖** សញ្ញាណទូទៅនៃបណ្ដឹងជំនុំជម្រះសាជាថ្មី
- **ជំពូកទី២៖** នីតិវិធីនៃការវិធីនៃការវិនិច្ឆ័យ និងការសម្រេចសេចក្ដី
- **ជំពូកទី៣៖** បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីជំនុំជម្រះសាជាថ្មី

# ជំពូកទី១
# សញ្ញាណទូទៅនៃនីតិវិធីជំនុំជម្រះសាជាថ្មី

## ១.១. ការវិវត្តនៃនីតិវិធីជំនុំជម្រះសាជាថ្មី

ប្រទេសកម្ពុជា ធ្លាប់បានធ្លាក់ចូលក្នុងផ្ទក់ភ្លើងនៃសង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំដែលបណ្ដាលឱ្យមានការបំផ្លិចបំផ្លាញ ការធ្លាក់ចុះ និងអន់ថយជាលំដាប់ស្ទើរគ្រប់វិស័យទាំងអស់ ក្នុងចំណោមនោះក៏មានវិស័យយុត្តិធម៌ផងដែរ។ ហេតុនេះហើយនៅពេលដែលប្រទេសកម្ពុជារួចផុតពីសង្គ្រាម ហើយទទួលបាននូវឯករាជ្យភាពពេញលេញរួចមក ដើម្បីរក្សានូវសុខសន្តិភាពរាជរដ្ឋាភិបាលបានធ្វើការរៀបចំបង្កើតឱ្យមានច្បាប់ ឬបទដ្ឋានគតិយុត្តឡើងវិញ ជាបន្តបន្ទាប់ដើម្បីធានាឱ្យមានប្រសិទ្ធភាព សុក្រឹតភាព នៃការអនុវត្តក្នុងវិស័យយុត្តិធម៌។ នៅក្នុងឆ្នាំ១៩៨៤ ក្រសួងយុត្តិធម៌បានចេញសារាចរ ០៤ ស.រ.ច ៨៤ ស្ដីពីសេចក្ដីណែនាំអំពីនីតិវិធីរដ្ឋប្បវេណីដោយមានបញ្ញត្តិអំពីការប្ដឹងជំទាស់ និងការជំនុំជម្រះសារឡើងវិញ។ សម្រាប់ករណីដែលរដ្ឋអាជ្ញាយល់ឃើញថា សាលក្រមរដ្ឋប្បវេណី របស់តុលាការប្រជាជនខេត្ត ក្រុងសម្រេចដោយមានការភាន់ច្រឡំ រដ្ឋអាជ្ញាត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដើម្បីពិនិត្យ និងសម្រេច។ ហើយនៅក្នុងនីតិវិធីនៃការជំនុំជម្រះសារឡើងវិញ ក្រុមប្រឹក្សាជំនុំជម្រះត្រូវមាន ចៅក្រមចំនួន ០២នាក់ ដែលម្នាក់ជាប្រធាន និងក្រុមប្រឹក្សាប្រជាជន ០៣ (បី)នាក់ ហើយសុទ្ធតែជាអ្នកដែលបានចូលរួមក្នុងការជំនុំជម្រះលើកមុន។ មួយវិញទៀតចំពោះសាលក្រមរបស់តុលាការប្រជាជនខេត្ត ក្រុងដែលជំនុំជម្រះសារឡើងវិញ បើទោះបីសម្រេចកំបាំងមុខក៏ដោយ ក៏មិនអាចឱ្យមានការប្ដឹងជំទាស់ ឬតវ៉ាទៀតឡើយ។

ក្រោយមកទៀត នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងរាជរដ្ឋាភិបាលជប៉ុនក្នុងការអភិវឌ្ឍវិស័យយុត្តិធម៌តាមរយៈគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការនៃក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ដើម្បីធ្វើការតាក់តែងសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីរហូតដល់ទទួលបានលទ្ធផលជាស្ថាពរក្នុងឆ្នាំ២០០៧។ហើយចាប់តាំងពីពេលនោះរហូតមកបច្ចុប្បន្ន បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានអនុវត្តដោយផ្អែកតាមបញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។

## ១.២. បណ្ដឹងទាមទារឱ្យជម្រះសាជាថ្មី និងបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

ដូចដែលបានរៀបរាប់នៅខាងលើ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាបណ្ដឹងទាមទារឱ្យលុបចោលសាលក្រម ឬសាលដីកាដែលបានស្ថាពរហើយ ដែលគេហៅថាបណ្ដឹងឧបាស្រ័យពិសេស។ ជាទូទៅនៅពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរហើយ គ្រប់សាលក្រមទាំងអស់ត្រូវមានអានុភាពអាជ្ញាអស់

ជំនុំជាអានុភាពដែលរារាំងសិទ្ធិរបស់ភាគីទាំងសងខាង រួមទាំងតុលាការនោះផង គឺមិនឱ្យធ្វើការកែប្រែ ឬផ្លាស់ប្តូរតាមចិត្តនោះឡើយ។

ផ្អែកតាមក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្នអាជ្ញាអស់ជំនុំមានពីរប្រភេទគឺ អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ និងអាជ្ញាអស់ជំនុំលក្ខណៈសារធាតុ។ ចំពោះអាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់ មានន័យថា នៅពេលដែលសាលក្រមចូលជាស្ថាពររួចហើយ គេមិនអាចទាមទារឱ្យលុបសាលក្រមនោះចោលដោយបណ្តឹងឧបាស្រ័យធម្មតា ដូចជាប្តឹងឧទ្ធរណ៍ ប្តឹងសាទុក្ខបានទេ ដោយសារតែគេចាត់ទុកថានេះជាលទ្ធផលនៃសេចក្តីវិនិច្ឆ័យដែលមានអានុភាពដែលរារាំង សូម្បីតែតុលាការដែលមានថ្នាក់ខ្ពស់ជាងក៏មិនអាចលុបចោលនូវសេចក្តីសម្រេចដែលបានចូលជាស្ថាពរ។ អាជ្ញាអស់ជំនុំជាលក្ខណៈទម្រង់នៃសាលក្រមនេះផងដែរ គឺជាលក្ខខណ្ឌមូលដ្ឋាននៃការកើតមានឡើងនូវអាជ្ញាអស់ជំនុំជាលក្ខខណៈសារធាតុ អានុភាពអនុវត្ត និងអានុភាពនៃការបង្កើត ផ្លាស់ប្តូរ ឬរំលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត។[1] រីឯអាជ្ញាអស់ជំនុំសារធាតុមានន័យថា បញ្ហាដែលបានវិនិច្ឆ័យដោយសាលក្រមចុងក្រោយដែលបានចូលជាស្ថាពរ បានក្លាយទៅជាបញ្ហាក្នុងបណ្តឹងមួយផ្សេងទៀត ភាគីមិនត្រូវអនុញ្ញាតឱ្យធ្វើការអះអាង ដែលមានភាពផ្ទុយគ្នានឹងការវិនិច្ឆ័យដែលបានធ្វើហើយក្នុងសាលក្រមស្ថាពរទេ ហើយតុលាការក៏មិនត្រូវអនុញ្ញាតឱ្យធ្វើការវិនិច្ឆ័យដែលមានភាពផ្ទុយគ្នា នឹងការវិនិច្ឆ័យដែលបានធ្វើហើយក្នុងសាលក្រមស្ថាពរនោះឡើយ។ ដូចនេះជាទូទៅនៅពេលដែលមានអានុភាពនៃអាជ្ញាអស់ជំនុំហើយភាគីនៃបណ្តឹងមិនអាចអនុវត្តសិទ្ធិក្នុងការធ្វើបណ្តឹងឧបាស្រ័យអ្វីបានទៀតឡើយ តែច្បាប់ក៏ទុកផ្លូវមួយដើម្បីធ្វើការដោះស្រាយទៅបញ្ហាដែលកើតឡើង ទៅលើសាលក្រមដែលបានចូលជាស្ថាពរនេះផងដែរ។ ប្រសិនជាច្បាប់មិនបានបើកសិទ្ធិឱ្យប្តឹងទាមទារជំនុំជម្រះសាជាថ្មីទេនោះ ទាំងករណីដែលសេចក្តីសម្រេចណាមួយមានវិការៈធ្ងន់ធ្ងរនោះ នោះវានឹងបណ្តាលធ្វើឱ្យមានការខូចខាតក៏ដូចជាប៉ះពាល់ដល់សិទ្ធិរបស់ភាគីយ៉ាងខ្លាំង។ ហេតុនេះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺផ្លូវតែមួយគត់ក្នុងការប្រឆាំងទៅនឹងសេចក្តីសម្រេចដែលបានចូលជាស្ថាពរហើយ ជាទូទៅមានអានុភាពអាជ្ញាអស់ជំនុំ។[2]

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនមែនជាប្រភេទបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់នោះទេ តែវាជាបណ្តឹងតវ៉ាប្រឆាំងទាមទារឱ្យតុលាការដែលបានចេញសាលក្រម ឬសាលដីកាដដែលធ្វើការ

[1] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *នីតិវិធីបណ្តឹង* (ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី,២០០៨),១៣៤។

[2] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *នីតិវិធីបណ្តឹង* (ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី,២០០៨),១៣៧។

ចេញសេចក្តីសម្រេចឡើងវិញ។ មានន័យថាប្រសិនបើសាលក្រមដែលជាសេចក្តីសម្រេច បានចេញដោយសាលាដំបូងរាជធានីភ្នំពេញ នោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏ត្រូវសម្រេចសេចក្តីដោយសាលាដំបូងរាជធានីភ្នំពេញដែរ។ នៅពេលដែលសាលក្រម ឬសាលដីកាត្រូវបានប្តឹងឧបាស្រ័យរួចរាល់ ឬផុតរយៈពេលប្តឹងឧបាស្រ័យ ហើយភាគីមិនបានអនុវត្តសិទ្ធិនៅក្នុងការប្តឹងឧបាស្រ័យទេនោះ បើសិនជាភាគីនៅតែចង់អនុវត្តសិទ្ធិនោះភាគីអាចអនុវត្តសិទ្ធិបាន តាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន។

បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ គឺជាវិធីឧបាស្រ័យទាមទារដោយភាគីទៅតុលាការជាន់ខ្ពស់ឱ្យលុបចោល ឬផ្លាស់ប្តូរនូវសេចក្តីសម្រេចដែលចេញដោយតុលាការថ្នាក់ក្រោម នៅមុនពេលដែលសេចក្តីសម្រេចនោះបានចូលជាស្ថាពរតែប៉ុណ្ណោះ។ ពេលដែលមានបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់សេចក្តីសម្រេចដើមមិនទាន់ចូលជាស្ថាពរ រហូតដល់ដំណើរការឧបាស្រ័យទៅតុលាការជាន់ខ្ពស់បានបញ្ចប់ ផ្ទុយទៅវិញបើសេចក្តីសម្រេចមួយចូលជាស្ថាពរហើយ មិនអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ចំពោះសេចក្តីសម្រេចដែលចូលជាស្ថាពរនោះបានទេ មានតែវិធីមួយគត់ គឺការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ទៅតុលាការដែលបានចេញសាលក្រម ឬសាលដីកាដើម។

បណ្តឹងឧប្រាស័យទៅតុលាការជាន់ខ្ពស់ ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គឺមានដូចជាបណ្តឹងជំទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខជាដើម។[3] ចំពោះបណ្តឹងទាំងបីនេះ ក៏មានបែបបទនីតិវិធី និងការវិនិច្ឆ័យខុសៗប្លែកពីគ្នាផងដែរ។ ដោយបណ្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មួយប្រភេទដែលឯករាជ្យ និងសង្ខេបចំពោះដីកាសម្រេចរបស់តុលាការថ្នាក់ក្រោម ដោយមិនមែនជាសាលក្រម ឬសាលដីកាដែលបានចេញទៅតុលាការជាន់ខ្ពស់។ រីឯ បណ្តឹងឧទ្ធរណ៍វិញ គឺជាបណ្តឹងឧប្រាស្រ័យទៅតុលាការជាន់ខ្ពស់មួយប្រភេទដែលអាចប្តឹងបានចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះជម្រះលើកទី១ ក្នុងគោលបំណងឱ្យតុលាការជាន់ខ្ពស់លុបចោល ឬផ្លាស់ប្តូរនូវសាលក្រមចុងក្រោយ មានន័យថាជាសេចក្តីសម្រេចរបស់តុលាការសាលាដំបូង ហើយធ្វើការសម្រេចសេចក្តីដោយសាលាឧទ្ធរណ៍។ ចំណែកឯបណ្តឹងសាទុក្ខវិញ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការកំពូលចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលទាមទារឱ្យវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយ ចំពោះការអនុវត្តច្បាប់តែប៉ុណ្ណោះ។ តុលាការនៃបណ្តឹងសាទុក្ខ មិនធ្វើការទទួលស្គាល់នូវអង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុ ដោយផ្អែកលើការទទួលស្គាល់នូវអង្គហេតុដោយតុលាការដើម។ សាលដីកាដែលអាចប្តឹងសាទុក្ខបាន មានដូចជា សាលដីកាចុងក្រោយដែលត្រូវបាន

[3] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា២៥៩។

ជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍ គឺជាសាលដីកាដែលសាលាឧទ្ធរណ៍បានចេញ។ សាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី១ តាមបញ្ញត្តិច្បាប់ពិសេស។

## ១.៣. លក្ខខណ្ឌនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

### ១.៣.១. ភាគីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

បុគ្គលដែលអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជម្រះសាជាថ្មី គឺជាបុគ្គលដែលទទួលរងនូវអានុភាពនៃសាលក្រម ឬសាលដីកាមួយផ្នែក ឬទាំងស្រុងហើយមានផលប្រយោជន៍ក្នុងការទាមទារឱ្យលុបចោលនូវសាលក្រម ឬសាលដីកា។

ច្បាប់មិនបានកំណត់ឱ្យជាក់លាក់ថាជាដើមចោទ ឬចុងម្លើយជាអ្នកដែលមានសិទ្ធិ ពោលគឺអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ទាំងដើមចោទ និងចុងចម្លើយនៃរឿងក្ដីដែលទទួលអានុភាពនៃសាលក្រម ឬសាលដីកា ហើយមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ ជាធម្មតាមានតែភាគីដែលចាញ់ក្ដីទាំងស្រុង ឬមួយផ្នែក និងភាគីដែលបានឈ្នះក្ដីតែមួយផ្នែកប៉ុណ្ណោះដែលប្ដឹង ព្រោះប្រសិនជាភាគីម្ខាងបានឈ្នះក្ដីទាំងស្រុងហើយនោះ ប្រាកដណាស់ថាមិនចង់ឱ្យគេលុបចោលសាលក្រម ឬសាលដីកាដែលខ្លួនបានឈ្នះក្ដីនោះទេ។ ម្យ៉ាងទៀត ប្រសិនជាភាគីដើមចោទ ឬចុងចម្លើយនៃសាលក្រម ឬសាលដីកាដើម ដែលឈ្នះក្ដីទាំងស្រុង ភាគីនោះមិនមានសិទ្ធិក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មីឡើយ បើទុកឱកាសឱ្យភាគីដែលបានឈ្នះក្ដីហើយដាក់ពាក្យបណ្ដឹងទាមទារឱ្យជម្រះសាជាថ្មីទៀតនោះ មានភាពមិនសមរម្យ និងគ្មានផលប្រយោជន៍សោះឡើយ។ ក្រៅពីដើមចោទ និងចុងចម្លើយ តតិយជនក៏មានសិទ្ធិក្នុងការប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះផងដែរ។ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការសិក្សា យើងនឹងបែកចែក ជាពីរចំណុច ១.៣.១.១. បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយដើមចោទ និងចុងចម្លើយ ១.៣.១.២. បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជនដែលមានផលប្រយោជន៍។

#### ១.៣.១.១. បណ្ដឹងទាមទារឱ្យជម្រះសាជាថ្មីដោយដើមចោទ និងចុងចម្លើយ

បុគ្គលដែលអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក្នុងនាមជាដើមចោទ គឺជាបុគ្គលដែលទទួលរងនូវអានុភាពនៃសាលក្រម ឬសាដីកាស្ថាពរ ហើយមានផលប្រយោជន៍ក្នុងការទាមទារឱ្យលុបចោលនូវអានុភាពនៃសាលក្រម ឬសាដីកា។ ដើមចោទអាចដាក់ពាក្យបណ្ដឹងទាមទារឱ្យជម្រះសាជាថ្មីបាន ករណីដែលខ្លួនចាញ់ក្ដីមួយផ្នែក ឬទាំងស្រុងតាមរយៈសេចក្ដីសម្រេចរបស់តុលាការដើម។ ក្នុងករណីដែលដើមចោទបានដឹងថាមានវិការៈណាមួយដែលបានកំណត់ក្នុងមាត្រា៣០៧ និងមាត្រា៣០៨ កើតឡើងនៅក្នុងសេចក្ដីសម្រេចដើមចោទអាចប្ដឹងទាមទារឱ្យតុលាការដែលបានចេញសាលក្រម ឬសាលដីកាធ្វើការជំនុំជម្រះ

សាជាថ្មីបាន។ ឯចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ គឺជាភាគីដែលបានឈ្នះក្តីក្នុងសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ ហើយចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏អាចពង្រីកនូវទំហំនៃការវិនិច្ឆ័យអត្ថប្រយោជន៍របស់ខ្លួនដោយពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបន្ទាប់បន្សំ។ ម្យ៉ាងទៀតចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីក៏អាចដាក់ពាក្យបណ្តឹងតបបាន ដោយយកមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលខ្លួនមាន។[4] ទោះបីជាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដែលបានកំណត់ដោយច្បាប់យ៉ាងណាក៏ដោយប្រសិនជាភាគីដែលបានដាក់ពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី គឺជាភាគីដែលបានឈ្នះក្តីទាំងស្រុង ក៏មិនគួរដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬសាលដីកាជាស្ថាពរដែលជាផលប្រយោជន៍របស់ខ្លួន ដោយមូលហេតុថាគ្មានផលប្រយោជន៍ក្នុងការទាមទារអ្វីឡើយ។

### ១.៣.១.២. បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយតតិយជន

ជាគោលការណ៍ ភាគីនៃបណ្តឹងដើមដែលជាអ្នកទទួលរងនូវអានុភាពនៃសាលក្រម ឬសាលដីកាជាអ្នកដែលមានសិទ្ធិដោយស្វ័យប្រវត្តិក្នុងការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តែក៏មានករណីលើកលែងមួយចំនួន ដែលតតិយជនទទួលរងនូវអានុភាពនៃសាលក្រម ឬសាលដីកា ឬតតិយជនដែលមានផលប្រយោជន៍តាមផ្លូវច្បាប់អំពីលទ្ធផលនៃបណ្តឹងអាចចូលរួមអន្តរាគមន៍ក្នុងបណ្តឹង ឬករណីដែលក្រោយពីភាគីនៃបណ្តឹងបានទទួលមរណភាពទៅ ជនដែលមានបំណងដាក់ពាក្យបណ្តឹងត្រូវយកប្រតិសិទ្ធិសកល (សន្តតិជន) អាចដាក់ពាក្យបណ្តឹបាន។ មានន័យថាបុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចពីមតកជន គឺអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាថ្មីបាន ដោយអះអាងអំពីសិទ្ធិដែលខ្លួនទទួលបានតាមរយៈសន្តតិកម្ម។

ហេតុនេះ តតិយជនដែលជាអ្នកចូលរួមជួយអន្តរាគមន៍ អាចដាក់វិធីតទល់ ឬការពារខ្លួន អាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ អាចទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មី និងអាចធ្វើសកម្មភាពបណ្តឹងផ្សេងទៀតដែលទាក់ទងនឹងបណ្តឹងនេះ។[5] បុគ្គលដែលជាម្ចាស់ផលប្រយោជន៍ ជាសារធាតុនៅក្នុងបណ្តឹងដែលទទួលបន្ទុកដោយអ្នកដទៃ ឬបុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចដែលជាសន្តតិជន ក្រោយពេលបណ្តឹងត្រូវបានចាត់ការជាដើម អាចធ្វើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ឱ្យតែបុគ្គលនោះមានផលប្រយោជន៍ជាក់លាក់

[4] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧),២៩៥។

[5] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៤៦,កថាខណ្ឌទី១។

ក្នុងការលុបចោលនូវសាលក្រម ឬសាលដីកា។[6] បុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ច មានន័យថា ករណីដែលដើមចោទ ឬចុងចម្លើយដែលជាបុគ្គលដែលមានផលប្រយោជន៍នៅក្នុងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទទួលមរណភាព នោះសន្តតិជននៃបុគ្គលដែលទទួលមរណភាពអាចធ្វើការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន។ ក្នុងករណីនេះសន្តតិជន គឺជាតតិយជនហើយអាចធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីប្រសិនបើតតិយជនបានដឹងថាសាលក្រមដែលបានចូលស្ថាពរមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដូចដែលបានកំណត់នៅក្នុងបញ្ញត្តិមាត្រា៣០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

លើសពីតតិយជនដែលទទួលរងនូវអានុភាពនៃសាលក្រម ឬសាលដីកាខាងលើក៏មានតតិយជនមួយប្រភេទទៀតដែរ ដែលបានបញ្ញត្តិនៅក្នុងមាត្រា៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីតតិយជននេះកើតឡើងពីការបាត់បង់ផលប្រយោជន៍ដោយសារការរួមគំនិតគ្នាដោយទុច្ចរិតរវាងដើមចោទ និងចុងចម្លើយ។ នៅពេលដែលអានុភាពនៃសាលក្រម ឬសាលដីកាមានចំពោះតតិយជនទូទៅ តតិយជនដែលមានផលប្រយោជន៍ជាក់លាក់ក្នុងការលុបចោលនូវសាលក្រម ឬសាលដីកា អាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានបើសិនជាករណីដែលដើមចោទ និងចុងចម្លើយបានធ្វើបណ្តឹងនឹងទទួលសាលក្រម ឬសាលដីកាស្ថាពរដោយផ្សំគំនិតគ្នាក្នុងគោលបំណងធ្វើឱ្យមានការខូចខាតដល់សិទ្ធិ ឬផលប្រយោជន៍របស់តតិយជន។ តតិយជនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ដើម្បីទាមទារឱ្យតុលាការធ្វើការលុបចោលនូវសាលក្រម ឬសាលដីកា និងវិនិច្ឆ័យសាជាថ្មី។ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បែបនេះហៅថាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសកម្មភាពដែលនាំឱ្យខូចប្រយោជន៍។ ក្នុងករណីនេះ ដើមចោទ និងចុងចម្លើយត្រូវក្លាយទៅជាសហបណ្តឹង (សហចុងចម្លើយ)។ ក្នុងករណីនេះ ទោះបីជាអង្គហេតុនៃរឿងក្តីមិនមានមូលហេតុទាំង១០ ដូចដែលបានកំណត់នៅក្នុងមាត្រា៣០៧ក៏ដោយ ឱ្យតែមានលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា៣១៨ ត្រូវបានបំពេញតតិយជនអាចធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅលើសាលក្រម ឬសាលដីកាស្ថាពរដែលមានការរួមគំនិតគ្នារវាងដើមចោទ និងចុងចម្លើយបាន។ តាមរយៈពេលមាត្រា៣១៨ នៃលក្ខខណ្ឌដែលត្រូវបំពេញមានដូចជា៖

១.ដើមចោទ និងចុងចម្លើយបានរួមគំនិតគ្នាដោយទុច្ចរិត ដើម្បីបង្កើតពាក្យបណ្តឹង

២.ការរួមគំនិតគ្នានេះត្រូវបានធ្វើឡើងក្នុងគោលបំណងធ្វើឱ្យបាត់បង់សិទ្ធិ ឬផលប្រយោជន៍របស់តតិយជន តាមរយៈអានុភាពនៃសាលក្រម ឬសាលដីកាដែលមានការផ្សំគំនិតគ្នារវាងដើមចោទ និងចុងចម្លើយនោះ។[7]

[6] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ១៩៨,ចំណុច គ។

[7] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣១៨,កថាខណ្ឌទី១។

ឧបមាថាក្នុងករណីដែលលោក ក ជាកូនបំណុលរបស់លោក គ បានផ្សំគំនិតជាមួយមិត្តរបស់ខ្លួនឈ្មោះ លោក ខ ដើម្បីឱ្យលោក ខ ធ្វើការដាក់ពាក្យបណ្តឹងចំពោះលោក ក ដែលទាមទារឱ្យបញ្ជាក់កម្មសិទ្ធិលើ អចលនវត្ថុដែលជាកម្មសិទ្ធិរបស់លោក ក ដោយឱ្យលោក ខ អះអាងថាខ្លួនជាកម្មសិទ្ធិករវិញក្នុងគោលបំណង ឱ្យរួចផុតពីការអនុវត្តដោយបង្ខំពីលោក គ ដែលជាតតិយជនហើយលោក ក បានចាញ់ក្នុងបណ្តឹងដោយ ចេតនានោះលោក គ អាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសកម្មភាពដែលនាំឱ្យខូចប្រយោជន៍ ចំពោះសាលក្រមស្ថាពរដែលបញ្ជាក់ថាលោក ក ជាម្ចាស់កម្មសិទ្ធិនៃបណ្តឹងរវាងលោក ក និងលោក ខ។[8] ក្នុងករណីនេះបញ្ញត្តិនៃមាត្រា៤១ (បទបញ្ញាស្តីពីការវិនិច្ឆ័យលើសហបណ្តឹងចាំបាច់) នៃក្រមនីតិវិធីរដ្ឋប្បវេណី នេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះជនដែលជាសហចុងចម្លើយតាម កថាខណ្ឌទី២ ខាងលើ និងតតិយ ជនដែលបានដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។

### ១.៣.២. មូលហេតុនៃការជំនុំជម្រះសាជាថ្មី

#### ១.៣.២.១. មូលហេតុនៃការជំនុំជម្រះសាជាថ្មីដោយមានការបំពាននីតិវិធី

មូលហេតុនៃការជំនុំជម្រះសាជាថ្មី ត្រូវបានកម្រិតត្រឹមតែមាត្រាដែលមានចែងនៅក្នុងបញ្ញត្តិ មាត្រា៣០៧ និង មាត្រា៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ តែប៉ុណ្ណោះ។ ការអះអាងអំពីមូលហេតុនៃ ការជំនុំជម្រះសាជាថ្មី គឺជាលក្ខខណ្ឌដើម្បីឱ្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានភាពត្រឹមត្រូវតាមច្បាប់ ដូចនេះ ប្រសិនបើគ្មានការអះអាងអំពីមូលហេតុណាមួយទេ បណ្តឹងទាមទារជំនុំជម្រះសាជាថ្មីនឹងត្រូវបាន លើកចោល។ ប្រសិនបើតុលាការយល់ថាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីដូចភាគីបានអះអាង នោះ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានមូលហេតុត្រឹមត្រូវ ហើយតុលាការនឹងចាប់ផ្តើមនីតិវិធីវិនិច្ឆ័យសាជាថ្មី អំពីរឿងក្តីដែលត្រូវបានបញ្ចប់។

ក្នុងចំណោម មូលហេតុនៃការជំនុំជម្រះសាជាថ្មី ដែលមានចែងនៅក្នុងមាត្រា៣០៧ ចំណុច ក ដល់ ចំណុច គ នៃកថាខណ្ឌទី១ គឺជាមូលហេតុដូចគ្នានឹងមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខដែរ។ ប្រសិនបើមាន អត្ថិភាពនូវមូលហេតុទាំងនេះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានទទួលស្គាល់ ទោះបីជាមូលហេតុ នោះមាន ឬគ្មានឥទ្ធិពលដល់សាលក្រម ឬសាលដីកាក៏ដោយ។ ចំពោះចំណុចដែលមានចែងពីចំណុច ឃ ដល់ចំណុច ជ គឺជាករណីដែលធនធានជាមូលដ្ឋានសម្រាប់សាលក្រម ឬសាលដីកានោះមានវិការៈធ្ងន់ធ្ងរ ហើយមូលហេតុដែលបានរៀបរាប់ពីចំណុច ឈ ដល់ចំណុច ញ គឺជាករណីដែលសេចក្តីសម្រេចរបស់តុលាការ

[8] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, *នីតិវិធីបណ្តឹង* (ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិ វិធីរដ្ឋប្បវេណី,២០០៨),២៣៦។

ខ្លួនឯង ក្នុងការចេញសាលក្រម ឬសាលដីកានោះមានវិការៈធ្ងន់ធ្ងរ នៅក្នុងករណីដែលពាក់ព័ន្ធជាមួយមូលហេតុដែលមានចែងពីចំណុច ឃ ដល់ ញ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើទៅបានលុះត្រាតែយល់ឃើញថាមូលហេតុនោះមានឥទ្ធិពលដល់សេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ឬសាលដីកាប៉ុណ្ណោះ។ ក្នុងចំណោមមូលហេតុទាំងនេះ មូលហេតុដែលមានចែងក្នុងចំណុច ឃ ដល់ចំណុច ច គឺផ្អែកទៅលើការដែលមានបទល្មើសព្រហ្មទណ្ឌ ឬអំពើដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបទល្មើសព្រហ្មទណ្ឌក្នុងដំណើរការនៃការធ្វើឯកសារ ឬធនធានផ្សេងទៀត ឬការប្រមូលភស្តុតាង ដែលបានក្លាយទៅជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាស្ថាពរ។ នៅពេលដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី ដោយផ្អែកលើមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងនេះចាំបាច់ត្រូវឱ្យមានសាលក្រម ឬសាលដីកាដែលសម្រេចផ្ដន្ទាទោស ឬសេចក្ដីសម្រេចដាក់ពិន័យស៊ីវិលចំពោះបទល្មើសព្រហ្មទណ្ឌជាដើម។ នៅក្នុងករណីខាងលើនេះប្រសិនជាមិនអាចទទួលបាននូវសាលក្រម ឬសាលដីកាសម្រេចផ្ដន្ទាទោស ឬសេចក្ដីសម្រេចដាក់ពិន័យស៊ីវិលដោយសារក្រៅពីមូលហេតុថា ភស្តុតាងមិនគ្រប់គ្រាន់ ដូចជាករណីដែលជនជាប់ចោទទទួលមរណភាព ឬករណីជនជាប់ចោទឬទណ្ឌិតបានទទួលការលើកលែងទោសជាដើម បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើឡើងដោយគ្មានសាលក្រម ឬសាលដីកាសម្រេចផ្ដន្ទាទោស ឬសេចក្ដីសម្រេចដាក់ពិន័យស៊ីវិលនោះ។[9]

ដើម្បីងាយស្រួលក្នុងការសិក្សាទៅលើប្រធានបទនេះ អ្នកស្រាវជ្រាវសូមអនុញ្ញាតធ្វើការបែងចែកចេញជា០៥(ប្រាំ)ករណីធំៗដែលរួមមានដូចជា៖ ក. ករណីដែលមានការបំពាននីតិវិធីធ្ងន់ធ្ងរ ខ. ករណីដែលបទល្មើសអ្នកដទៃមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ គ. ករណីខ្លឹមសារនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរផ្ទុយគ្នានឹងខ្លឹមសារនៃសាលក្រម ឬសាលដីកាមុនដែលបានចូលជាស្ថាពរ ឃ. ករណីដែលមានការភ្លេចបញ្ចូលការវិនិច្ឆ័យនៅក្នុងសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ ង. ករណីដែលខ្លឹមសារនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរមានភាពផ្ទុយគ្នានឹងខ្លឹមសារនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរមុន។

### ក. ករណីមានការបំពានទៅនឹងនីតិវិធីយ៉ាងធ្ងន់ធ្ងរ

សាលក្រម ឬសាលដីកាអាចចងភាគីបានលុះត្រាតែសាលក្រម ឬសាលដីកា មានការធានានូវនីតិវិធីត្រឹមត្រូវ។ ប៉ុន្តែបើសិនជាមានការធ្វើផ្ទុយនឹងនីតិវិធីធ្ងន់ធ្ងរ គឺមិនមានការធានាអំពីនីតិវិធីទេ។ ដូចច្នេះលក្ខខណ្ឌដែលជាអានុភាពចងនៃសាលក្រម ឬសាលដីកានោះពុំមានឡើយ។ ហេតុនេះហើយ ការធ្វើផ្ទុយនឹងនីតិវិធី គឺ

[9] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា,*នីតិវិធីបណ្ដឹង* (ភាគ១ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី,២០០៨),២៣៣។

ជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ទោះជាការធ្វើផ្ទុយនឹងនីតិវិធីនោះមានឥទ្ធិពលទៅលើខ្លឹមសារនៃសាលក្រម ឬសាដីកានោះ ឬគ្មានក៏ដោយ។[10]

ករណីបើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬសាលដីកាទៅតាមច្បាប់កំណត់ដែលមានដូចជា ការធ្វើការចេញសាលក្រម ឬសាដីកាដោយចៅក្រមផ្សេងក្រៅពីចៅក្រមដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ មាត្រា១៨៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលក្រម ឬសាលដីកាដែលបានចេញដោយប្រធានសាលាដំបូង ក្នុងឋានៈជាប្រធានតុលាការជំនាញ និងករណីដែលតុលាការគ្មានសមត្ថកិច្ចបានចេញសាលក្រម ឬសាលដីកា។ ហើយបើក្នុងគោលការណ៍ច្បាប់បានកំណត់ថា ការសម្រេចសេចក្តីត្រូវធ្វើដោយចៅក្រម ៣រូបតែបែរទៅជាធ្វើការសម្រេចសេចក្តីដោយចៅក្រម ២រូបទៅវិញ។[11] មានន័យថាច្បាប់បានចែងកំណត់បែបណាចៅក្រមត្រូវតែអនុវត្តតាម ក្នុងករណីដែលចៅក្រមអនុវត្តផ្ទុយពីច្បាប់ ជាហេតុនាំឱ្យមានការបំពាននីតិវិធីយ៉ាងធ្ងន់ធ្ងរ ដែលបង្កើតបានជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ មួយវិញទៀត ចំពោះចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាតាមច្បាប់បែរជាបានចូលរួមក្នុងការចេញសាលក្រម ឬសាលដីកា។

ចៅក្រមដែលពុំអាចចូលរួមក្នុងការសម្រេចសេចក្តី គឺជាចៅក្រមដែលត្រូវបានដកហូតចេញពីមុខងាររបស់ខ្លួន ហើយចៅក្រមរូបនោះបានចូលរួមក្នុងការជំនុំជម្រះ និងចេញសាលក្រម ឬសាលដីកាតាមមាត្រា២៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយបានចូលរួមក្នុងការវិនិច្ឆ័យជម្រះក្តី និងបានចេញសាលក្រម ឬសាលដីកានោះ មានដូចជា ករណីសហព័ទ្ធ ឬអតីតសហព័ទ្ធរបស់ចៅក្រមជាភាគីក្នុងរឿងក្តីនោះ។[12] ករណីដែលចៅក្រមដែលទទួលបន្ទុករឿងក្តីធ្លាប់ ឬកំពុងមានវិវាទនៅតុលាការជាមួយនឹងភាគីណាមួយ។[13] ចៅក្រមដែលត្រូវបានប្តឹងជិតចិត្ត ដោយសារតែករណីបណ្តាលឱ្យមានភាពលម្អៀងក្នុងការជម្រះក្តី និងចៅក្រមដែលបានចេញសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃការទាមទារជំនុំជម្រះសាជាថ្មីបានចូលរួមក្នុងការជំនុំជម្រះក្តី និងសម្រេចសេចក្តីអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ។

ម្យ៉ាងវិញទៀត ករណីខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដែលច្បាប់បានកំណត់ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬខ្វះសិទ្ធិតំណាងដោយអាណត្តិ ក៏ជាការបំពាននីតិវិធី

[10] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama (បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី),៤១។

[11] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ២៣,កថាខណ្ឌទី៣។

[12] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ២៧,កថាខណ្ឌទី១,ក។

[13] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ២៧,កថាខណ្ឌទី១,ចំណុច ឃ។

យ៉ាងធ្ងន់ធ្ងរដែរ។[14] ដោយច្បាប់បានចាត់ទុកថាមានការខ្វះសិទ្ធិតំណាង ឬអ្នកតំណាងខ្វះការប្រគល់សិទ្ធិ ជាបញ្ហាដ៏ធំដែលនាំឱ្យប៉ះពាល់ដល់នីតិវិធីនៃបណ្ដឹងដែលអាចឱ្យភាគីចាញ់ក្ដីដោយសារតែភាគីមិនបានធ្វើការអះអាង មិនបានធ្វើសេចក្ដីថ្លែងការណ៍ដោយខ្លួនឯង ជាហេតុនាំឱ្យប៉ះពាល់ដល់គោលការណ៍សិទ្ធិជម្រះក្ដីរបស់ភាគី ហើយប្រសិនជាច្បាប់មិនបានបើកសិទ្ធិឱ្យភាគីនៃបណ្ដឹងធ្វើការជំនុំជម្រះសាជាថ្មីនោះទេ នោះវាកាន់តែធ្វើឱ្យភាគីរងនូវភាពអយុត្តិធម៌ដោយគ្មានមូលហេតុអ្វីសោះ។

ជាក់ស្ដែង បើបុគ្គលម្នាក់មិនមែនជាអ្នកអាណាព្យាបាលទេ តែបានធ្វើសកម្មភាពបណ្ដឹងក្នុងនាមជាអ្នកអាណាព្យាបាល និងមេធាវីដែលគ្មានការតំណាងអាណត្តិបានធ្វើសកម្មភាពបណ្ដឹងឱ្យកូនក្ដី អ្នកដែលពុំមានសិទ្ធិតំណាងបានធ្វើសកម្មភាពបណ្ដឹងក្នុងនាមជាអ្នកតំណាងរបស់នីតិបុគ្គលជាអាទិ៍។ ហើយមូលហេតុចំណុចនេះផងដែរ អំឡុងពេលគឺមានលក្ខណៈផ្ទុយអំពីអំឡុងពេលដែលអាចប្ដឹងទាមទារជំនុំជម្រះសាជាថ្មីក្នុងចំណោមមូលហេតុផ្សេងៗ ដែលមានរយៈពេល ៣០ថ្ងៃដោយគិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មីក្រោយពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរហើយ និងពុំអាចធ្វើការប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទេ ប្រសិនបើអំឡុងពេល ០៥ឆ្នាំបានកន្លងផុត ដោយគិតពីថ្ងៃដែលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ឬគិតពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើងក្នុងករណីដែលមូលហេតុកើតឡើងក្រោយពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ប៉ុន្តែចំពោះមូលហេតុនៃការជំនុំជម្រះ សាជាថ្មីដែលបានកំណត់នៅក្នុងចំណុចនេះ គឺត្រូវបានលើកលែងចំពោះការកម្រិតអំឡុងពេលនៃការដាក់ពាក្យបណ្ដឹងតាមមាត្រា៣១១ កថាខណ្ឌទី១ វាក្យខណ្ឌទី២ និងកថាខណ្ឌទី៣ វាក្យខណ្ឌទី២។ មានន័យថា ភាគីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី អាចធ្វើការប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនៅពេលណាក៏បាន ដោយមិនចាំបាច់ពិចារណា ឬគិតអំពីអំឡុងពេលដែលច្បាប់បានកំណត់នោះទេ ។

### ខ. ករណីបទល្មើសរបស់អ្នកដទៃដែលមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា

បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាបានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្ដី[15] គឺជាមូលហេតុដែលផ្អែកលើបទល្មើសព្រហ្មទណ្ឌ ដោយទាមទារឱ្យមានសាលក្រម ឬសាលដីកាដែលចូលជាស្ថាពរ ហេតុនេះនៅពេលដែលដាក់ពាក្យបណ្ដឹងទាមទារឱ្យជម្រះសាជាថ្មីដោយផ្អែកលើមូលហេតុនេះ ចាំបាច់ត្រូវមានសាលក្រម ឬសាលដីកាស្ថាពរ ដែលត្រូវបានផ្ដន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីដែលភាគីមិនអាចទទួលបាននូវសាលក្រម ឬសាលដីកាផ្ដន្ទាទោស ដោយសារមរណភាពជនត្រូវចោទ

[14] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ២៧,កថាខណ្ឌទី១,ចំណុចគ។

[15] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី១,ចំណុចឃ។

ឬទណ្ឌិតត្រូវបានលើកលែងទោស បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីអាចធ្វើបានដោយគ្មានសាលក្រម ឬសាដីកាស្ថាពរ (ផ្តន្ទាទោស)នោះ ប៉ុន្តែត្រូវមានភស្តុតាងអំពីអង្គហេតុស៊ីសំណូក។[16] មានន័យថា ប្រសិនបើចៅក្រមបានប្រព្រឹត្តបទល្មើសស៊ីសំណូកត្រូវមានភស្តុតាងអំពីអង្គហេតុស៊ីសំណូកនោះមកបញ្ជាក់។

ម្យ៉ាងវិញទៀត បើភាគីបានសារភាព ឬត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬសាលដីកាដោយបទល្មើសរបស់អ្នកដទៃ។[17] មានន័យថាភាគីបានសារភាព ឬមិនបានដាក់មធ្យោបាយតទល់ ឬការពារខ្លួន ដោយសារតែមានការគាបសង្កត់ដោយសារភាគីម្ខាងទៀត ឬតតិយជន។ ចំពោះបទល្មើសដែលបានកើតឡើងនៅក្នុងស្ថានភាពនេះមានដូចជា៖

- បទហិង្សាដោយចេតនា ដែលមានចែងក្នុងមាត្រា២១៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដោយសារតែបានទទួលអំពើហិង្សាពីតតិយជន ទើបភាគីមិនហ៊ានអះអាងអំពីការសង ឬក៏មិនបានដាក់ភស្តុតាងសំខាន់ៗ។

- បទគំរាមកំហែង ដែលមានចែងនៅក្នុងមាត្រា២៣១ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដោយសាតែដើមចោទគំរាមកំហែងទើបចុងចម្លើយសារភាព។[18] ជាក់ស្តែង ក បណ្តឹង ខ ទៅសាលាដំបូងរាជធានីភ្នំពេញដោយទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ ខ បង់ប្រាក់ទៅឱ្យ ក។ ខ បានទទួលស្គាល់អង្គហេតុខ្ចីប្រាក់ ប៉ុន្តែមិនទទួលការទាមទាររបស់ ក ទេ ដោយសារខ្លួនបានសងរួចរាល់ហើយ ខ មានបំណងចង់ដាក់ភស្តុតាងអំពីការសងនេះទៅតុលាការ នៅពេលដែលតុលាការបង្គាប់ឱ្យដាក់ភស្តុតាង ប៉ុន្តែ ខ មិនបានដាក់នោះទេ ដោយសារខ្លួនត្រូវបាន ក កំរាមកំហែងជាច្រើនលើកថា បើហ៊ានដាក់ភស្តុតាងស្តីពីការសងនេះ ក នឹងធ្វើទារុណកម្មកូនរបស់ ខ ដោយសារការគំរាមកំហែងនេះ ខ មិនហ៊ានដាក់ភស្តុតាងនោះឡើយ ហេតុនេះតុលាការបានចេញសាលក្រមតាមការទាមទាររបស់ ក ហើយសាលក្រមបានចូលជាស្ថាពរ។

មូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលបានកំណត់នៅក្នុងចំណុច ង នេះជាមូលហេតុដែលផ្អែកលើបទល្មើសព្រហ្មទណ្ឌ ដែលរារាំងភាគីក្នុងការដាក់មធ្យោបាយការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬសាលដីកា ហេតុនេះនៅពេលដែលដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយផ្អែកលើមូលហេតុនេះចាំបាច់ត្រូវមានសាលក្រម ឬសាលដីកាស្ថាពរដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើសព្រហ្មទណ្ឌ។ ក្នុងករណីភាគីមិនអាចទទួលបានសាលក្រម ឬសាលដីកាផ្តន្ទាទោសដោយសារមរណភាពជនត្រូវចោទ ឬទណ្ឌិត

[16] លោកមេធាវី អ៊ីវ ប៉ូលី,សិក្ខាសាលាស្តីពី *(នីតិវិធីនៃការជំនុំជម្រះសាជាថ្មី)*,អនុស្សរណៈនៃការយោគយល់រវាងវិភាគទានច្បាប់ និងក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ, ២៨ មករា ២០២៤,២៤។

[17] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី១, ង។

[18] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama (បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី),៤៧។

ត្រូវបានលើកលែងទោស បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើបានដោយគ្មានសាលក្រម ឬសាលដីកាស្ថាពរនោះ ប៉ុន្តែត្រូវមានភស្តុតាងអំពីអង្គហេតុគំរាមកំហែងបង្ហាញរូបអាក្រាត និងហិង្សារដោយចេតនានោះ។[19] លើសពីនេះចំពោះឯកសារ ឬវត្ថុឯទៀតដែលបានក្លាយជាវត្ថុតាងសម្រាប់សាលក្រម ឬសាលដីកាត្រូវបានក្លែង ឬកែប្រែដោយបន្លំ។[20] ជាមូលហេតុនៃការជម្រះសាជាថ្មីដែលជាមូលហេតុផ្អែកលើបទល្មើសព្រហ្មទណ្ឌ ដោយឯកសារដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬសាលដីកាត្រូវបានក្លែងកែប្រែដោយបន្លំ ហេតុនេះនៅពេលដែលដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយផ្អែកលើមូលហេតុនេះចាំបាច់ត្រូវមានសាលក្រម ឬសាលដីកាស្ថាពរដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើសព្រហ្មទណ្ឌនោះ។ ក្នុងករណីដែលភាគីមិនអាចទទួលបាននូវសាក្រម ឬសាដីកាផ្តន្ទាទោស ដោយសារមរណភាពជនត្រូវចោទ ឬទណ្ឌិតត្រូវបានលើកលែងទោស បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីអាចធ្វើបានដោយគ្មានសាលក្រម ឬសាលដីកាស្ថាពរ (ផ្តន្ទាទោស) នោះ ប៉ុន្តែត្រូវមានភស្តុតាងបញ្ជាក់ថាឯកសារនោះក្លែង (លទ្ធផលកោសលវិច័យ) ទើបភាគីអាចធ្វើការប្តឹងទាមទារជំនុំជម្រះសាជាថ្មីបាន មិនអាចគ្រាន់តែអះអាងដោយគ្មានអំណះអំណាងបានឡើយ ប្រសិនបើដើមចោទមិនទទួលបានសាលក្រម ឬសាលដីកាស្ថាពរ ឬភស្តុតាងបញ្ជាក់នោះទេ នោះដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមិនអាចត្រូវទទួលយកបានឡើយ។

បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគីដែលបានធ្វើសម្បថ ឬរបស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬសាលដីកា។[21] ប្រសិនបើការថ្លែងការណ៍មិនពិតរបស់បុគ្គលដែលមានកាតព្វកិច្ចដូចជា សាក្សី អ្នកបកប្រែ អ្នកធ្វើកោសលវិច័យ បានធ្វើឱ្យតុលាការជឿជាក់ថាអង្គហេតុដែលបានអះអាងនោះជាអង្គហេតុពិត ហើយតុលាការបានចេញសាលក្រម ឬសាលដីកាស្ថាពរ។ តែក្រោយមកស្រាប់តែបុគ្គលដែលបានធ្វើសេចក្តីថ្លែងការណ៍នោះត្រូវបានតុលាការរកឃើញថាជាសេចក្តីថ្លែងការណ៍មិនពិត ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោស។ ភាគីដែលចាញ់បណ្តឹង ឬក្តីដោយសារមូលហេតុនោះ អាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន។ មូលហេតុនៃការជំនុំជម្រះសាជាថ្មី ដែលមានកំណត់នៅក្នុងចំណុច " ឆ " នេះជាមូលហេតុដែលផ្អែកលើបទល្មើសព្រហ្មទណ្ឌដែលសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬសាលដីកា ហេតុនេះនៅពេលដែលដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយផ្អែកលើ

[19] លោកមេធាវី អ៊ីវ ប៉ូលី,សិក្ខាសាលាស្តីពី*(នីតិវិធីនៃការជំនុំជម្រះសាជាថ្មី)*,អនុស្សរណៈនៃការយោគយល់រវាងវិភាគទានច្បាប់ និងក្រុមហ៊ុនមេធាវីកម្ពុជា សហប្រតិបត្តិការអន្តរជាតិ, ២៨ មករា ២០២៤,២៨។

[20] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី១, ច។

[21] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី១,ឆ។

មូលហេតុនេះ ចាំបាច់ត្រូវមានសាលក្រម ឬសាលដីកាស្ថាពរដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើសព្រហ្មទណ្ឌ។[22]

ក្នុងករណីភាគីមិនអាចទទួលបានសាលក្រម ឬសាលដីកាផ្តន្ទាទោស ដោយសាមរណភាពជនត្រូវចោទ ឬទណ្ឌិតត្រូវបានលើកលែងទោស បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចធ្វើបានដោយគ្មានសាលក្រម ឬសាលដីកាស្ថាពរ (ផ្តន្ទាទោស) នោះ ប៉ុន្តែ ត្រូវមានភស្តុតាងបញ្ជាក់ថាសេចក្តីថ្លែងការណ៍របស់សាក្សីមិនមែនជាការពិតទេវាគឺ ជាការកុហក។ បទល្មើសព្រហ្មទណ្ឌដែលមានក្នុងរូបភាពនេះដូចជា បទផ្តល់សក្ខីកម្មក្លែងក្លាយ បទក្លែងដោយអ្នកជំនាញ បទស៊ីសំណូករបស់អ្នកបកប្រែ អំពើក្លែងបន្លំ សេចក្តីថ្លែងការណ៍ជាដើម។

### គ. ករណីផ្លាស់ប្តូរសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ

បើសាលក្រម ឬសាលដីកា ឬសេចក្តីសម្រេចផ្សេងទៀត នៃផ្នែករដ្ឋប្បវេណី ឬផ្នែកព្រហ្មទណ្ឌ ឬការចាត់ចែងផ្នែករដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាត្រូវបានផ្លាស់ប្តូរដោយសារសេចក្តីសម្រេច ឬការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ។[23] មានន័យថា អាចមានករណីដែលសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ ត្រូវបានសម្រេចដោយយកសាលក្រម ឬសាលដីកា ឬការចាត់ចែងរដ្ឋបាលពិសេសណាមួយមកធ្វើជាមូលដ្ឋាន។ ក្នុងករណីបែបនេះ បើសិនជាសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ ត្រូវបានសម្រេចដោយយកសាលក្រម ឬសាលដីកា ឬការចាត់ចែងរដ្ឋបាលពិសេសណាមួយមកធ្វើជាមូលដ្ឋាន ត្រូវបានផ្លាស់ប្តូរ ទាំងនេះក៏ជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែរ ដោយសារតែគេគិតថាគប្បីដោះស្រាយវិវាទដែលពាក់ព័ន្ធឱ្យមានឯកភាព។[24]

ចំពោះការចាត់ចែងរដ្ឋបាល ឧបមាថាលោក ក បានលក់ដី L ដែលជាកម្មសិទ្ធិរបស់ខ្លួនទៅឱ្យលោក ខ លក់ក្នុងតម្លៃ ១០០០០ដុល្លារអាមេរិកបូកនឹង ១០០ដុល្លារអាមេរិកដែលជាពន្ធលើអចលនទ្រព្យក្នុងឆ្នាំនោះ។ លោក ខ បានបង់ប្រាក់ ១០០០០ដុល្លារអាមេរិករួចហើយតែគាត់មិនបានបង់ប្រាក់១០០ដុល្លារអាមេរិកទេ ព្រោះគាត់និយាយថា ១០០ដុល្លារអាមេរិកដែលជាប្រាក់ពន្ធលើអចលនទ្រព្យនោះមានបញ្ហា។ លោក ក បានប្តឹងលោក ខ ទៅតុលាការ ហើយតុលាការបានទទួលស្គាល់នូវប្រាក់១០០ដុល្លារអាមេរិកនោះ ហើយសាលក្រមបានចូលជាស្ថាពរ។ តែបន្ទាប់ពីពេលនោះការយកពន្ធលើអចលនទ្រព្យនោះត្រូវបានលុបចោល។ លោក ខ អាចដាក់ពាក្យ

[22] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី២,ចំណុច ក។

[23] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី១,ចំណុច ជ។

[24] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama (បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី),៥១។

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ដោយហេតុថា មានការផ្លាស់ប្ដូរនូវការចាត់ចែងផ្នែករដ្ឋបាលដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកានោះ។

ចំពោះការចាត់ចែងខាងផ្នែកព្រហ្មទណ្ឌវិញ ដូចជាករណី ក ជាដើមចោទ ខ ជាចុងចម្លើយ សាលាដំបូងបានចេញសាលក្រមបង្គាប់ឱ្យ ខ បង់ប្រាក់ផ្អែកលើអំពើអនីត្យានុកូល (ករណីឃាតកម្ម) ដោយភ្ជាប់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងបានផ្ដន្ទាទោស ខ ដែលបានសម្លាប់ គ ត្រូវជាកូនរបស់ ក បានចូលជាស្ថាពរ។ សន្មតថាសាលក្រមព្រហ្មទណ្ឌដែលបានចូលជាស្ថាពរនេះមានមូលហេតុនៃការសើរើ ហេតុនេះ ខ បានដាក់ពាក្យបណ្ដឹងសើរើទៅតុលាការកំពូលតាមនីតិវិធីព្រហ្មទណ្ឌ ទាមទារឱ្យសើរើសំណុំរឿងឃាតកម្មនេះ។ ជាលទ្ធផលតុលាការកំពូលទទួលយកការទាមទាររបស់ ខ មូលហេតុ គ ត្រូវបានសម្លាប់ដោយ ឃ មិនមែន ខ ជាអ្នកសម្លាប់នោះទេ។ ផ្អែកលើសាលដីកាព្រហ្មទណ្ឌដែលបានសើរើ និងលើកលែងចោទប្រកាន់ចំពោះ ខ គឺ ខ អាចដាក់ពាក្យបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី ទៅសាលាដំបូងរាជធានីភ្នំពេញចំពោះ សាលក្រមរដ្ឋប្បវេណីស្ថាពរដែលបានបង្គាប់ឱ្យ ខ បង់ប្រាក់មក ក។ ករណីនេះហៅថា សេចក្ដីសម្រេចផ្នែកព្រហ្មទណ្ឌដែលជាមូលដ្ឋាននៃសាលក្រមរដ្ឋប្បវេណីត្រូវបានផ្លាស់ប្ដូរ។

## ឃ. ករណីភ្លេចបញ្ចូលចំណុចសំខាន់ៗទៅលើសាលក្រម ឬសាលដីកា

បើមានការភ្លេចបញ្ចូលសេចក្ដីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា។[25] ក្នុងករណីដែលតុលាការ បានភ្លេចបញ្ចូល ឬមិនបានបញ្ចូលនូវចំណុចសំខាន់ដែលភាគីបានធ្វើការអះអាង ហើយការភ្លេចបញ្ចូលនូវចំណុចសំខាន់ៗ ជាហេតុដែលធ្វើឱ្យអ្នកទាមទារនោះបានចាញ់ក្ដីនៅក្នុងនីតិវិធីបណ្ដឹង។ ក្នុងករណីនេះភាគីនោះអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ព្រោះប្រសិនជាច្បាប់មិនបានបើកសិទ្ធិឱ្យប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទេ នោះវាហាក់បីដូចជាដាក់បន្ទុកយ៉ាងធ្ងន់ធ្ងរ ធ្វើឱ្យគាត់ខាតបង់ផលប្រយោជន៍ ធ្វើឱ្យគាត់ចាញ់ក្ដីដោយសារតែមិនមែនជាកំហុសរបស់ខ្លួន។

ចំណុចសំខាន់ៗ នេះ គឺសំដៅទៅលើមធ្យោបាយតទល់ ឬការពារខ្លួនដែលភាគីបានអះអាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ចំពោះចំណុចណាមួយដែលមានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬសាលដីកា តុលាការត្រូវតែធ្វើការវិនិច្ឆ័យចំណុចសំខាន់នេះ ទាមទារឱ្យតុលាការធ្វើការវិនិច្ឆ័យ និងបង្ហាញពីការវិនិច្ឆ័យរបស់ខ្លួនក្នុងសំអាងហេតុនៃសាលក្រម ឬសាលដីកា។ ក្នុងករណីដែលតុលាការមិនបានធ្វើការវិនិច្ឆ័យចំពោះមធ្យោបាយតទល់ ឬការពារខ្លួនដែលមានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬសាលដីកា វាអាចធ្វើឱ្យមានការប្រែប្រួលនូវខ្លឹមសារនៃសាលក្រម ឬសាលដីកា។ ការភ្លេចបញ្ចូលនូវការវិនិច្ឆ័យដែល

[25] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី ១,ចំណុច ឈ។

មានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា មានន័យថា ប្រសិនសិនបើតុលាការបានវិនិច្ឆ័យអំពីចំណុច នោះ រឿងក្តីអាចប្រែពីចាញ់មកឈ្នះ ឬពីឈ្នះមកចាញ់ ព្រោះការអះអាងនោះមានសារៈសំខាន់។

**ខ. ករណីមានភាពផ្ទុយគ្នានៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរមុន**

បើសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានការប៉ះពាល់ដល់សាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរហើយ[26] សាលក្រម ឬសាលដីកាពីរ ដែលបានជំនុំជម្រះទៅលើសំណុំរឿងក្តីតែមួយ តែសាលក្រម ឬសាលដីកាក្រោយដែលបានចេញមានខ្លឹមសារផ្ទុយគ្នាទៅនឹងសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរម្តងរួចហើយ នោះចាំបាច់ត្រូវធ្វើការជំនុំជម្រះសាជាថ្មីដើម្បីស្វែងរកភាពត្រឹមត្រូវសម្រេចឱ្យភាគីណាចាញ់ ឬភាគីណាឈ្នះលើការទាមទារ។

ឧបមាថា ដើមចោទប្តឹងចុងចម្លើយទាមទារប្រាក់ចំនួន ១០០០០ដុល្លារអាមេរិក ផ្អែកលើកិច្ចសន្យាលក់ទិញ។ តុលាការបានចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ ហើយសាលក្រមនោះបានចូលជាស្ថាពរ។ បន្ទាប់មកទើបចុងចម្លើយដឹងថាកិច្ចសន្យាលក់ទិញនោះមានវិការៈក្នុងការបង្ហាញឆន្ទៈដោយសារការឆបោក ហើយចុងចម្លើយបានបង្ហាញឆន្ទៈលុបចោលកិច្ចសន្យា និងធ្វើបណ្តឹងទាមទារបញ្ជាក់អំពីនត្ថិភាពនៃកាតព្វកិច្ច ផ្អែកលើការលុបចោលកិច្ចសន្យា។

តាមរយៈការលើកឡើងខាងលើ សាលក្រមស្ថាពរទីមួយទទួលស្គាល់ឱ្យបង់ប្រាក់ថ្លៃលក់ទិញ និងសាលក្រមស្ថាពរទីពីរសម្រេចអំពីនត្ថិភាពនៃកាតព្វកិច្ចផ្អែកលើការលុបចោលកិច្ចសន្យាលក់ទិញ។ ហេតុនេះចុងចម្លើយអាចប្តឹងទាមទារឱ្យលុបចោលសាលក្រមទីមួយ ហើយអនុវត្តសាលក្រមទីពីរបាន។ ក៏ប៉ុន្តែផ្ទុយទៅវិញប្រសិនជាករណីដែលគ្រាន់តែរកឃើញភស្តុតាងថ្មី នោះភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទេ ប្រសិនជាភាគីបានអះអាងថាបានរកឃើញភស្តុតាងថ្មីនោះនៅក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ តុលាការត្រូវច្រានចោលពាក្យបណ្តឹងនោះដើម្បីកុំឱ្យមានភាពយឺតយ៉ាវតាមរយៈមាត្រា៣១៤ កថាខណ្ឌទី២។

**១.៣.២.២. មូលហេតុនៃការជំនុំជម្រះសាជាថ្មីលើដីកាសម្រេច**

ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់អំពីមូលហេតុផ្សេងទៀត ដែលមានចែងនៅក្នុងមាត្រា៣០៨ ក្នុងករណីដែលសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាមានមូលហេតុនៃការជំនុំជម្រះសាថ្មីដូចដែលបានរៀបរាប់នៅក្នុងមាត្រា៣០៧ ខាងលើ ទោះបីជាបានកំណត់មធ្យោបាយនៃឧបាស្រ័យ។ ចំពោះសេចក្តីសម្រេចនោះក៏ដោយ ក៏ភាគីអាចលើកយកមូលហេតុនៃការជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ

[26] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី១,ចំណុច ញ។

សាលដីកានោះបានដែរ។ សេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកា គឺចង្អុលទៅលើសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាចុងក្រោយដែលស្ថាពរហើយ អាចនឹងប៉ះពាល់ទៅលើអត្ថន័យរបស់សាលក្រម ឬសាលដីកានោះ។ ទោះបីជាសាលក្រម ឬសាលដីកាចុងក្រោយគ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ តែបើនៅក្នុងសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ភាគីអាចធ្វើការប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយផ្ទាល់ចំពោះសាលក្រម ឬសាលដីកាចុងក្រោយនោះបាន។

សេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកានោះមានដូចជា៖

-ដីកាសម្រេចច្រានចោលពាក្យសុំឱ្យផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង។[27]

-ដីកាសម្រេចច្រានចោលពាក្យសុំទទួលបន្តនីតិវិធីបណ្តឹង។[28]

-ដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យយោងតាមមាត្រា៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-សាលក្រមរបៀប គឺជាសេចក្តីសម្រេចជាមូលដ្ឋាននៃសាក្រម ឬសាលដីកាតែវាពុំមែនជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយឯករាជ្យនោះទេ។ ដូចនេះបើសិនករណីដែលសាលក្រមរបៀបមានវិការៈ មានន័យថាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ភាគីអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីភ្ជាប់ទៅនឹងសាលក្រម ឬសាលដីកាដែលបានចេញនោះបាន ទោះបីជាសាលក្រម ឬសាលដីកាដែលបានចេញនោះពុំមានវិការៈក៏ដោយ។[29] បើអនុញ្ញាតឱ្យដាក់ពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីដោយឯករាជ្យចំពោះសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកា ហើយសេចក្តីសម្រេចនោះនឹងត្រូវបានលុបចោល នោះយើងត្រូវទទួលស្គាល់ផងដែរ នូវបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ យោងទៅតាមចំណុច ជ នៃមាត្រា៣០៧ ដែលជាហេតុនាំឱ្យខាតពេលច្រើន ព្រមទាំងមិនស្របនឹងសេដ្ឋកិច្ចនៃបណ្តឹងទៀតផង។[30] ផ្ទុយពីករណីខាងលើ ប្រសិនបើដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យបាន (ប្តឹងជំទាស់) ហើយចូលជាស្ថាពរ គឺអាចដាក់ពាក្យសុំទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយឯករាជ្យបានដោយមិនចាំបាច់ភ្ជាប់ទៅនឹងសាលក្រម ឬសាលដីកាស្ថាពរខាងលើទេ។ មានន័យថា ចំពោះដីកាសម្រេច

[27] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៨៤,កថាខណ្ឌទី៤។

[28] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ១៧៥,កថាខណ្ឌទី៣។

[29] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៨។

[30] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧),២៨៦។

ដែលមានភាពជាចុងក្រោយ ហើយក្រោយមកទៀតក៏ពុំមានភ្ជាប់ជាមួយសាលក្រម ឬសាលដីកាចុងក្រោយមកទៀតដែរ បើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក្នុងដីកាសម្រេចនោះ ត្រូវអនុញ្ញាតឱ្យប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យ។ ចំពោះការវិនិច្ឆ័យទៅលើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនៃដីកាសម្រេចនេះបញ្ញត្តិចាប់ពីមាត្រា៣០៧ មូលហេតុនៃការជំនុំជម្រះសាជាថ្មី(មួយ) រហូតដល់ដល់មាត្រា៣១៦ (ការវិនិច្ឆ័យ និងសម្រេចសេចក្ដីលើអង្គសេចក្ដី) ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

**១.៣.៣. កម្មវត្ថុនៃការជម្រះសាជាថ្មី**

ជាទូទៅបណ្ដឹងតវ៉ា ឬបណ្ដឹងឧបាស្រ័យផ្សេងៗ ដែលបានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនេះ មិនអាចប្ដឹងតវ៉ាចំពោះសាលក្រម ឬសាលដីកាស្ថាពរទេ តែចំពោះពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវតែមានសាលក្រម ឬសាលដីកាដែលចូលជាស្ថាពរ ហើយលើសពីនេះបញ្ញត្តិនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏បានអនុញ្ញាតឱ្យប្ដឹងទាមទារជំនុំជម្រះសាជាថ្មីទៅនឹងដីកាសម្រេចស្ថាពរនៃបណ្ដឹងជំទាស់ផងដែរ។ ដូចនេះពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីអាចប្ដឹងប្រឆាំងបានតែចំពោះសាលក្រម ឬសាដីកាដែលបានចូលជាស្ថាពរ(១.៣.៣.១) និងដីកាសម្រេចស្ថាពរ (១.៣.៣.២) របស់តុលាការតែប៉ុណ្ណោះ។

**១.៣.៣.១. សាលក្រមឬ សាលដីកាដែលបានចូលជាស្ថាពរ**

យោងតាមមាត្រា៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី បានចែងថាភាគីអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានចំពោះសាលក្រមចុងក្រោយ ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ។

សាលក្រម ឬសាលដីកាចុងក្រោយ សំដៅទៅលើសេចក្ដីសម្រេចរបស់តុលាការដែលបានបញ្ចប់ទៅលើរឿងក្ដីទាំងមូល ឬមួយភាគហើយត្រូវបានតុលាការប្រកាសសាលក្រមរួចទៅហើយ។ ម្យ៉ាងវិញទៀតកាលណាដែលសាលក្រម ឬសាដីកាបានចូលជាស្ថាពរហើយ សាលក្រម ឬសាលដីកានោះនឹងកើតមានអានុភាពអាជ្ញាអស់ជំនុំ។[31] សាលក្រម ឬសាដីកាដែលតុលាការបានចេញនោះ អាចជាសាលក្រម ឬសាលដីកាទទួលស្គាល់ការទាមទារ សាលក្រម ឬសាលដីកាលើកចោលការទាមទារ និងសាលក្រម ឬសាលដីកាច្រានចោលការទាមទារ។[32] ភាគីនៃបណ្ដឹងដើមអាចបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានតែទៅលើសាលក្រមចុង

[31] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ១៩៥,កថាខណ្ឌទី១។

[32] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា,*នីតិវិធីបណ្ដឹង* (ភាគ១ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី,២០០៨),១២៩។

ក្រោយ ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរតែប៉ុណ្ណោះ។[33] ក្នុងករណីដែលសាលក្រម ឬសាលដីកានោះមិនទាន់ត្រូវបានចូលជាស្ថាពរទេ ភាគីមិនអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ។

ម្យ៉ាងវិញទៀត បើតាមរយៈមាត្រា៣០៨ សាលក្រមរបៀបក៏ជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីផងដែរ។ ដូចដែលបានរៀបរាប់នៅខាងលើសាលក្រមរបៀប គឺជាសេចក្ដីសម្រេចជាមូលដ្ឋាននៃសាលក្រម ឬសាលដីកា តែវាមិនមែនជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយឯករាជ្យនោះទេ។ ក៏ប៉ុន្តែក្នុងករណីដែលសាលក្រមរបៀបនោះមាននិការៈ ដូចដែលបានកំណត់នៅក្នុងមាត្រា៣០៧ នោះសាលក្រមរបៀបក៏មានមូលហេតុនៃការជំនុំជម្រះសាជាថ្មីផងដែរ។ សាលក្រមរបៀបមិនអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយឯករាជ្យបានឡើយ មានន័យថា ប្រសិនជាសាលក្រមរបៀបមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ភាគីអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅលើសាលក្រម ឬសាដីកាដែលមានសាលក្រមរបៀបនោះតែម្ដង។[34] ប្រសិនបើសាលក្រមរបៀបជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី សាលក្រមរបៀបនឹងក្លាយទៅកម្មវត្ថុនៃការកែប្រែសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ។ ក្នុងករណីនេះអាច នាំឱ្យមានការជំនុំជម្រះសាជាថ្មីលើសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរសាជាថ្មីម្ដងទៀត ស្របទៅតាមមូលហេតុដូចដែលបានកំណត់ក្នុងមាត្រា៣០៧ កថាខណ្ឌទី១ ចំណុច ជ នៃក្រមនីតិវិធីរដ្ឋប្បវេណីដែលនាំឱ្យមានការជំនុំជម្រះសាជាថ្មីចំនួនពីរលើកទៅលើសំណុំរឿងតែមួយដែលបានកើតឡើង។

#### ១.៣.៣.២. ដីកាសម្រេច

ដីកាសម្រេច សំដៅដល់សេចក្ដីសម្រេចរបស់តុលាការ ឬចៅក្រមដែលអាចធ្វើបានដោយមិនចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ ហើយមិនមែនជាសាលក្រមទេ។[35]

ដីកាសម្រេចដែលធ្វើដោយចៅក្រម សំដៅទៅលើដីកាសម្រេចរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះក្នុងករណីដែលតុលាការជំនុំជម្រះរឿងក្ដីដោយក្រុមប្រឹក្សាជំនុំជម្រះ។[36] ជារួមដីកាសម្រេចក៏ជាសេចក្ដីសម្រេចរបស់តុលាការផងដែរ ហើយសេចក្ដីសម្រេចក៏មានស្ថានភាពដែលមាននិការៈ ឬមានមូលហេតុនៃការជម្រះសាជាថ្មី

---

[33] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៧,កថាខណ្ឌទី១។

[34] ឧទ្ទេសនាមដោយលោកមេធាវី អ៊ុំ ប៉ូលី ,សិក្ខាសាលា វិភាគទាន និងក្រុមមេធាវីសហប្រតិបត្តិការអន្តរជាតិ *ស្ដីអំពីការជំនុំជម្រះសាជាថ្មី* ,អនុស្សរណៈនៃការយោគយល់រវាងវិភាគទានច្បាប់ និងក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ(ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤),៦។

[35] www.khsearch.com ,ចូលមើលថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤។

[36] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា,*នីតិវិធីបណ្ដឹង* (ភាគ១ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី,២០០៨),១៥៥។

ផងដែរ ប្រសិនជាអង្គហេតុដែលបានកំណត់នៅក្នុងមាត្រា៣០៧ ចាប់ពីចំណុច ក រហូតដល់ចំណុច ញ បាន កើតនៅក្នុងដីកាសម្រេច។ មូលហេតុដែលច្បាប់បានផ្តល់ឱ្យនូវសិទ្ធិដល់ភាគីក្នុងការប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ទៅលើដីកាក៏ព្រោះតែដីកាសម្រេចវាមានឥទ្ធិពលទៅលើសាក្រម ឬសាលដីកា ហើយម្យ៉ាងវិញទៀតដីកាសម្រេចខ្លះវាមានអានុភាពអនុវត្តដូចទៅនឹងសាលក្រម ឬសាលដីកាស្ថាពរដែរ។

ដូចដែលបានរៀបរាប់នៅខាងលើ ចំពោះដីកាសម្រេចដែលបានធ្វើឡើងដើម្បីជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាចុងក្រោយ ប្រសិនបើមានមូលហេតុនៃការជម្រះសាជាថ្មី ដូចជាដីកាសម្រេចមិនទទួលយកភស្តុតាង (ផ្អែកតាមមាត្រា១២៦) នៃក្រមរដ្ឋប្បវេណី។[37] ដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួនដែលបានដាក់យឺតយ៉ាវ[38] ក៏ជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែរ ឱ្យតែមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី នៅក្នុងដីកាសម្រេចលើកចោលមធ្យោបាយតទល់ ឬការពារខ្លួននោះតែមិនអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យបានទេ។ ចំពោះដីកាសម្រេចដែលបានកំណត់នៅក្នុងមាត្រា៣១៧ ក៏អាចជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីបានដែរ ប្រសិនជាដីកាសម្រេចមានមូលហេតុនៃការជម្រះសាជាថ្មី។[39] ដីកាសម្រេចដែលបានកំណត់ក្នុងមាត្រា៣១៧ ខុសពីដីកាសម្រេចដែលបានកំណត់នៅក្នុងមាត្រា៣០៨ ដែលដីកាសម្រេចតាមមាត្រា៣១៧ វាមិនមែនជាដីកាសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាទេ តែវាជាដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យដោយបណ្តឹងជំទាស់ហើយបានចូលជាស្ថាពរ។ គ្រប់ដីកាសម្រេចទាំងអស់ដែលអាចប្តឹងជំទាស់បាន ហើយភាគីបានប្តឹងជំទាស់ បន្ទាប់មកប្រសិនជាដីកាសម្រេចដែលជាសេចក្តីសម្រេចរបស់បណ្តឹងជំទាស់បានចូលជាស្ថាពរ ទើបភាគីអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន។ តែប្រសិនជាដីកាសម្រេចដែលជាសេចក្តីសម្រេចនៃបណ្តឹងជំទាស់ មិនទាន់ត្រូវបានចូលជាស្ថាពរ ភាគីមិនអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទេ។ ដីកាសម្រេចនៃបណ្តឹងជំទាស់ដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីត្រូវបានប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយឯករាជ្យ ពោលគឺអាចប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅលើដីកាសម្រេចផ្ទាល់តែម្តងមិនចាំបាច់ប្តឹងភ្ជាប់ទៅលើសាលក្រម ឬសាលដីកាស្ថាពរ ដូចករណីដីកាសម្រេចដែលបានកំណត់នៅក្នុងមាត្រា៣០៨ ដែលជាដីកាសម្រេចជាមូលដ្ឋាននៃសាលក្រមឡើយ។ ដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្តឹងជំទាស់នេះមានដូចជា ដីកាសម្រេចអំពីការដកហូត ឬបណ្តឹងជិតចិត្តពុំត្រឹមត្រូវ មាត្រា៣០ កថាខណ្ឌទី៦ ដីកាសម្រេចលើកបណ្តឹងចោល មាត្រា៧៦ និងដីកាសម្រេចរក្សាការពារជាអាទិ៍។

[37] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ១២៦។

[38] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៩៤។

[39] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣១៧។

### ១.៣.៤. ការដាក់ពាក្យបណ្តឹង

ជាគោលការណ៍ ក្នុងករណីដែលភាគីនៃបណ្តឹងមានបំណងចង់ឱ្យតុលាការសម្រេចឱ្យបានត្រឹមត្រូវអំពីការទាមទាររបស់ខ្លួនប្រកបដោយភាពឆាប់រហ័ស និងដំណើរការដោយយ៉ាងរលូន ភាគីត្រូវដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅតុលាការដែលមានសមត្ថកិច្ចទៅតាមច្បាប់កំណត់។

លើសពីនេះដើម្បីឱ្យពាក្យបណ្តឹងមួយត្រឹមត្រូវតាមច្បាប់ ហើយអាចទទួលយកបាន ពាក្យបណ្តឹងត្រូវសរសេរឱ្យបានត្រឹមត្រូវទៅតាមទម្រង់ និងខ្លឹមសារដែលច្បាប់បានកំណត់ និងពិនិត្យមើលឱ្យបានគ្រប់ជ្រុងជ្រោយ។ម្យ៉ាងវិញទៀត ពាក្យបណ្តឹងត្រូវដាក់ឱ្យត្រូវទៅតាមតុលាការដែលមានសមត្ថកិច្ច ប្រសិនបើពាក្យបណ្តឹងត្រឹមត្រូវសព្វគ្រប់អស់ហើយ តែដើមចោទបានដាក់ពាក្យបណ្តឹងទៅតុលាការដែលគ្មានសមត្ថកិច្ចក៏គ្មានផលប្រយោជន៍អ្វីដែរ ហើយវានាំឱ្យមានភាពយឺតយ៉ាវ និងខាតពេលវេលា។

ដូចនេះដើម្បីឱ្យពាក្យបណ្តឹងមួយត្រឹមត្រូវ និងអាចទទួលយកបាន យើងត្រូវសិក្សាទៅលើសមត្ថកិច្ចនៃសាលាជម្រះក្តី (១.៣.៤.១) និងការពិនិត្យពាក្យបណ្តឹង(១.៣.៤.២)។

#### ១.៣.៤.១. សមត្ថកិច្ចនៃសាលាជម្រះក្តី

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានច្បាប់កំណត់ពីសមត្ថកិច្ចនៃសាលាជម្រះក្តីផងដែរ គឺស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដែលបានចេញសាលក្រម ឬសាលដីកា ដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី។[40] មានន័យថា ភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដែលបានចេញសាលក្រម ឬសាលដីកាដោយភាគីមិនអាចព្រមព្រៀងកំណត់អំពីតុលាការដែលមានសមត្ថកិច្ចតាមចិត្តខ្លួនបានឡើយ។ ជាគោលការណ៍ ប្រសិនបើសាលក្រមនៃសាលាដំបូងរាជធានី ខេត្ត ដែលចូលស្ថាពរ ហើយមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី នោះសាលាដំបូងតែមួយគត់ជាតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ ទៅលើពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។ ជាក់ស្តែង ដូចក្នុងករណីដែលសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញចូលជាស្ថាពរ ហើយមានមូលហេតុនៃការជម្រះសាជាថ្មី នោះសាលាដំបូងរាជធានីភ្នំពេញ គឺជាតុលាការដែលមានសមត្ថកិច្ចលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។ បើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រម ឬសាលដីកាអំពីរឿងក្តីតែមួយដែលត្រូវបានចេញដោយតុលាការច្រើនដែលមានថ្នាក់ខុសគ្នា តុលាការជាន់ខ្ពស់ (សាលាឧទ្ធរណ៍ និងតុលាការកំពូល) មានសមត្ថកិច្ចរួមបញ្ចូលនូវសាលក្រម ឬសាលដីកាទាំងនោះ។[41] មានន័យថា ក្នុងករណីដែល

[40] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៩,កថាខណ្ឌទី១។

[41] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៩,កថាខណ្ឌទី២។

សាលក្រមរបស់សាលាដំបូងត្រូវបានប្ដឹងទៅសាលាឧទ្ធរណ៍ ហើយតុលាការនៃបណ្ដឹងឧទ្ធរណ៍បានវិនិច្ឆ័យទៅលើអង្គសេចក្ដី នោះសាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ គឺជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី។ ដូចនេះត្រូវដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នោះទៅតុលាការនៃបណ្ដឹងឧទ្ធរណ៍ដែរ។[42]

ប៉ុន្តែ បន្ថែមពីលើករណីខាងលើប្រសិនបើមានការប្ដឹងសាទុក្ខចំពោះសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ ទៅតុលាការកំពូល ហើយតុលាការកំពូលបានចេញសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ នោះសាលដីការបស់តុលាការកំពូលដែលជាសេចក្ដីសម្រេចរបស់តុលាការដែលខ្ពស់ជាងគេ ត្រូវក្លាយទៅជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយតុលាការដែលមានសមត្ថកិច្ចផ្ដាច់មុខក្នុងការសម្រេចអំពីបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាតុលាការកំពូលតែមួយគត់។ តុលាការនៃបណ្ដឹងសាទុក្ខ គឺជាតុលាការដែលវិនិច្ឆ័យអង្គច្បាប់ ប៉ុន្តែជាករណីលើកលែង តុលាការនៃបណ្ដឹងសាទុក្ខអាចវិនិច្ឆ័យទៅលើអង្គហេតុ ចំពោះការស្រាវជ្រាវអំពីអត្ថិភាព ឬនត្ថិភាពនៃការជំនុំជម្រះសាជាថ្មី។[43] ចំពោះការវិនិច្ឆ័យអំពីអង្គសេចក្ដី គឺជានីតិវិធីបណ្ដឹង ហេតុនេះបញ្ញត្តិស្ដីពីនីតិវិធីបណ្ដឹងនៅតុលាការដែលមានលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗត្រូវយកមកអនុវត្តចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។[44] មានន័យថាក្នុងករណីកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីជាសាលក្រមស្ថាពររបស់តុលាការនៃការជំនុំជម្រះលើកទី១ នីតិវិធីវិនិច្ឆ័យ និងសម្រេចអំពីអង្គសេចក្ដីចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីនីតិវិធីបណ្ដឹងនៃតុលាការនៃការជំនុំជម្រះលើកទី១ ដែរ។ ប្រសិនបើជំនុំជម្រះសាជាថ្មីចំពោះសាលដីការបស់សាលាឧទ្ធរណ៍ បញ្ញត្តិស្ដីពីនីតិវិធីបណ្ដឹងនៃការជំនុំជម្រះលើកទី២ ត្រូវយកមកអនុវត្តដូចគ្នានឹងនីតិវិធីនៃការជំនុំជម្រះសាជាថ្មី។ ដោយសារតែមាត្រា៣១០ បានចែងថា បទបញ្ញត្តិទាក់ទងនឹងដំណាក់នៃការជំនុំជម្រះនីមួយៗត្រូវយកមកអនុវត្តទៅតាមបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីលើសាលាជម្រះក្ដីនីមួយៗនោះ។

បញ្ញត្តិដែលយកមកអនុវត្តដូចគ្នានោះ ដូចជាមាត្រា៧៨ (ការពិនិត្យបណ្ដឹង) ការលើកបណ្ដឹងចោលដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់[45] មាត្រា២៧០ (បណ្ដឹងឧទ្ធរណ៍បន្ទាប់បន្សំ) មាត្រា៨៦ (បណ្ដឹងតប) មាត្រា២១៧ (ការដកពាក្យបណ្ដឹង) មាត្រា២៧៨ (ទំហំនៃការផ្លាស់ប្ដូរសាលក្រមនៃការជំនុំជម្រះលើកទី១) ជាដើម។

[42] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama (បញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី),២៥។

[43] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧),២៨៧។

[44] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣១០។

[45] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៨១។

ដូចនេះ បញ្ញត្តិដែលបានរៀបរាប់ខាងលើនេះត្រូវយកមកអនុវត្តក្នុងករណីដែលមានបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។[46]

ម្យ៉ាងវិញទៀត ចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី ពុំអាចចូលរួមក្នុងការជម្រះ និងសម្រេចសេចក្តីអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ។[47] ប្រសិនបើរកឃើញថាចៅក្រមដែលបានចូលរួមបានចេញសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នោះវាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីទៀតចំណុច ខ នៃមាត្រា៣០៧ ដែលនិយាយអំពីការដកហូតចៅក្រម (មាត្រា២៧ ចំណុច ឆ) ក្នុងករណីនេះភាគីនៃបណ្តឹងអាចដាក់ពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីម្តងទៀតបាន។

**១.៣.៤.២. ការពិនិត្យពាក្យបណ្តឹង**

មុននឹងឈានទៅដល់ការពិនិត្យពាក្យបណ្តឹង ជាដំបូងភាគីត្រូវដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីជាលាយលក្ខណ៍អក្សរ នៅតុលាការដែលបានចេញសាលក្រម ឬសាលដីកានៅឯការិយាល័យរដ្ឋបាលរបស់តុលាការ ហើយការពិនិត្យពាក្យបណ្តឹងនេះផងដែរគឺ មានមានដូចជា ការពិនិត្យអំពីពន្ធដាក់ពាក្យសុំ[48] ការពិនិត្យទៅលើទម្រង់នៃពាក្យបណ្តឹងជាដើម។

**ក. ការពិនិត្យពន្ធដាក់ពាក្យសុំ**

ពន្ធដាក់ពាក្យសុំ គឺជាប្រាក់ពន្ធដែលភាគីដែលជាដើមចោទត្រូវបង់ទៅតុលាការដែលមានសមត្ថកិច្ចដើម្បីឱ្យតុលាការមានចំណាត់ការលើពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។ ចំពោះការបង់ពន្ធដាក់ពាក្យសុំក្នុងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីភាគីត្រូវបង់ចំនួន ១០០០០រៀល។[49]

ក្នុងករណីដែលដើមចោទមិនបានបង់ពន្ធ ឬបង់ពន្ធខ្វះតុលាការដែលទទួលពាក្យបណ្តឹងត្រូវបង្គាប់ឱ្យដើមចោទបង់ពន្ធ ឬបង់ពន្ធបន្ថែមដោយដីកាបង្គាប់ឱ្យបង់ពន្ធ។ ក្នុងករណីដែលដើមចោទពុំព្រមប្រតិបត្តិតាមទេ តុលាការត្រូវលើកចោលពាក្យបណ្តឹងរបស់ដើមចោទដោយដីកាសម្រេច។ ក្រៅពីពន្ធដាក់ពាក្យបណ្តឹងដើមចោទត្រូវបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធសម្រាប់ធ្វើការកោះហៅភាគីផងដែរ ក្នុងករណីដែលតុលាការបង្គាប់

[46] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧),២៨៨។

[47] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣០៩,កថាខណ្ឌទី៣។

[48] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៦១។

[49] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៦១,កថាខណ្ឌទី៤។

ឱ្យដើមចោទបង់ប្រាក់សម្រាប់ការកោះហៅភាគី តែដើមចោទពុំព្រមប្រតិបត្តិតាមតុលាការអាចលើកចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយដីកាសម្រេច ហើយមានការយល់ព្រមពីចុងចម្លើយ។[50]

### ខ. ការពិនិត្យទម្រង់ពាក្យបណ្ដឹង

ក្នុងករណីដែលតុលាការបានទទួលពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវពិនិត្យមើលពីភាពត្រឹមត្រូវនៃពាក្យបណ្ដឹង ដូចជាទម្រង់ និងចំណុចចាំបាច់ដែលត្រូវសរសេរជាដើម។

ការពិនិត្យ គឺជាការពិនិត្យអំពីភាពស្រប ឬមិនស្របនឹងលក្ខខណ្ឌទម្រង់តែប៉ុណ្ណោះ មិនពិចារណាអំពីផលប្រយោជន៍នៃបណ្ដឹង ឬលក្ខខណ្ឌបណ្ដឹង ឬការទាមទារមានមូលហេតុត្រឹមត្រូវតាមច្បាប់ឡើយ។ ប្រសិនបើពាក្យបណ្ដឹងមិនត្រឹមត្រូវទៅតាមទម្រង់ ដូចជាចំណុចចាំបាច់ដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង ឬពន្ធដាក់ពាក្យសុំមិនត្រូវបានបង់ ឬបង់ពន្ធមិនគ្រប់ចំនួនជាដើម តុលាការអាចបង្គាប់ឱ្យកែតម្រូវនូវចំណុចខ្វះខាតនោះ ដោយកំណត់អំឡុងពេលសមរម្យបាន តែប្រសិនបើដើមចោទមិនបានកែតម្រូវនូវចំណុចដែលមានការខ្វះខាតតាមការកំណត់របស់តុលាការនោះទេ តុលាការនឹងលើកចោលពាក្យបណ្ដឹងនោះដោយដីកាសម្រេច។ ហើយចំពោះដីកាសម្រេចនេះអាចប្ដឹងជំទាស់បាន។[51]

### គ. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង

ដើម្បីឱ្យពាក្យបណ្ដឹងមួយអាចទទួលយកបាន ហើយជៀសវាងការកែតម្រូវ លុះត្រាតែភាគីដើមចោទនៃបណ្ដឹងត្រូវសរសេរនូវពាក្យបណ្ដឹងនោះឱ្យបានត្រឹមត្រូវតាមច្បាប់។ ចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវសរសេរតាមអ្វីដែលមានកំណត់តាមចំណុចដែលមានចែងនៅក្នុងមាត្រា៣១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែកជាពីរចំណុចគឺ ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចាំបាច់ត្រូវសរសេរ (គ.១) និងឯកសារចម្លងនៃសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (គ.២)។

#### គ.១. ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចាំបាច់ត្រូវសរសេរ

ពោល គឺពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវសរសេរនូវចំណុចសំខាន់ៗមួយចំនួនដូចជា ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ សញ្ញាណនៃសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី សេចក្ដីទាមទារឱ្យជំនុំជម្រះសាជាថ្មី សេចក្ដីសម្រេចទាមទារចំពោះសាលក្រម ឬសាលដីកានោះ ហើយនិងសេចក្ដី

[50] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៨២,កថាខណ្ឌទី១។

[51] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣១៤។

ទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលភាគីនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទាមទារមានដូចជា ទាមទារឱ្យចាប់ផ្ដើមជំនុំជម្រះសាជាថ្មីចំពោះសំណុំរឿងរដ្ឋប្បវេណីដែលតុលាការបានចេញសាលក្រម ឬសាលដីកាជាស្ថាពររួច ទាមទារឱ្យតុលាការលុបចោលសាលក្រម ឬសាលដីការដ្ឋប្បវេណីរបស់សាលាដំបូង ឬសាលាឧទ្ធរណ៍ បង្គាប់ឱ្យចុងចម្លើយធ្វើការសង ឬប្រគល់មកឱ្យដើមចោទតាមអ្វីដែលដើមចោទទាមទារ និងចំណុចទាមទារបញ្ជាប់ គឺប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។ មួយវិញទៀត ក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវមានសរសេរនូវអង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី។[52]

ចំពោះអង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ជាការពន្យល់ស្ថានភាពណាមួយ ឬច្រើនដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី។[53]

### គ.២. ឯកសារភ្ជាប់នៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី

ឯកសារចម្លងនៃសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវភ្ជាប់ជាមួយនឹងពាក្យបណ្ដឹងទាមទារឱ្យជម្រះសាជាថ្មី។[54] យោងតាមមាត្រា៣១២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឯកសារដែលភាគីចាំបាច់ត្រូវភ្ជាប់មកជាមួយនឹងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ត្រូវយកទៅដាក់ពាក្យបណ្ដឹងនៅតុលាការមានសមត្ថកិច្ច គឺឯកសារចម្លងនៃសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីនេះ។ ក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ភាគីត្រូវតែសរសេរឱ្យបានច្បាស់លាស់អំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយភាគីដែលបានដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏អាចកែប្រែមូលហេតុ នៃការជំនុំជម្រះសាជាថ្មីបាន ក្រោយពីបានដាក់ពាក្យបណ្ដឹង រហូតដល់ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៃការជំនុំជម្រះសាជាថ្មីទៅតាមលំដាប់ថ្នាក់ និងរាប់បញ្ចូលការកែប្រែនៅដំណាក់កាលនៃការជំនុំជម្រះរបស់តុលាការជាន់ខ្ពស់ផងដែរ។[55] ការដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនត្រូវផ្អាកនូវអានុភាពនៃការអនុវត្តសាលក្រម ឬសាលដីកាស្ថាពរដោយស្វ័យប្រវត្តិឡើយ មានន័យថា អាចផ្អាក ឬលុបបានលុះត្រាតែភាគីបានដាក់ពាក្យសុំទៅតុលាការ ឱ្យតុលាការចេញដីកាសម្រេចបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈពេល ឬលុបចោលការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ។ ក្នុង

[52] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦,មាត្រា ៣១២,កថាខណ្ឌទី១។

[53] ឧទ្ទេសនាមដោយលោកមេធាវី អ៊ីវ ប៉ូលី ,សិក្ខាសាលា វិភាគទាន និងក្រុមមេធាវីសហប្រតិបត្តិការអន្តរជាតិ *ស្តីអំពីការជំនុំជម្រះសាជាថ្មី,* អនុស្សរណៈនៃការយោគយល់រវាងវិភាគទានច្បាប់ និងក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ(ថ្ងៃទី២៨ ខែមករា ឆ្នាំ២0២៤),៦២។

[54] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦,មាត្រា ៣១២,កថាខណ្ឌទី២។

[55] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦,មាត្រា ៣១៣។

ករណីដែលភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាតតិយជនផ្សេងក្រៅពីភាគីនៃសាលក្រម ឬសាលដីកាដើមចាំបាច់ត្រូវសរសេរឱ្យបានច្បាស់លាស់អំពីទំនាក់រវាងជននោះជាមួយនឹងភាគីនៃសាលក្រម ឬសាលដីកាដើមនោះ។ ដូចជាករណីសន្តតិជនរបស់ភាគីនៃសាលក្រម ឬសាលដីកាដើមជាអាទិ៍។

ក្រោយការពិនិត្យពាក្យបណ្តឹង បើតុលាការយល់ថា ពាក្យបណ្តឹងស្របតាមទម្រង់ ក្រឡាបញ្ជីនឹងបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ ហើយតុលាការនឹងប្រាប់ឱ្យដើមចោទថតចម្លងពាក្យបណ្តឹងទៅតាមចំនួនដែលត្រូវការ ដើម្បីបញ្ជូនទៅចុងចម្លើយ និងបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពន្ធសម្រាប់ជាសោហ៊ុយនៃការបញ្ជូនជាដើម។ បើដើមចោទមិនបង់សោហ៊ុយថ្លៃបញ្ជូនឯកសារ តុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យបណ្តឹង។ ទោះបីដើមចោទបានដាក់ពាក្យបណ្តឹងមកតុលាការក៏ដោយ ក៏ទំនាក់ទំនងគតិយុត្តនឹងកើតឡើងត្រឹមតែរវាងតុលាការ និងដើមចោទតែប៉ុណ្ណោះ រហូតដល់ពេលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅចុងចម្លើយ។ ការបញ្ជូនស្របច្បាប់ នាំឱ្យចុងចម្លើយក្លាយជាប្រធាននៃនីតិវិធីបណ្តឹង ហើយនឹងកើតទំនាក់ទំនងគតិយុត្តត្រីភាគី គឺមានតុលាការ ដើមចោទ និងចុងចម្លើយ។ ក្នុងន័យនេះពាក្យបណ្តឹងត្រូវបានសម្រេចបង្កើតអានុភាពពេញលេញនៅពេលដែលចុងចម្លើយបានទទួលនូវពាក្យបណ្តឹងរបស់ដើមចោទពីតុលាការ។

### ឃ. ការពិនិត្យពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

នៅពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនមកដល់ចៅក្រមដែលទទួលបន្ទុក ចៅក្រមត្រូវពិនិត្យទៅលើអំឡុងពេលដែលបានដាក់ពាក្យបណ្តឹង និងលក្ខខណ្ឌផ្សេងៗទៀត។

តុលាការដែលទទួលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវពិនិត្យអំពីភាគីនៃពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ថាតើកំណត់ត្រឹមត្រូវដែរ ឬទេ? ដូចដែលបានរៀបរាប់ខាងលើ ថាភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាដើមចោទ ចុងចម្លើយ ឬអាចជាតតិយជន។ ដូចនេះ ភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ ហើយត្រូវសរសេរឱ្យបានគ្រប់ជ្រុងជ្រោយគ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ និងអ្នកតំណាងស្របច្បាប់ផងដែរ។ ដើមចោទនៃពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាភាគីដែលមានផលប្រយោជន៍ក្នុងការទាមទារឱ្យលុបចោលនូវសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះជាថ្មី ឬតតិយជនដែលទទួលរងអានុភាពនៃសាលក្រម ឬសាលដីកាស្ថាពរ។ ចុងចម្លើយនៃពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាភាគីដែលមានផលប្រយោជន៍ក្នុងការទាមទារឱ្យលុបចោលនូវសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី។

តុលាការត្រូវពិនិត្យទៅលើអំឡុងពេលនៃការដាក់ពាក្យបណ្តឹង ក្នុងករណីដែលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនបានដាក់ក្នុងអំឡុងពេលដែលច្បាប់បានកំណត់ ចាត់ទុកថាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

មានភាពផ្ទុយច្បាប់។ តុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងចេញដីកាសម្រេចលើកចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបើបណ្ដឹងមានភាពផ្ទុយនឹងច្បាប់។ ពាក្យបណ្ដឹងមានភាពផ្ទុយច្បាប់សំដៅលើដើមចោទ មិនមែនជាបុគ្គលដែលមានសិទ្ធិប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ឬអំឡុងពេលនៃការដាក់ពាក្យបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មីបានកន្លងផុត ឬការប្ដឹងមិនមែនជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាដើម។ ភាគីដាក់ពាក្យបណ្ដឹងឱ្យជំនុំជម្រះសាជាថ្មី គឺដើម្បីកែប្រែនូវអានុភាពនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ ប្រសិនបើច្បាប់អនុញ្ញាតឱ្យដាក់ពាក្យបណ្ដឹងពេលណាក៏បាន វាគឺជាការរារាំងដល់ស្ថិរភាពនៃទំនាក់ទំនងរវាងភាគី។ ហេតុនេះ បណ្ដឹងទាមទារឱ្យជម្រះសាជាថ្មី ត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជម្រះសាជាថ្មី ក្រោយពេលសាលក្រម ឬសាលដីកាបានចូលជាស្ថាពររួច ហើយចំពោះអំឡុងពេលនេះមិនអាចពន្យាបានទេ។[56] មួយវិញទៀត ចំពោះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដែលដាក់ក្រោយអំឡុងពេលនេះកន្លងផុតទៅ គឺខុសច្បាប់ ប៉ុន្តែទោះបីជាមានការកម្រិតទៅលើអំឡុងពេល ៣០ថ្ងៃ នេះក៏ដោយ ហើយទោះជាផុតរយៈពេល ៣០ថ្ងៃ នេះក៏ដោយ ក៏ភាគីអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានក្នុងរយៈពេល ៥ឆ្នាំគិតពីថ្ងៃដែលសាលក្រម ឬសាលដីកាបានចូលជាស្ថាពរ ឬគិតចាប់ពីថ្ងៃដែលមូលហេតុនៃការជម្រះសាជាថ្មីបានកើតឡើង។ តែអាចអនុវត្តបានក្នុងករណីដែលមូលហេតុនោះកើតឡើងក្រោយសាលក្រម ឬសាលដីកាចូលជាស្ថាពរប៉ុណ្ណោះ។ មានន័យថា ទោះបីជាមូលហេតុនោះបានកើតឡើងក្រោយពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរក៏ដោយ បើផុតរយៈពេល ៥ឆ្នាំនេះទៀត នោះភាគីលែងអាចប្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទៀតឡើយ។[57] ឧបមាថា ដើមចោទលោក ក បានប្ដឹងចុងចម្លើយលោក ខ ទាមទារឱ្យប្រគល់ដីដោយផ្អែកលើកម្មសិទ្ធិ តុលាការបានចេញសាលក្រមតាមការទាមទាររបស់ដើមចោទ ហើយសាលក្រមបានចូលជាស្ថាពរនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៧។ ហើយនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤លោក ខ បានដឹងពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ ក្នុងករណីនេះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនអាចធ្វើបានឡើយ ពីព្រោះអំឡុងរយៈពេល ៥ឆ្នាំបានកន្លងផុតទៅហើយ។ ចំពោះការលើកឡើងអំពីការបានដឹង ឬមិនបានដឹង គឺជាអង្គហេតុតវ៉ាដែលត្រូវអះអាងដោយចុងចម្លើយនៃបណ្ដឹងទាមទារ មិនមែនជាការទទួលខុសត្រូវរបស់ដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះទេ។[58]

ប៉ុន្តែ ការកំណត់ខាងលើ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីនៃបណ្ដឹងទាមទារឱ្យជម្រះសាជាថ្មី

[56] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦,មាត្រា ៣១១,កថាខណ្ឌទី១ និង២។

[57] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦,មាត្រា ៣១១,កថាខណ្ឌទី៣។

[58] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama (បញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី),២៥។

ដែលយកមូលហេតុដូចបានកំណត់នៅក្នុងចំណុច គ (បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដែលច្បាប់បានកំណត់ ខ្វះការប្រគល់សិទ្ធិ ចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬខ្វះសិទ្ធិតំណាងដោយអាណត្តិ) ឬចំណុច ញ (សាលក្រម ឬសាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬសាលដីកាមុនដែលបានចូលជាស្ថាពរហើយ) កថាខណ្ឌទី១ នៃមាត្រា៣០៧។ ក្នុងករណីដែលមានការខ្វះសិទ្ធិតំណាង ដោយសារថាបណ្តឹងដែលមានសាលក្រម ឬសាលដីកានោះបានធ្វើឡើង ក្នុងករណីដែលអ្នកតំណាង និងសាមីភាគីមិនបានដឹងសោះអំពីមូលហេតុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ  ហើយសាលក្រម ឬសាលដីកាបានចេញដោយមិនធានានូវសិទ្ធិជាមូលដ្ឋាននៃនីតិវិធីចំពោះភាគី ហេតុដូចនេះ ការកម្រិតនូវរយៈពេល ៣០ថ្ងៃនេះ គឺមានភាពមិនសមរម្យ និងអយុត្តិធម៌ជាខ្លាំង ដោយហេតុថាបណ្តឹងដែលមានសាលក្រម ឬសាលដីកាស្ថាពរនោះ ត្រូវបានធ្វើឡើងនៅពេលដែលសាមីភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់មិនបានដឹងសោះ បែរជាតុលាការបានចេញសាលក្រម ឬសាលដីកាដោយមិនធានានូវសិទ្ធិជាមូលដ្ឋាននៃនីតិវិធីចំពោះភាគី ដូច្នេះការកម្រិតនូវអំឡុងពេលសម្រាប់បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺវាផ្ទុយទៅនឹងយុត្តិធម៌។ ម្យ៉ាងទៀត ចំពោះមូលហេតុសាលក្រម ឬសាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬសាលដីកាមុនដែលបានចូលជាស្ថាពរហើយ និងមូលហេតុខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬអ្នកតំណាងដែលច្បាប់បានកំណត់ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬខ្វះសិទ្ធិតំណាងដោយអាណត្តិ ភាគីអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយនៅពេលណាក៏បានដែលមិនចាំបាច់គោរពអំឡុងពេលដែលបានកំណត់ខាងលើនេះទេ។[59] ក្នុងករណីដែលសាលក្រម ឬសាលដីកាចេញមុន និងក្រោយមានការប៉ះពាល់គ្នាបើមានការកម្រិតអំឡុងពេល នោះវានឹងធ្វើឱ្យមានភាពច្របូកច្របល់ ដោយហេតុថា គ្មានភាពច្បាស់លាស់ក្នុងការកំណត់ទំនាក់ទំនងគតិយុត្តរវាងភាគីថា សាលក្រម ឬសាលដីកាណាមួយឱ្យប្រាកដទេ។

ចំពោះការពិនិត្យពាក្យបណ្តឹងវិញ ប្រសិនបើតុលាការរកឃើញថាពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានភាពផ្ទុយពីច្បាប់ ដូចជាពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះពុំគោរពទៅនឹងអំឡុងពេលនៃការជំនុំជម្រះសាជាថ្មីទេ តុលាការត្រូវលើកបណ្តឹងនោះចោលដោយដីកាសម្រេច[60] ដើម្បីកុំឱ្យមានភាពយឺតយ៉ាវដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ។ ដីកាសម្រេចលើកចោលនៃបណ្តឹង

[59] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣១១,កថាខណ្ឌទី១ និងទី៣។

[60] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា៣១៤,កថាខណ្ឌទី១។

ទាមទារឱ្យជំនុំជម្រះសាជាថ្មី ភាគីដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីអាចប្តឹងជំទាស់បាន។[61] លើសពីនេះ បើក្នុងករណីដែលតុលាការនៃបណ្តឹងជំទាស់បានរកឃើញថាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះត្រឹមត្រូវតាមច្បាប់ហើយ តុលាការនៃបណ្តឹងជំទាស់ត្រូវចេញដីកាសម្រេចមួយលុបចោលដីកាសម្រេចដើម ហើយចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី។ ប្រសិនបើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះមានភាពស្របច្បាប់ ហើយបន្ទាប់មកតុលាការត្រូវធ្វើការពិនិត្យអំពីអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលភាគីបានធ្វើការអះអាងនោះ។ ប៉ុន្តែក្នុងករណីដែលតុលាការកំពូលបានចេញដីកាសម្រេចលើកចោលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលនេះបានទេ ពីព្រោះប្តឹងជំទាស់ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ប៉ុន្តែតុលាការកំពូលគឺជាតុលាការជាន់ខ្ពស់ជាងគេ។ ដូចច្នេះ គ្មានតុលាការណាដែលមានសមត្ថកិច្ចខ្ពស់ជាងតុលាការកំពូលទៀតនោះឡើយ ក្នុងករណីនេះតុលាការកំពូលត្រូវលើកបណ្តឹងជំទាស់ចោល។

## ១.៤. អានុភាពនៃការទាមទារជំនុំជម្រះសាជាថ្មី

នៅពេលដែលមានពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ដើម្បីការពារផលប្រយោជន៍របស់ភាគីនៅក្នុងសំណុំរឿង តុលាការត្រូវចាត់ចែងផ្អាកការអនុវត្តដោយបង្ខំ បើភាគីបានដាក់ពាក្យសុំ។ ប្រសិនជាការដាក់ពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី មិនបានផ្អាកការអនុវត្តដោយបង្ខំទេច្បាស់ជាពិបាកក្នុងការស្តារស្ថានភាពណាស់ ប្រសិនជាដើមបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី បែរទៅជាឈ្នះក្តីក្នុងសំណុំរឿងនេះទៅវិញ។

### ១.៤.១. ការផ្អាកការអនុវត្តដោយបង្ខំដោយការជំនុំជម្រះសាជាថ្មី

ជាទូទៅនៅពេលដែលសេចក្តីសម្រេចដើមចូលជាស្ថាពរ ភាគីដែលបានឈ្នះក្តីទាំងស្រុង ឬមួយផ្នែកធ្វើការយកសេចក្តីសម្រេចដែលជាលិខិតអនុវត្ត ទៅធ្វើការអនុវត្តដោយបង្ខំលើកូនបំណុលដែលបានចាញ់ក្តីដើម្បីសម្រេចសិទ្ធិទាមទាររបស់ខ្លួន។ ហេតុនេះប្រសិនជាកូនបំណុលបានឃើញថា សេចក្តីសម្រេចនោះមានវិការៈ ហើយបានដាក់ពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ទៅលើសេចក្តីសម្រេចដើម នោះខ្លួនអាចដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំបាន។

ការផ្អាកការអនុវត្តដោយបង្ខំ ដោយសារបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏អាចទទួលស្គាល់បានដែរ តែក្នុងករណីពិសេសតែប៉ុណ្ណោះ គឺមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយមានសេចក្តីបញ្ជាក់ដំបូងអំពីហេតុការណ៍ពិតទៅលើមូលហេតុនោះ។ ប្រសិនសេចក្តីសម្រេចនៃការជំនុំជម្រះលើកទី១ ដែលបានចូលជាស្ថាពរមានភ្ជាប់ជាមួយការអនុវត្តដោយបង្ខំ ភាគីដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីអាចដាក់ពាក្យសុំ

[61] ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា ៣១៤,កថាខណ្ឌទី៤។

ឱ្យតុលាការផ្អាកការអនុវត្តដោយបង្ខំមួយរយៈសិនបានដោយដាក់ប្រាតិភោគ ឬមិនដាក់ប្រាតិភោគ។[62] ដែលនេះ គឺជារបបផ្អាកការអនុវត្តមួយរយៈពេល ក្នុងករណីដែលមានការដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី រហូតដល់ពេលបានទទួលលទ្ធផលនៃការដាក់ពាក្យបណ្ដឹងនោះ។ តែទោះជាយ៉ាងណាក៏ដោយ ការសុំផ្អាកការអនុវត្តដោយបង្ខំនោះមិនមានលក្ខណៈងាយស្រួលនោះទេ គឺត្រូវមានលក្ខខណ្ឌតឹងរ៉ឹងណាស់។

ការដាក់ពាក្យសុំផ្អាកការអនុវត្តដោយបង្ខំ នេះត្រូវគោរពទៅតាមលក្ខខណ្ឌដូចជា៖

**ក. ស្ថានភាពដែលត្រូវបានអះអាងថាហាក់ដូចជាមានមូលហេតុតាមផ្លូវច្បាប់**

ការអះអាងរបស់ដើមបណ្ដឹងនៃការជំនុំជម្រះសាជាថ្មី ហាក់ដូចជាមានមូលហេតុណាមួយដូចដែលមានចែងក្នុងចំណុចណាមួយនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី ពីចំណុច ក ដល់ចំណុច ញ នៃមាត្រា៣០៧។ តែប្រសិនជាអង្គហេតុដែលអះអាងដោយដើមបណ្ដឹងនៃការជំនុំជម្រះសាជាថ្មី មិនត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ គឺមិនស្របនឹងលក្ខខណ្ឌបណ្ដឹងឡើយ។ ឧបមាថា មានការរកឃើញភស្តុតាងថ្មីមួយចំពោះសំណុំរឿងដែលចូលជាស្ថាពរហើយ។ ការរកឃើញភស្តុតាងថ្មីមិនមែនជាមូលហេតុនៃការជំនុំជម្រះសាជាថ្មីនោះទេ។ តែចំពោះការផ្ដល់សក្ខីកម្មមិនត្រឹមត្រូវ បើសិនជាមានសាលក្រម ឬសាលដីកាស្ថាពរដែលទទួលស្គាល់ថាសក្ខីកម្មនោះមិនត្រឹមត្រូវទេ នោះអាចជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី។[63]

**ខ. សេចក្ដីបញ្ជាក់ដំបូងអំពីហេតុការណ៍**

មូលហេតុនៃការជំនុំជម្រះសាជាថ្មី ដែលដើមចោទធ្វើសេចក្ដីអះអាងដើម្បីទាមទារឱ្យជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវធ្វើសេចក្ដីបញ្ជាក់ដំបូង។ សេចក្ដីបញ្ជាក់ដំបូង គឺជារបៀបនៃការទទួលស្គាល់អង្គហេតុ ទោះបីជាសេចក្ដីបញ្ជាក់ដំបូងមានកម្រិតទាបជាងការបញ្ជាក់តឹកតាងក៏ដោយ។ សេចក្ដីបញ្ជាក់ដំបូងត្រូវធ្វើឡើងដោយភស្តុតាងដែលអាចពិនិត្យបានភ្លាម។[64] បន្ទាប់ពីទទួលបានសេចក្ដីបញ្ជាក់ដំបូងថាស្របនឹងលក្ខខណ្ឌទើបអាចទទួលស្គាល់នូវការផ្អាកការអនុវត្តបាន ជារួមទាល់តែស្របទៅនឹងលក្ខខណ្ឌទាំងពីរ នោះទើបអាចទទួលស្គាល់នូវការផ្អាកការអនុវត្តដោយបង្ខំបាន។ ករណីដែលតុលាការដែលបានទទួលពាក្យសុំឱ្យផ្អាកការអនុវត្តបែបនេះមិនអាចបង្គាប់ឱ្យផ្អាកការអនុវត្តទេ គឺត្រូវលើកចោល។ ចំពោះដីកាសម្រេចអំពីការផ្អាកការអនុវត្ត ឬដីកា

[62] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៦៦ កថាខណ្ឌទី១។

[63] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama (បញ្ហានានាដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី),៨១។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៣១។

សម្រេចលើកចោលនូវពាក្យសុំនោះ មិនអាចប្ដឹងឧបាស្រ័យបានទេ។ ដោយបណ្ដឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែមានក្នុងបញ្ញត្តិច្បាប់។[65]

### ១.៤.២. ការដកពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

ការដកពាក្យបណ្ដឹង គឺជាសកម្មភាពដកមួយភាគ ឬទាំងស្រុងនូវពាក្យសុំទាមទារឱ្យចេញសាលក្រម តាមរយៈបណ្ដឹង ដោយដើមចោទ។[66] ចំពោះការដកពាក្យបណ្ដឹង ត្រូវធ្វើឡើងជាលាយល័ក្ខអក្សរ ប៉ុន្តែលើកលែង នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការផ្សះផ្សា ការដកពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាន។[67] ក្នុងករណីដែល ដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានបំណងចង់ដកពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នោះភាគីអាចដកនៅពេលណាក៏បាន រហូតដល់ពេលសាលក្រម ឬសាលដីកាចុងក្រោយរបស់តុលាការនៃ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានប្រកាស។

ការដកបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាការដកចេញនូវឧបាស្រ័យពិសេសចំពោះសេចក្ដី សម្រេចដើមដែលបានចូលជាស្ថាពរ (កម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី) ហើយអានុភាពនៃការដកបណ្ដឹងទាមទារ ជំនុំជម្រះសាជាថ្មី នាំឱ្យនីតិវិធីនៃការជំនុំជម្រះសាជាថ្មីត្រូវបានបញ្ចប់ និងចាត់ទុកថាគ្មានបណ្ដឹងទាមទារឱ្យ ជំនុំជម្រះសាជាថ្មីតាំងពីដើម ហើយសេចក្ដីសម្រេចដើមដែលបានចូលជាស្ថាពរនៅតែបន្តអានុភាពអនុវត្ត ដដែល។ ចំពោះការដកបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះ សាជាជាថ្មី មិនចាំបាច់មានការយល់ព្រមពីចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទេ ព្រោះថា ចុងចម្លើយមិនត្រូវបានទទួលស្គាល់ថាខូចប្រយោជន៍ ដោយសារការដកពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះ សាជាថ្មីនោះឡើយ។[68]

---

[65] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី២។

[66] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា,*នីតិវិធីបណ្ដឹង* (ភាគ១ នៃសេចក្ដីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី,២០០៨),១៥៨។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២១៧ កថាខណ្ឌទី៣។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១០។

# ជំពូកទី២

## នីតិវិធីនៃការវិនិច្ឆ័យ និងការសម្រេចសេចក្តី

# ជំពូកទី២
# នីតិវិធីនៃការវិនិច្ឆ័យ និងការសម្រេចសេចក្ដី

បណ្ដឹងទាមទារជំនុំជម្រះសាជាថ្មីគឺ ជាបណ្ដឹងដែលមានពាក្យសុំពីរ ដោយរួមមានពាក្យសុំលុបចោលនូវសាលក្រម ឬសាលដីកាដើមដែលបានចូលជាស្ថាពរ និងពាក្យសុំទាមទារឱ្យចេញសាលក្រម ឬសាដីកាថ្មីជំនួសសាលក្រម ឬសាលដីកាដើមដែលមានវិការៈ។ ហេតុដូចនេះ តុលាការត្រូវវិនិច្ឆ័យទៅលើទៅលើបណ្ដឹងរួចហើយតុលាការនឹងធ្វើការ(២.១) ការវិនិច្ឆ័យអំពីអង្គសេចក្ដី(២.២) ក្រោយមកតុលាការនឹងធ្វើការសម្រេចសេចក្ដីទៅលើអង្គសេចក្ដី(២.៣)។

## ២.១. នីតិវិធីនៃការវិនិច្ឆ័យលើបណ្ដឹង

### ២.១.១. ភាពបង្គ្រប់នៃបណ្ដឹងទាមទារជម្រះសាជាថ្មី

ទោះបីមានអង្គហេតុដែលត្រូវនឹងមូលហេតុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីក៏ដោយ ក៏ការទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មីមិនអាចធ្វើទៅបានដែរ ប្រសិនបើមានករណីមួយចំនួនកើតឡើងដូចជា ករណីដែលភាគីបានធ្វើការអះអាងអំពីអង្គហេតុនោះ នៅពេលធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មុនពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរតែត្រូវច្រានចោល ឬក៏ករណីដែលភាគីបានដឹងអំពីមូលហេតុនេះហើយតែមិនបានធ្វើការអះអាងតាមបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។[69]

លក្ខខណ្ឌខាងលើនេះហៅថា ភាពបង្គ្រប់នៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលមានប្រសិទ្ធភាពនៃគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់។ ដូចនេះ ជាបឋមភាគីត្រូវអះអាងអំពីអង្គហេតុដែលត្រូវនឹងមូលហេតុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីតាមរយៈពាក្យបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលមានន័យថា មានតែករណីដែលមិនអាចធ្វើការអះអាងបាននៅក្នុងបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដោយសារខ្លួនមិនបានដឹងពីហេតុនោះ ឬដោយសារមូលហេតុនោះកើតឡើងនៅពេលក្រោយប៉ុណ្ណោះ ទើបភាគីអាចយកមកធ្វើការអះអាងនៅក្នុងបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។[70] ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងយល់បន្ថែមឱ្យកាន់តែច្បាស់ អ្នកស្រាវជ្រាវសូមធ្វើការបែងចែកជាពីរចំណុច ហើយនឹងពន្យល់លម្អិតអំពី

[69] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

[70] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧),២៨៤។

បញ្ហានេះ ការបានធ្វើការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី (២.១.១.១) និងការមិនបានធ្វើការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី (២.១.១.២)។

### ២.១.១.១. ការបានធ្វើការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ក្នុងករណីភាគីដែលបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយបានធ្វើការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី នៅពេលដែលភាគីបានធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលមានបញ្ញត្តិក្នុងមាត្រា៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ មានន័យថា នៅក្នុងករណីដែលភាគីបានដឹងអំពីមូលហេតុណាមួយ ដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី និងបានលើកយកមូលហេតុនោះមកធ្វើការអះអាងនៅពេលដែលខ្លួន ឬភាគីម្ខាងទៀតបានធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។ ដូចនេះភាគីមិនអាចយកមូលហេតុដដែលនោះ មកធ្វើជាមូលដ្ឋានក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅលើសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពររួចហើយនោះទេ ដោយហេតុថាភាគីបានលើកយកបញ្ហានោះមកឱ្យតុលាការជាន់ខ្ពស់ធ្វើការវិនិច្ឆ័យលើមូលហេតុនោះរួចរាល់ហើយ។

ដូច្នេះការលើកយកបញ្ហាដដែលនេះមកឱ្យតុលាការធ្វើការជំនុំជម្រះម្ដងទៀត គឺជាការមិនសមរម្យឡើយ ហើយច្បាប់ក៏មិនបើកសិទ្ធិឱ្យតុលាការលើកយកមូលហេតុដដែលមកធ្វើការវិនិច្ឆ័យដែរ។ ប្រសិនជាតុលាការបានអនុញ្ញាតបើកសិទ្ធិឱ្យភាគីដែលបានអះអាងអំពីអង្គហេតុនោះ នៅក្នុងបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហើយដែលត្រូវបានត្រូវតុលាការច្រានចោលម្ដងរួចហើយនោះ គឺវាគ្មានផលប្រយោជន៍អ្វីនោះទេ ហើយថែមទាំងនឹងធ្វើឱ្យខាតបង់ពេលវេលាបន្ថែមទៀតផង។

### ២.១.១.២. ការមិនបានធ្វើការអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី

#### ក. ការមិនបានធ្វើការអះអាងនៅក្នុងដំណើរការនីតិវិធី

នៅក្នុងដំណើរការនីតិវិធីនៃដំណាក់កាលណាមួយរបស់តុលាការដូចជា នៅនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ឬក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់។ បើសិនភាគីបានដឹងអំពីអង្គហេតុណាមួយដែលអាចក្លាយជាមូលហេតុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ប៉ុន្តែខ្លួនពុំបានធ្វើការអះអាងភ្លាមៗអំពីមូលហេតុនោះឡើយ ដោយរងចាំរហូតដល់ពេលសាលក្រម ឬសាលដីកាចូលជាស្ថាពរដើម្បីយកមកធ្វើជាមូលហេតុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ នោះបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មីមិនអាចត្រូវបានទទួលយកឡើយ ដោយមូលហេតុថាភាគីមិនបានគោរពតាមភាពបង្គ្រប់នៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។[71]

[71] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៧, កថាខណ្ឌទី១ វាក្យខណ្ឌទី២។

ក្នុងករណីនេះ ប្រសិនជាតុលាការបានអនុញ្ញាតបើកសិទ្ធិឱ្យភាគីដែលមិនបានអះអាងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី នៅក្នុងដំណើការនីតិវិធី និងអនុញ្ញាតឱ្យប្តឹងទាមទារជំនុំជម្រះសាជាថ្មី វាមើលទៅហាក់បីដូចជាការផ្តល់សិទ្ធិឱ្យដើមបណ្តឹងច្រើនហួសហេតុពេក និងនាំឱ្យខាតបង់ផលប្រយោជន៍របស់ភាគីចុងចម្លើយនៃបណ្តឹងទាមទារជំនុជម្រះសាជាថ្មី។

### ខ. ការមិនបានធ្វើការអះអាង នៅក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់

ចំពោះករណីដែលភាគីណាមួយ បានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយដែលគួរលើកឡើងនៅក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ប៉ុន្តែខ្លួនពុំបានធ្វើបណ្តឹងឧប្រាស្រ័យទៅតុលាការជាន់ខ្ពស់ដោយទុកឱកាសធ្វើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី នោះក៏ជាការបំពានលើភាពបំពេញបន្ថែមនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីផងដែរ។ ដូចនេះចំពោះមូលហេតុដែលកើតឡើង ហើយដែលភាគីអាចយកទៅអះអាងក្នុងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តែខ្លួនបែរជាមិនព្រមអះអាងដោយទុកសេចក្តីសម្រេចឱ្យចូលជាស្ថាពរ នោះមិនអាចយកហេតុខាងដើមមកធ្វើការលើកឡើងមកធ្វើជាមូលហេតុនៃការទាមទារជំនុំជម្រះសាជាថ្មីឡើយ។[72]

### ២.១.២. សេចក្តីសម្រេចទទួលស្គាល់ ឬមិនទទួលស្គាល់ការទាមទារ

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជានីតិវិធីបណ្តឹងមួយ ដែលតុលាការត្រូវធ្វើការពិនិត្យពិច័្ចយឱ្យបានច្បាស់លាស់ទៅលើមូលហេតុនៃការជំនុំជម្រះសាជាថ្មី ព្រោះវាជាការប្រឆាំងទាមទារឱ្យលុបចោល ឬកែប្រែសាលក្រម ឬសាលដីកាដែលចូលជាស្ថាពរ ដែលមិនអាចទទួលយកបានដោយងាយៗនោះទេ។ ដើម្បីធ្វើការវិនិច្ឆ័យទៅលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តុលាកាត្រូវធ្វើការពិនិត្យ និងវិនិច្ឆ័យពីរដំណាក់កាលគឺដំណាក់កាលនៃការវិនិច្ឆ័យអំពីការអនុញ្ញាត ឬមិនអនុញ្ញាតឱ្យជំនុំម្រះសាជាថ្មីតាមរយៈការចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី បន្ទាប់មកត្រូវវិនិច្ឆ័យ និងចេញសាលក្រម ឬសាលដីកាដែលពាក់ព័ន្ធទៅនឹងការទាមទារដើមក្នុងករណីដែលអនុញ្ញាតឱ្យជំនុំជម្រះសាជាថ្មីជាដំណាក់កាលទីពីរ។

ជាដំបូងយើងនឹងធ្វើការសិក្សាបន្ថែមទៅលើការ វិនិច្ឆ័យទៅលើដំណាក់កាលទីមួយរបស់តុលាការដែលតុលាការនឹងធ្វើការវិនិច្ឆ័យ ទៅលើមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដោយក្នុងចំណុចនេះតុលាការមានឆន្ទានុសិទ្ធិត្រូវសម្រេចថា មិនទទួលស្គាល់ការទាមទារ(២.១.២.១) ឬក៏ទទួលស្គាល់ការទាមទារ(២.១.២.២) របស់ដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។

[72] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២។

### ២.១.២.១. ការមិនទទួលស្គាល់ការទាមទារ

ការសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យធ្វើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ត្រូវផ្អែកលើមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ ដូចច្នេះនៅពេលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានដាក់ទៅតុលាការជាបឋម គឺតុលាការត្រូវពិនិត្យអំពីនិយ័តភាពនៃពាក្យបណ្តឹងដោយតុលាការត្រូវធ្វើការវិនិច្ឆ័យទៅលើមូលហេតុដែលដើមចោទបានសរសេរក្នុងពាក្យបណ្តឹង និងធ្វើការសម្រេចថាមាន ឬគ្មានមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំង១០ (ដប់)នៃការជំនុំជម្រះសាជាថ្មីដែលបានបញ្ញត្តិក្នុងមាត្រា៣០៧ កថាខណ្ឌទី១ ឬមូលហេតុពិសេសដូចមានកំណត់ក្នុងមាត្រា៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ពាក្យថាគ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី សំដៅលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមិនបានពន្យល់អំពីអង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ស្របតាមលក្ខខណ្ឌច្បាប់ ឬគ្មានភស្តុតាងគាំទ្រអង្គហេតុឡើយ។

នៅក្នុងដំណាក់កាលវិនិច្ឆ័យទៅលើមូលហេតុនៃការជំនុំជម្រះសាជាថ្មី ការទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងដំណាក់កាលនេះមិនតម្រូវនោះទេ ព្រោះការជំនុំជម្រះអំពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីនៃការចេញដីកាសម្រេច ដែលដូចគ្នាទៅនឹងដំណាក់កាលនៃការនៃនីតិវិធីជំនុំជម្រះពីភាពស្របច្បាប់នៃបណ្តឹងដែរ។ ក្នុងករណីដែលតុលាការយល់ឃើញថា ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ពុំមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ នោះតុលាការត្រូវចេញដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី។[73] ចំពោះដីកាសម្រេចច្រានចោលបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីអាចប្តឹងជំទាស់បានក្នុងអំឡុងពេល ១សប្តាហ៍គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេចច្រានចោល ដោយអំឡុងពេលនេះមិនអាចពន្យារបានឡើយ។[74] នៅដំណាក់កាលនៃបណ្តឹងជំទាស់ តុលាការនៃបណ្តឹងជំទាស់វិនិច្ឆ័យទៅលើមូលហេតុនៃការជំនុំជម្រះសាជាថ្មី នៅពេលដែលដីកាសម្រេចនៃបណ្តឹងជំទាស់បានចូលជាស្ថាពរ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀត ដោយយកមូលហេតុដូចគ្នាបានឡើយ។

ក្នុងករណីនេះតុលាការនៃបណ្តឹងជំទាស់ត្រូវសម្រេច ហើយប្រសិនជាតុលាការនៃបណ្តឹងជំទាស់រកឃើញថាបណ្តឹងនោះមានភាពស្របច្បាប់ ហើយមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីតាមមាត្រា៣០៧ កថាខណ្ឌទី១ នោះតុលាការនៃបណ្តឹងជំទាស់ត្រូវចេញដីកាសម្រេចមួយលុបចោលដីកាសម្រេចដើម និងចាប់ផ្តើមជំនុំជម្រះសាជាថ្មី។ តែប្រសិនបើតុលាការនៃបណ្តឹងជំទាស់រកឃើញថា ដីកាសម្រេចដើមមានភាពត្រឹមត្រូវ

[73] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១ កថាខណ្ឌទី២។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៣០៣។

ហើយនោះតុលាការនៃបណ្តឹងជំទាស់ត្រូវចេញសេចក្តីសម្រេចច្រានចោលបណ្តឹងជំទាស់នោះ។[75] ចំពោះដីកាសម្រេចអំពីបណ្តឹងជំទាស់ភាគីមិនអាចដាក់ពាក្យបណ្តឹងជំទាស់ម្តងទៀតបានឡើយ។[76]

### ២.១.២.២. ការទទួលស្គាល់ការទាមទារ

បន្ទាប់ពីតុលាការធ្វើការពិនិត្យលើពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីរួចមក ក្នុងករណីតុលាការរកឃើញថាការទាមទារមានអត្ថិភាពនៃមូលហេតុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី តែតុលាការត្រូវសួរភាគីម្ខាងទៀត ដែលជាចុងចម្លើយនៃការជំនុំជម្រះសាជាថ្មីជាមុនសិន។[77] ការសួរចុងចម្លើយនៃការទាមទារជំនុំជម្រះសាជាថ្មីជាមុន គឺជាលក្ខខណ្ឌដែលត្រូវបំពេញមុននឹងតុលាការចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី ដែលមានភាពផ្ទុយពីការចេញដីកាសម្រេចលើកចោល និងដីកាសម្រេចច្រានចោល ដែលមិនចំណុះឱ្យលក្ខខណ្ឌនៃការសួរចុងចម្លើយនៃការជំនុំជម្រះសាជាថ្មីនោះឡើយ។ ប្រសិនបើតុលាការចេញដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មី ដោយមិនធ្វើការសួរភាគីម្ខាងទៀតទេនោះ គឺជាការដឹកនាំនីតិវិធីមួយដែលខុសច្បាប់។ ហេតុនេះ បុគ្គលដែលខូចប្រយោជន៍អាចតវ៉ាចំពោះការដឹកនាំនីតិវិធី ឬបើមានការខូចខាតកើតឡើង អាចប្តឹងទាមទារសំណងផ្អែកលើអំពើអនីត្យានុកូល។ មូលហេតុនៃការកំណត់លក្ខខណ្ឌបែបនេះ ដោយហេតុថាដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី អាចនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលចុងចម្លើយគប្បីដឹងអំពីអត្ថិភាពនៃការចាប់ផ្តើមនីតិវិធី ដើម្បីឱ្យខ្លួនមានឱកាសត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការចូលរួមនីតិវិធីនៃអង្គសេចក្តីជាដើម។ ម្យ៉ាងទៀត ដោយសារតែដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី គឺជាការវិនិច្ឆ័យដំបូងដែលអាចនាំឱ្យលុបចោលនូវសាលក្រម ឬសាលដីកាស្ថាពរដើមដែលតុលាការចាំបាច់ត្រូវសួរភាគីម្ខាងទៀត។

ការសួរចុងចម្លើយនៃការទាមទារជំនុំជម្រះសាជាថ្មី មិនមែនជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដោយតុលាការអាចធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរបាន។[78]

មួយវិញទៀត ចំពោះដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មីនេះ ភាគីម្ខាងទៀតដែលជាចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏អាចប្តឹងជំទាស់បានដែរ។[79] ក៏ប៉ុន្តែប្រសិនបើមានការប្តឹង

[75] ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ វគ្គបណ្តុះបណ្តាលបន្តសម្រាប់ចៅក្រម និងក្រឡាបញ្ជី រាជធានី-ខេត្ត *ស្តីពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី* (ខែវិច្ឆិកា ឆ្នាំ២០០៦ ដល់ខែកុម្ភៈ ឆ្នាំ២០០៧),៦៨។

[76] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៩ កថាខណ្ឌទី៣។

[77] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៥ កថាខណ្ឌទី១ និងទី២។

[78] Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama (បញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី),៣៧។

[79] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៥ កថាខណ្ឌទី៣។

ជំទាស់ ចំពោះដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី ហើយតុលាការនៃបណ្តឹងជំទាស់ រកមិនឃើញនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មី ស្របតាមបញ្ញត្តិមាត្រា៣០៧ កថាខណ្ឌទី១ ទេ នោះតុលាការនៃបណ្តឹងជំទាស់ត្រូវចេញដីកាសម្រេចមួយលុបចោលដីកាសម្រេចដើម (ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី) ហើយច្រានចោលការទាមទារឱ្យជំនុំជំជម្រះសាជាថ្មី របស់ដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីលើរឿងក្តី។ ផ្ទុយទៅវិញប្រសិនបើតុលាការនៃបណ្តឹងជំទាស់រកឃើញថាដីកាសម្រេចដើម(ដីកាសម្រេចច្រានចោល ឬដីកាសម្រេចលើកចោល) មានភាពត្រឹមត្រូវហើយនោះ តុលាការនៃបណ្តឹងជំទាស់ត្រូវចេញសេចក្តីសម្រេចច្រានចោលបណ្តឹងជំទាស់នោះ។ នៅពេលដែលដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសេចក្តីសម្រេច (សាលក្រម ឬសាលដីកា) អំពីរឿងក្តីដែលត្រូវបានបញ្ចប់ដោយសាលក្រម ឬសាលដីកាស្ថាពរដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយដែលជាអង្គសេចក្តីនៃការប្រៀបធៀបស្តីពីចំណុចត្រឹមត្រូវ ឬចំណុចមិនត្រឹមត្រូវនៃការជំនុំជម្រះសាជាថ្មី និងតាមទំហំនៃឧបាស្រ័យនោះ។[80]

## ២.២. ការវិនិច្ឆ័យអំពីអង្គសេចក្តី

ចំពោះការវិនិច្ឆ័យអំពីអង្គសេចក្តីនៅក្នុងការជំនុំជម្រះសាជាថ្មី ត្រូវធ្វើឡើងដោយបន្តពីបណ្តឹងមុន ហេតុនេះនីតិវិធីដែលត្រូវបានធ្វើពីមុនមកត្រូវមានអានុភាពនៅក្នុងការជំនុំជម្រះសាជាថ្មី លើកលែងតែនីតិវិធីដែលពាក់ព័ន្ធនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មីទេ ដែលតុលាការត្រូវធ្វើសាជាថ្មីឡើងវិញ។ ក្នុងករណីដែលដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មីបានចូលជាស្ថាពរ តុលាការត្រូវធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីអំពីរឿងក្តីដែលបានបញ្ចប់ដោយសាលក្រម ឬសាលដីកាស្ថាពរដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។ ប្រសិនបើតុលាការនៃការជំនុំជម្រះសាជាថ្មី ជាតុលាការជំនុំជម្រះទៅលើអង្គហេតុ ភាគីអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនថ្មីបាន និងចុងចម្លើយអាចដាក់ពាក្យសុំលុបចោលនូវផ្នែកណាមួយនៃសាលក្រម ឬសាលដីកាដើមដែលធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់ខ្លួន តាមរយៈបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបន្ទាប់បន្សំ ដោយអនុលោមទៅតាមបញ្ញត្តិនៃបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បន្ទប់បន្សំ (បណ្តឹង សាទុក្ខបន្ទាប់បន្សំ និងបណ្តឹងឧទ្ធរណ៍បន្ទាប់បន្សំ)។ ម្យ៉ាងវិញទៀត ចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ ក៏អាចប្តឹងតបបានដែរ ដោយយកមូលហេតុនៃការជំនុំជម្រះសាជាថ្មីដែលខ្លួនមាន។

ក្នុងការជំនុំជម្រះស្តីអំពីអង្គសេចក្តី ត្រូវប្រើនីតិវិធីទៅតាមលំដាប់ថ្នាក់នៃសាលក្រម ឬសាលដីកាដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី។ ក្នុងការជំនុំជម្រះសាជាថ្មីនៃសាលក្រមរបស់តុលាការសាលាដំបូងត្រូវប្រើ

[80] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៦ កថាខណ្ឌទី១។

បញ្ញត្តិនីតិវិធីបណ្ដឹងនៃការជំនុំជម្រះលើកទី១។ ចំណែកឯការជំនុំជម្រះសាជាថ្មីស្ដីពីសាលដីកានៃការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ ត្រូវធ្វើតាមបញ្ញត្តិនីតិវិធីនៃការជំនុំជម្រះលើកទី២។ រីឯការជំនុំជម្រះសាជាថ្មីស្ដីពីសាលដីកានៃការជំនុំជម្រះលើកចុងក្រោយដែលជាតុលាការកំពូល នោះបញ្ញត្តិនីតិវិធីនៃការជំនុំជម្រះលើកចុងក្រោយត្រូវយកមកអនុវត្ត។ ពោល ក្នុងករណីដែលសាលាដំបូងនឹងក្លាយទៅជាតុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយប្រសិនជាសាលាដំបូងយល់ឃើញថាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី សាលាដំបូងនឹងចេញដីកាសម្រេចចាប់ផ្ដើមនៃការជំនុំជម្រះសាជាថ្មី នៅពេលដីកាសម្រេចនេះបានចូលជាស្ថាពរ សាលាដំបូងនឹងបន្តនីតិវិធី ដូចបណ្ដឹងធម្មតា។ មានន័យថា គឺការកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបន្ទាប់មករៀបចំការអះអាង រៀបចំណុចវិវាទ រៀបចំភស្ដុតាងពាក់ព័ន្ធនឹងចំណុចវិវាទ បញ្ចប់នីតិវិធីត្រៀមបង្គាប់ឱ្យដាក់ភស្ដុតាង កំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រមជាអាទិ៍។ ចំណែកឯ សាលាឧទ្ធរណ៍ ដែលនឹងក្លាយជាតុលាការនៃការជំនុំជម្រះសាជាថ្មី ប្រសិនបើសាលាឧទ្ធរណ៍យល់ឃើញថាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី សាលាឧទ្ធរណ៍នឹងចេញដីកាសម្រេចចាប់ផ្ដើមការជំនុំជម្រះសាជាថ្មីនៅពេលដីកាសម្រេចនេះចូលជាស្ថាពរ ហើយសាលាឧទ្ធរណ៍នឹងបន្តនីតិវិធីដូចបណ្ដឹងឧទ្ធរណ៍ មានន័យថា គឺកំណត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលដីកា។ រីឯនៅក្នុងដំណាក់កាលតុលាការកំពូលវិញ ប្រសិនបើតុលាការកំពូលយល់ឃើញថា មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី នោះតុលាការកំពូលនឹងចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី បន្ទាប់មកតុលាការកំពូលនឹងបន្តនីតិវិធីដូចបណ្ដឹងសាទុក្ខ មានន័យថា គឺចេញដីកាសម្រេចបង្គាប់ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ ដីកាសម្រេចបង្គាប់ឱ្យដាក់ឯកសារត្រៀម និងកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ ហើយវិនិច្ឆ័យអង្គហេតុស្ដីពីអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី និងអង្គច្បាប់បន្ទាប់មកប្រកាសសាលដីកាជាដើម។[81]

តុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវវិនិច្ឆ័យ និងសម្រេចសេចក្ដីលើអង្គសេចក្ដីត្រឹមកម្រិតនៃខ្លឹមសារបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (ដែលជាគោលការណ៍នៃសិទ្ធិចាត់ចែងភាគី) ករណីដីកាសម្រេចចាប់ផ្ដើមការជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ។ នៅក្នុងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រង់ចំណុចស្ដីពី (សេចក្ដីទាមទារឱ្យជំនុំជម្រះសាជាថ្មី) មានលក្ខណៈដូចគ្នានឹងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ បើដើមចោទទាមទារត្រឹមទំហំណាតុលាការត្រូវវិនិច្ឆ័យត្រឹមទំហំនោះប៉ុណ្ណោះ ដោយមិនអាចពិចារណាលើសពីទំហំនៃឧបាស្រ័យដែលភាគីបានទាមទារឡើយ។

[81] អ្នកបណ្ដុះបណ្ដាលៈ មេធាវី អ៊ីវ ប៉ូលី, បណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី,១៨។

ឧបមាថាដើមចោទ ខ នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានសរសេរក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រង់ចំណុច (សេចក្តីទាមទារជំនុំជម្រះសាជាថ្មី) ថាបង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០០០០ ដុល្លារអាមេរិក នេះហៅថាទំហំនៃការវិនិច្ឆ័យចំពោះអង្គសេចក្តី ហេតុនេះទោះបីដើមចោទមានសិទ្ធិទាមទារលើសពីនេះ ក៏តុលាការមិនទទួលស្គាល់ឡើយទោះបីមានភស្តុតាងក៏ដោយ។

## ២.៣. ការសម្រេចសេចក្តីលើអង្គសេចក្តី

បន្ទាប់ពីតុលាការវិនិច្ឆ័យទៅលើអង្គសេចក្តីរួចរាល់ហើយ តុលាការនឹងត្រូវសម្រេចសេចក្តីដូចជាការសេចក្តីសម្រេចលុបចោលសេចក្តីសម្រេចដើម (២.៣.១) ដោយចេញសាលក្រម ឬសាលដីកាថ្មី ហើយប្រសិនបើឃើញថាសាលក្រម ឬសាដីកាដើមមិនត្រឹមត្រូវ តុលាការនឹងធ្វើការចេញសេចក្តីសម្រេចទទួលស្គាល់សេចក្តីសម្រេចដើម (២.៣.២) ប្រសិនបើសេចក្តីសម្រេចដើមមានភាពត្រឹមត្រូវដោយសារមានលទ្ធផលដូចគ្នាបន្ទាប់ពីវិនិច្ឆ័យសាជាថ្មី។

### ២.៣.១. ការសម្រេចសេចក្តីលុបចោលសេចក្តីសម្រេចដើម

បន្ទាប់ពីការវិនិច្ឆ័យ ក្នុងករណីដែលតុលាការយល់ឃើញថាលទ្ធផលនៃការវិនិច្ឆ័យដើម និងលទ្ធផលនៃការវិនិច្ឆ័យសាជាថ្មីមានលក្ខណៈផ្ទុយគ្នា តុលាការត្រូវចេញសាលក្រម ឬសាលដីកាថ្មីដែលមានខ្លឹមសារសម្រេចលុបចោលសាលក្រម ឬសាលដីកាដើមដែលបានចូលជាស្ថាពរ ហើយសម្រេចសាជាថ្មីលើការទាមទារក្នុងអង្គសេចក្តីរបស់ដើមបណ្តឹងនៃសាលក្រម ឬសាលដីកាដើម ដោយតុលាការត្រូវចេញសាលក្រម ឬសាលដីកាថ្មី ដែលនៅក្នុងសេចក្តីសម្រេចបញ្ចប់ត្រូវសរសេរបញ្ជាក់ថាលុបចោលសាលក្រម ឬសាលដីកាដើម និងច្រានចោលការទាមទារក្នុងអង្គសេចក្តី។[82] ប្រសិនបើមិនអនុញ្ញាតឱ្យមានការលុបចោលនូវសាលក្រម ឬសាលដីកាដើមទាំងដែលមានវិការៈធ្ងន់ធ្ងរហាក់ដូចជាមានលក្ខណៈផ្ទុយនឹងទស្សនៈស្តីពីការស្វែងរកយុត្តិធម៌ តាមរយៈនីតិវិធីបណ្តឹងប្រកបដោយភាពត្រឹមត្រូវមួយ ហើយនាំឱ្យប៉ះពាល់ទៅដល់សិទ្ធិ និងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ ដែលជាហេតុនាំឱ្យក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិអំពីករណីមួយចំនួន ដែលមានអត្ថិភាពនៃវិការៈធ្ងន់ធ្ងរនៅក្នុងសាលក្រម ឬសាលដីកា ហើយយល់ថាយុត្តិធម៌ត្រូវបានបំពានប្រសិនបើមិនអនុញ្ញាតឱ្យលុបចោលសាលក្រម ឬសាលដីកានោះ។

កាលណាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយប្រសិនបើតុលាការសន្និដ្ឋានថាទទួលបានលទ្ធផលខុសពីសាលក្រម ឬសាលដីកាដើម នោះតុលាការត្រូវលុបចោលនូវសាលក្រម ឬសាលដីកាដើម ហើយត្រូវវិនិច្ឆ័យលើអង្គសេចក្តីបន្ថែមទៀត។ ប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខ ជាតុលាការនៃបណ្តឹង

[82] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៦ កថាខណ្ឌទី៣។

ទាមទារជំនុំជម្រះសាជាថ្មី ហើយតុលាការនៃបណ្តឹងសាទុក្ខ មិនអាចធ្វើការសម្រេចសេចក្តីជំនួសសាលដីកាដើម ដោយមិនវិនិច្ឆ័យអង្គហេតុចំពោះរឿងក្តីឡើយ តុលាការចាំបាច់ត្រូវចេញសាលដីកាដែលបង្គាប់ឱ្យបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការនៃការវិនិច្ឆ័យអង្គហេតុវិញ គឺមានន័យថាបញ្ជូនត្រឡប់ទៅសាលាសាលាដំបូង ឬឧទ្ធរណ៍វិញ យោងតាមមាត្រា២៩៩ ដោយសារតែតុលាការនៃបណ្តឹងសាទុក្ខ ជាតុលាការនៃការវិនិច្ឆ័យលើអង្គច្បាប់ ហើយជាគោលការណ៍មិនវិនិច្ឆ័យទៅលើអង្គហេតុឡើយ។ ចំពោះសេចក្តីសម្រេចអំពីប្រាក់ប្រដាប់ក្តីដែលទាក់ទងនឹងសាលក្រម ឬសាលដីកាដើមដែលត្រូវបានលុបចោល ហើយតុលាការនៃការជំនុំជម្រះសាជាថ្មីត្រូវសម្រេចសេចក្តីសាជាថ្មីចំពោះប្រាក់ប្រដាប់ក្តី។

### ២.៣.២. ការទទួលស្គាល់សេចក្តីសម្រេចដើម

នៅក្នុងដំណាក់កាលដែលពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានដាក់ទៅតុលាការជាកិច្ចចម្បងដំបូង គឺតុលាការត្រូវពិនិត្យអំពីនិយ័តភាពនៃពាក្យបណ្តឹងនោះ ហើយបន្ទាប់ពីតុលាការបានធ្វើការវិនិច្ឆ័យ យ៉ាងលម្អិតទៅលើអង្គសេចក្តីរួចមក ប្រសិនបើតុលាការយល់ឃើញថាសាលក្រម ឬសាលដីកាដើមដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី មានលក្ខណៈត្រឹមត្រូវស្របទៅនឹងបញ្ញត្តិច្បាប់ ឬមិនមានភាពផ្ទុយពីបញ្ញត្តិនៃច្បាប់ទេ តុលាការត្រូវចេញសាលក្រម ឬសាលដីកាដោយច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយលទ្ធផលនៃការវិនិច្ឆ័យដើម និងលទ្ធផលនៃការវិនិច្ឆ័យសាជាថ្មីដូចគ្នាដដែល។[83] ទោះបីជាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ក៏មិនប្រាកដថាតុលាការនៃបណ្តឹងជំនុំជម្រះសាជាថ្មី ត្រូវលុបចោលសេចក្តីសម្រេចដើមដែលបានចូលជាស្ថាពរឡើយ។ មូលហេតុនៃការវិនិច្ឆ័យលើអង្គសេចក្តីក្នុងការលុបចោលសេចក្តីសម្រេចដើម លុះត្រាតែសេចក្តីដើមផ្ទុយច្បាប់សារជាតុ ប៉ុន្តែបើសេចក្តីសម្រេចដើមមិនផ្ទុយច្បាប់សារជាតុទេ ដោយគ្រាន់តែមានកំហុសនីតិវិធី ដូចជាចៅក្រមដែលចេញសាលក្រម ជាចៅក្រមដែលមិនអាចចូលរួមចេញសាលក្រម ដោយសារជាញាតិរបស់ភាគីណាមួយ ឬអ្នកតំណាងគ្មានលក្ខណៈសម្បត្តិ ឬមិនបានទទួលការប្រគល់សិទ្ធិជាដើម នោះមិននាំឱ្យលុបចោលសេចក្តីសម្រេចដើមឡើយ។[84]

ក្នុងករណីតុលាការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី តុលាការត្រូវតម្កល់អត្ថិភាពនៃសាលក្រម ឬសាលដីកាដើមដែលបានចូលជាស្ថាពរមុន ទុកជាបានការដដែល។ តុលាការទទួលស្គាល់នូវសេចក្តីសម្រេចដែលជាសាលក្រម ឬសាលដីកាដើមរក្សាទុកនៅដដែល ក៏ព្រោះថាទោះបីជាសាលក្រម ឬសាលដីកាដើមមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយក៏មូលហេតុនៃការជំនុំជម្រះសាជាថ្មីមិនបានកែប្រែការពិតនៃសំណុំរឿងឡើយ ដោយយុត្តិធម៌នៅតែមានសម្រាប់អ្នកស្អាតស្អំ។ ជាក់ស្តែងចៅក្រមដែលពុំអាចចូលរួម

[83] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១៦ កថាខណ្ឌទី២។

[84] អ្នកបណ្តុះបណ្តាលៈ មេធាវី អ៊ីវ ប៉ូលី, បណ្តឹងទាមទារជំនុំជម្រះសាជាថ្មី,២៣។

ចំណែកក្នុងការសម្រេចសេចក្តីបានចូលរួមក្នុងការសម្រេចសេចក្តី ប៉ុន្តែក្រោយពេលតុលាការនៃការជំនុំជម្រះសាជាថ្មីពិនិត្យមើលទៅលើខ្លឹមសារនៃការវិនិច្ឆ័យនោះឃើញថាអត្ថន័យនៃការវិនិច្ឆ័យលើសាលក្រមដើមនោះមានភាពត្រឹមត្រូវ ហេតុនេះតុលាការត្រូវច្រានចោលនូវការទាមទារជំនុំជម្រះសាជាថ្មី។[85]

[85] ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី* (២០០៧),២៩៥។

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣

# បញ្ហាប្រឈម និងដំណោះស្រាយ

ដើម្បីយល់បានកាន់តែច្បាស់ អំពីប្រធានបទបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងដើម្បីធ្វើយ៉ាងណាឱ្យបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មីកាន់តែមានភាពល្អប្រសើរ យើងនឹងធ្វើការស្វែងយល់បន្ថែមពីបញ្ហាប្រឈមនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (៣.១) និងដំណោះស្រាយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (៣.២)។

## ៣.១. បញ្ហាប្រឈមនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

### ៣.១.១. ការអូសបន្លាយពេលវេលា

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដូចជាប្រភេទបណ្ដឹងផ្សេងៗទៀត ដែលត្រូវបានគូភាគីនៃបណ្ដឹង និងអ្នកច្បាប់ ឬអ្នកវិជ្ជាជីវៈដូចជាមេធាវីជាដើមយកមកប្រើប្រាស់នៅពេលដែលពួកគេអស់វិធីក្នុងការដោះស្រាយបន្តទៀត ដោយពួកគេនៅតែជ្រើសរើសការប្ដឹងទាមទារឱ្យជម្រះសាជាថ្មីទាំងដែលពេលខ្លះមិនមានសូម្បីតែមូលហេតុច្បាស់លាស់ដូចបានកំណត់ដោយច្បាប់។

ជាទូទៅ មិនមែនគ្រប់ពាក្យបណ្ដឹងសុទ្ធតែតុលាការទទួលយកមកវិនិច្ឆ័យឡើយ ក៏មានបណ្ដឹងខ្លះតុលាការច្រានចោល ឬលើកចោលដោយមូលហេតុផ្សេងៗ ដោយសារតែបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជានីតិវិធីមួយតឹងរ៉ឹងដែលតម្រូវឱ្យអ្នកប្ដឹងគោរពនូវលក្ខខណ្ឌ និងមានមូលហេតុច្បាស់លាស់ជាក់លាក់ដូចដែលបានកំណត់នៅក្នុងមាត្រា៣០៧។ តែបើសិនជាអ្នកប្ដឹងមិនគោរពទៅតាមលក្ខខណ្ឌ ឬគ្មានមូលហេតុច្បាស់លាស់ទេនោះ តុលាការនឹងច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាហេតុដែលនាំឱ្យភាគីអាចអនុវត្តសិទ្ធិធ្វើបណ្ដឹងជំទាស់ ដែលនេះជាសញ្ញាណមួយបង្ហាញថា ប្រសិនជាក្នុងករណីដែលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានទទួលស្គាល់ដោយមានមូលហេតុជាក់លាក់ ភាគីប្រាកដជាទទួលបានប្រយោជន៍មកវិញ ទោះបីជាខាតបង់ពេលវេលាបន្តិចក៏អាចទទួលយកបានដែរ។ ផ្ទុយទៅវិញប្រសិនបើក្នុងករណីដែលពាក្យបណ្ដឹងមិនត្រូវបានទទួលស្គាល់ទេ ឬក៏តុលាការមិនធ្វើការវិនិច្ឆ័យទេនោះភាគីនៃបណ្ដឹងជាពិសេសចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងប្រាកដជាខាតបង់ពេលវេលាជាក់ជាមិនខាន និងបង្កភាពស្មុគស្មាញដល់ចុងចម្លើយក្រោយពេលសាលក្រមចូលជាស្ថាពរ។

### ៣.១.២. ខាតបង់សោហ៊ុយ

តុលាការនៅក្នុងសំណុំរឿងរដ្ឋប្បវេណីគឺជាតុលាការអកម្មដែលខុសពីតុលាការនៅក្នុងសំណុំរឿងព្រហ្មទណ្ឌ ដែលជាតុលាការសកម្មសម្រាប់ការចំណាយថ្លៃសោហ៊ុយ ថ្លៃរ៉ាប់រងផ្សេងៗគឺរដ្ឋជាអ្នកទទួលខុសត្រូវ។

ចំណែកឯរឿងរដ្ឋប្បវេណី ជាការដោះស្រាយជម្លោះដោយផ្អែកលើវិវាទឯកជន ដែលតម្រូវឱ្យភាគីធ្វើការបង់ប្រាក់ថ្លៃពន្ធ និងសោហ៊ុយចំណាយផ្សេងៗដើម្បីដំណើរការនីតិវិធីនៃរឿងក្តីដែលហៅថាប្រាក់ប្រដាប់ក្តី។

ប្រាក់ប្រដាប់ក្តី គឺជាពន្ធសរុប និងចំណាយផ្សេងៗដែលត្រូវបង់សម្រាប់ដំណើរការនៃរឿងក្តីនីមួយៗ ដែលត្រូវបានកំណត់ដោយតុលាការ ដោយការគណនាតាមកំណត់ច្បាប់។[86] ជាទូទៅទំហំចំនួននៃប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណី និងបុគ្គលដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្តីរដ្ឋប្បវេណី គឺប្រែប្រួលទៅតាមប្រភេទនៃបណ្តឹង តម្លៃកម្មវត្ថុនៃការទាមទារជាក់ស្តែង និងស្ថានភាពផ្សេងៗនៃរឿងក្តីរដ្ឋប្បវេណីនីមួយៗ។ គ្រប់សកម្មភាពរបស់តុលាការ និងភាគីនៅក្នុងប្រភេទបណ្តឹងនីមួយៗ គឺតម្រូវឱ្យភាគីនៃបណ្តឹងធ្វើការចំណាយថវិកាផ្ទាល់របស់ខ្លួនដើម្បីអាចទាមទារឱ្យតុលាការធ្វើការដំណើរការនីតិវិធីបានដូចជា ពន្ធដាក់ពាក្យសុំ សោហ៊ុយនីតិវិធី សោហ៊ុយធ្វើដំណើរជាដើម។ ប្រាក់ប្រដាប់ក្តីដែលបានលើកឡើងខាងលើ គឺជាខាតបង់តតប្រយោជន៍ដល់ដើមចោទ និងជាពិសេសចុងចម្លើយ។ បើសិនជាក្នុងករណីសេចក្តីសម្រេចសាថ្មីរបស់តុលាការមានលទ្ធផល ដូចគ្នាទៅនឹងសេចក្តីសម្រេចដើម ឬពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានលើកចោល ឬត្រូវបានប្រានចោល នោះវានឹងនាំឱ្យខាតបង់ថវិកាយ៉ាងច្រើនចំពោះភាគីដើមចោទ។ តែផ្ទុយទៅវិញ ក្នុងករណីដែលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានតុលាការទទួលស្គាល់ និងសម្រេចតាមការទាមទាររបស់ដើមចោទ ប្រាកដណាស់ថាអ្នកខាតបង់ ឬបាត់បង់ផលប្រយោជន៍នោះជាភាគីចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយដោយជាគោលការណ៍កំណត់ថាប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកចាញ់ក្តី។[87]

### ៣.១.៣. បញ្ហាភាពស្មុគស្មាញដល់ភាគីពាក់ព័ន្ធក្នុងសំណុំរឿង

នីតិវិធីបណ្តឹងនៅក្នុងសំណុំរឿងរដ្ឋប្បវេណី បណ្តឹងប្រភេទណាក៏ដោយក៏មានលក្ខណៈស្មុគស្មាញដែរ តែចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី វាអាចនឹងមានលក្ខណៈស្មុគស្មាញច្រើនជាងប្រភេទនីតិវិធីបណ្តឹងធម្មតា ដោយសារតែវាជាប្រភេទបណ្តឹងឧបាស្រ័យពិសេសដែលភាគីទាមទារឱ្យតុលាការកែប្រែ ឬលុបចោលសេចក្តីសម្រេចដែលបានចូលជាស្ថាពរហើយ។ វាមិនងាយស្រួលនោះទេក្នុងការលុបចោលសេចក្តីសម្រេចដែលចូលជាស្ថាពរហើយ ហេតុនេះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺមានច្រើនដំណាក់កាល ដើម្បីអាចឱ្យតុលាការធ្វើការចេញសេចក្តីសម្រេចទៅតាមពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដោយតុលាការត្រូវឆ្លងកាត់ដំណាក់កាលជាច្រើនដូចជា ដំណាក់កាលពិនិត្យពាក្យបណ្តឹង ដំណាក់កាលជំនុំជម្រះ អំពីភាពស្របច្បាប់នៃបណ្តឹង និងអត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីដោយការចេញដីកាជំនុំជម្រះសាជាថ្មី ប្រសិន

[86] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៣។

[87] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦៤ វាក្យខណ្ឌទី១។

ជាមានអត្ថិភាព និងដំណាក់កាលទី២ គឺដំណាក់កាលវិនិច្ឆ័យលើអង្គសេចក្តី។

ក្រៅពីភាពស្មុគស្មាញទៅលើបញ្ហានេះហើយ បណ្តឹងទាមទារជំនុំជម្រះសាជាថ្មីក៏មានវត្តមាននៃបណ្តឹងជំទាស់ផងដែរ ដែលជាហេតុធ្វើឱ្យកាន់តែមានភាពស្មុគស្មាញ ដោយយោងតាមបទប្បញ្ញត្តិនៃការជំនុំជម្រះសាជាថ្មី យើងឃើញថានៅក្នុងការវិនិច្ឆ័យទៅលើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី មានការវិនិច្ឆ័យទៅលើមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ ការសម្រេចលើការវិនិច្ឆ័យពីមូលហេតុនៃការជំនុំជម្រះសាជាថ្មីច្បាប់បានអនុញ្ញាតថាអាចប្តឹងជំទាស់បាន ដោយភាគីនៃបណ្តឹងមិនថាតែដីកាសម្រេចនោះជាដីកាសម្រេចច្រានចោល ឬលើកចោល និងចាប់ផ្តើមជំនុំជម្រះសាជាថ្មីនោះទេ។ នៅក្នុងដំណាក់កាលនៃបណ្តឹងជំទាស់តុលាការនៃបណ្តឹងជំទាស់នឹងត្រូវពិនិត្យទៅលើមូលហេតុនៃបណ្តឹងជំទាស់ បើតុលាការពិនិត្យឃើញថាមានមូលហេតុនៃបណ្តឹងជំទាស់ តុលាការនៃបណ្តឹងជំទាស់ត្រូវវិនិច្ឆ័យ និងសម្រេច។ ក្រៅពីបណ្តឹងជំទាស់ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបន្ទាប់បន្សំក្នុងនោះផងដែរ។

### ៣.១.៤. បង្កភាពស្មុគស្មាញដល់តុលាការ

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក្រៅពីបង្កភាពស្មុគស្មាញ ការចំណាយពេលវេលា និងការចំណាយសោហ៊ុយរបស់ភាគី បណ្តឹងទាមទារជំនុំជម្រះសាជាថ្មីក៏បង្កភាពស្មុគស្មាញដល់តុលាការផងដែរ។ តុលាការជាអ្នកវិនិច្ឆ័យ និងសម្រេចសេចក្តីទៅលើសាលក្រម ឬសាលដីកានៅពេលដែលទទួលបាននូវពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីតុលាការត្រូវធ្វើការវិនិច្ឆ័យសារឡើងវិញ ឬម្តងទៀតនូវចំណុចដែលបានវិនិច្ឆ័យរួច ក្នុងស្ថានភាពនេះដើម្បីធានាបាននូវសាលក្រមដែលល្អប្រសើរគ្មានវិការៈ តុលាការច្បាស់ជាបន្ថែមការយកចិត្តទុកដាក់ក្នុងការពិនិត្យពិច្ច័យ។ ការពិនិត្យសារឡើងវិញនេះក៏ខុសគ្នាពីបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសាទុក្ខផងដែរ បើនិយាយពីបណ្តឹងឧទ្ធរណ៍ និងតុលាការនៃបណ្តឹងសាទុក្ខ ច្បាស់ជាមិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញផលឡើងវិញទេ គឺធ្វើតែនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ប៉ុណ្ណោះ ដើម្បីវិនិច្ឆ័យ និងចេញសាលក្រម ឬសាលដីកា។ តែបើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ បើមូលហេតុនៃការជំនុំជម្រះសាជាថ្មីបានកើតឡើងនៅដំណាក់កាលណាមួយ តុលាការនឹងធ្វើការជម្រះសាជាថ្មីនៅដំណាក់កាលនោះ មានន័យថាបើមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីនៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល តុលាការត្រូវធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលសាជាថ្មី រួចធ្វើការទាញហេតុផលដោយផ្ទាល់មាត់។

### ៣.១.៥. ពន្យារពេលអនុវត្តដោយការដាក់ពាក្យបណ្តឹងដែលគ្មានមូលហេតុ

ការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីរដ្ឋប្បវេណីមួយដែលអនុញ្ញាតឱ្យភាគីដែលទទួលរងនូវភាពអយុត្តិធម៌ដោយការសម្រេចសេចក្តីមានចំណុចខ្វះចន្លោះក្នុងដំណើរការនីតិវិធីនៃបណ្តឹង ឬឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យសាលក្រម ឬសាលដីកានោះមានវិការៈធ្ងន់ធ្ងរ ឬមានភាពខ្វះខាតមិនប្រក្រតីដែលបានចូលជាស្ថាពររួចហើយ។ ទោះបីជាច្បាប់បានផ្តល់សិទ្ធិឱ្យភាគីដែលបានចាញ់ក្តីនៅក្នុងសាលក្រម ឬសាលដីកាស្ថាពររួច

ហើយក៏ដោយ ករណីដែលភាគីចាញ់ក្តីបានដាក់ពាក្យបណ្តឹងទាមទារ ទាំងដែលខ្លួនពុំមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដោយសារតែខ្លួនមានបំណងចង់ពន្យារពេលនៃការអនុវត្តសាលក្រម ឬសាលដីកា។ ការដាក់ពាក្យបណ្តឹងដោយគ្មានមូលហេតុនេះបានធ្វើឱ្យមានការប៉ះពាល់យ៉ាងខ្លាំងទៅដល់ភាគីដើមចោទ និងចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និងជាពិសេសបណ្តាលឱ្យមានភាពស្មុគស្មាញទៅដល់តុលាការ។

## ៣.១.៦. បញ្ហាការស្មុគស្មាញដល់ការធ្វើបដិទាននូវស្ថានភាពដើម

ទោះបីជាបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី បានផ្តល់នូវសារប្រយោជន៍ជាច្រើនដល់ភាគី ដែលបានចាញ់ក្តីទាំងស្រុង ឬមួយផ្នែកនៃសាលក្រម ឬសាលដីកាដើមក៏ដោយ ប៉ុន្តែអានុភាពនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីគឺបានធ្វើឱ្យមានការផ្អាកការអនុវត្តដោយបង្ខំ។ ជាទូទៅក្នុងបណ្តឹទាមទារឱ្យផ្តល់តាវកាលិក នៅពេលដែលភាគីដែលបានឈ្នះក្តីទាំងស្រុង ភាគីនោះគឺមានបំណងចង់រឹបអូសសិទ្ធិលើបំណុលរបស់ខ្លួនមានន័យថា ចង់បានប្រាក់ក៏ដូចជាវត្ថុរបស់ខ្លួនដែលនៅនឹងភាគីម្ខាងទៀតមកត្រឡប់ជារបស់ខ្លួនវិញ។ ក្នុងករណីនេះភាគីដែលទទួលបានលិខិតអនុវត្ត អាចយកលិខិតអនុវត្ត ទៅអនុវត្តសិទ្ធិរបស់ខ្លួនដោយការដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ដើម្បីធ្វើការអនុវត្តដោយបង្ខំចំពោះកូនបំណុលដែលជាអ្នកចាញ់ក្តីក្នុងដំណាក់កាលទី១ឱ្យប្រគល់វត្ថុ ឬបង់ប្រាក់ក្នុងចំនួនណាមួយជាកំណត់មកឱ្យខ្លួនបាន។

ប្រសិនបើការអនុវត្តដោយបង្ខំនោះកំពុងតែធ្វើ ឬធ្វើការអនុវត្តដោយបង្ខំរួចអស់ជាស្រេចហើយ។ ក្នុងករណីពេលនោះដែរ ប្រសិនជាបុគ្គលដែលបានចាញ់ក្តី ក្នុងដំណាក់កាលសាលក្រម ឬសាលដីកាដើមបានដាក់ពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ហើយបានដាក់ឯកសារដែលជាមូលហេតុនៃការផ្អាកការអនុវត្តដោយបង្ខំ ហើយតុលាការបានសម្រេចផ្អាកការអនុវត្តដោយបង្ខំតាមការទាមទាររបស់ដើមបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី។ នោះជាលទ្ធផលនឹងនាំឱ្យមានផលវិបាក និងស្មុគស្មាញក្នុងការធ្វើបដិទាននូវស្ថានភាពដើមវិញ ពិសេសពិបាកធ្វើការទាមទារកម្មវត្ថុពីអ្នកទិញតាមផ្លូវតុលាការ ក្នុងករណីសាលក្រម ឬសាលដីកាដើម ជាសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិក បើទោះបីជាភាគីដែលបានដាក់ពាក្យសុំឱ្យផ្អាកការអនុវត្តដោយបង្ខំមានមូលហេតុនៃការផ្អាកក៏ដោយ។ មួយវិញទៀតស្ថានភាពនេះអាចទៅរួចផងដែរ ដោយសារអំឡុងពេលដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានរយៈពេលយូរខុសពីបណ្តឹងឧបាស្រ័យដទៃទៀតដែលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានរយៈពេល ៥ឆ្នាំគិតពីថ្ងៃដែលសាលក្រម ឬសាលដីកាស្ថាពរ ឬគិតចាប់ពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ហើយភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មីក្រោយពេលនោះ។ ហើយមានមូលហេតុ នៃការជំនុំជម្រះសាជាថ្មីមួយចំនួន ដោយច្បាប់ថែមទាំងមិនបានកម្រិតអំឡុងពេលក្នុងការដាក់ពាក្យបណ្តឹងផងដែរ។

### ៣.១.៧. មានការវាយតម្លៃលើសេចក្ដីសម្រេចរបស់តុលាការពីសាធារណៈជន

ដោយសារតែសេចក្ដីសម្រេចរបស់តុលាការត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមរយៈការបិទផ្សាយនៅកន្លែងបិទប្រកាសនៅតុលាការ ឬអាចផ្សាយតាមរយៈសារព័ត៌មាន មួយវិញទៀតជាគោលការណ៍តុលាការតែងតែប្រកាសសាលក្រមនៅក្នុងសវនាការជាសាធារណៈ ដែលអាចឱ្យសាធារណៈជនអាចធ្វើការមកចូលរួមទស្សនា ស្ដាប់ការប្រកាសនូវលទ្ធផល ឬស្ដាប់នូវការពិភាក្សាដេញដោលរបស់តុលាការនៅក្នុងសវនាការ ហើយនៅពេលដែលសាធារណៈជនឃើញថាតុលាការចេញសេចក្ដីសម្រេចមានភាពមិនប្រក្រតី ពួកគាត់តែងតែវាយតម្លៃទៅលើសេចក្ដីសម្រេចនោះ។ ដោយមានការវាយតម្លៃថាសេចក្ដីសម្រេចលើកទី១ វិថ្ឋ័យដោយភាពធ្វេសប្រហែសមិនយកចិត្តទុកដាក់ឱ្យបានល្អិតល្អន់ធ្វើឱ្យមានការរំលោភលើសិទ្ធិភាគី។ ការសម្រេចសេចក្ដីរបស់តុលាការតែងតែមានបញ្ហាខ្វះចន្លោះជៀសមិនផុតនោះទេពីព្រោះតុលាការក៏ជាមនុស្សដែរ ហើយមនុស្សតែងតែមានកំហុស និងការភ្លាំងភ្លាត់ត្រង់ចំណុចណាមួយ ហេតុនេះអាចនឹងមិនបានមើលឱ្យបានគ្រប់ជ្រុងជ្រោយ។ តែប្រជាពលរដ្ឋខ្មែរយើងសព្វថ្ងៃមិនសូវបានយល់ដឹងច្បាស់នោះទេ តែងតែបន្ទោសទៅលើតុលាការដោយការជេស្ដី និយាយថាតុលាការគ្មានយុត្តិធម៌ធ្វើការមិនបានយកចិត្តទុកដាក់ជាដើម។ ម្យ៉ាងទៀតបើសិនជាភាគីនៃបណ្ដឹងមិនបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយព្រមទទួលយកលទ្ធផលនៃការជម្រះលើកទីមួយនោះភាគីចាញ់ក្ដីនឹងទទួលរងនូវភាពអយុត្តិធម៌។

## ៣.២. ដំណោះស្រាយ

### ៣.២.១. ចំពោះតុលាការ

នៅក្នុងការវិនិច្ឆ័យទៅលើសំណុំរឿងនីមួយៗ តែងតែមានផលវិបាកក៏ដូចជាបញ្ហាប្រឈមជាច្រើនបានកើតឡើង តែគ្រប់បញ្ហាទាំងអស់ត្រូវមានដំណោះស្រាយ ហើយក្នុងគោលបំណងដើម្បីការពារកុំឱ្យមាន ឬក៏កាត់បន្ថយនូវការសម្រេចសេចក្ដីដោយមានវិការៈដែលនាំឱ្យប៉ះពាល់ទៅដល់ប្រព័ន្ធយុត្តិធម៌។ ដូច្នេះតុលាការគួរតែពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយប្រកបដោយការយកចិត្តទុកដាក់ ហ្មត់ចត់ក្នុងការងាររបស់ខ្លួនមុននឹងចេញសេចក្ដីសម្រេចអ្វីមួយ ដើម្បីជៀសវាងនូវវិការៈទៅលើសាលក្រម ឬសាលដីកា។ ហើយតុលាការត្រូវពង្រឹងទៅលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងយកចិត្តទុកដាក់ក្នុងការដោះស្រាយសំណុំរឿងដែលជាវិវាទរបស់គូភាគីបន្ថែមឱ្យបានម៉ឺងម៉ាត់ ដោយប្រកាន់យកភាពត្រឹមត្រូវ និងយុត្តិធម៌ជាគោលក្នុងចំណាត់ការរបស់ខ្លួន។

ក្រៅពីនេះទៀតសោតចៅក្រម ឬតុលាការទាំងឡាយត្រូវសម្រេចសេចក្ដីប្រកាន់យកនូវភាពយុត្តិធម៌មិនលម្អៀង ដោយឈរលើគោលការណ៍គោរពច្បាប់ដោយមិនធ្វើការគាបសង្កត់ ការគំរាមគំហែង ឬការបំភិតបំភ័យ ការបង្គាប់ដោយផ្ទាល់ ឬដោយប្រយោលពីភាគីណាមួយក្នុងរឿងក្ដី ឬបុគ្គលណាមួយឡើយ ហើយត្រូវជៀសវាងនូវអគតិទាំងបួន គឺឆន្ទាគតិ ទោសាគតិ ភយាគតិ មោហាគិត និងត្រូវគោរពទៅលើបទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តទាំងឡាយជាដាច់ខាតក្នុងការធានាការប្រព្រឹត្តទៅដ៏ល្អនៃការអនុវត្តក្រមសីលធម៌របស់ចៅក្រម។

### ៣.២.២. ចំពោះភាគី

ដើម្បីហាមឃាត់ដើមចោទក្នុងការដាក់ពាក្យបណ្តឹងដែលមានគោលបំណងពន្យាពេលវេលា និងដើម្បីកាត់បន្ថយកុំឱ្យមានភាពស្មុគស្មាញទៅដល់ភាគី និងតុលាការ នោះតុលាការត្រូវតែលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក្នុងដំណាក់កាលពិនិត្យទៅលើពាក្យបណ្តឹងតែម្តងដើម្បីកុំឱ្យខាតពេលវេលា។ ភាគីនៃបណ្តឹងមានសិទ្ធិរៀងខ្លួនៗស្របទៅតាមច្បាប់កំណត់ ផ្អែកតាមគោលការណ៍សិទ្ធិចាត់ចែងរបស់ភាគី។ ទោះបីជាច្បាប់ផ្តល់សិទ្ធិឱ្យដល់ភាគីយ៉ាងណាក៏ដោយ ក៏ភាគីជាពិសេសដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមិនគួរយកសិទ្ធិរបស់ខ្លួនយកមកចាត់ចែង ឬប្រើប្រាស់តាមអំពើចិត្តដោយបំពានទៅលើសិទ្ធិរបស់អ្នកដទៃតាមរយៈការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយគ្មានមូលហេតុនោះដែរ។ ដោយហេតុថាការវាគ្មានផលប្រយោជន៍អ្វីឡើយ។ បន្ថែមពីនេះទៅទៀតមុននឹងដាក់ពាក្យបណ្តឹង ភាគីត្រូវធ្វើការស្រាវជ្រាវឱ្យបានលម្អិតជាមុននូវទំនាក់ទំនងនៃអង្គហេតុចំពោះសាក្សី និងភស្តុតាងផ្សេងៗដើម្បីធ្វើការអះអាង និងបញ្ជាក់ឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ក្នុងបណ្តឹង។

ពិសេសជាងនេះទៀត ភាគីត្រូវតែគោរពឱ្យបានហ្មត់ចត់ចំពោះគោលការណ៍ច្បាប់ដែលបានចែងកំណត់ដោយក្រមនីតិវិធីរដ្ឋប្បវេណីដែលបានបញ្ញត្តិអំពីការទទួលខុសត្រូវភាគីក្នុងបណ្តឹង គឺភាគីត្រូវមានការទទួលខុសត្រូវចំពោះសកម្មភាពបណ្តឹងដែលខ្លួនអនុវត្តក្នុងបណ្តឹងរដ្ឋប្បវេណីប្រកបដោយសុចរិត និងស្មោះត្រង់។[88] មានន័យថាក្នុងខណៈពេលដែលភាគីត្រូវបានអនុញ្ញាតឱ្យអនុវត្តបណ្តឹងតាមឆន្ទៈរបស់ខ្លួនដើម្បីឈ្នះក្តី តែពួកគេក៏ត្រូវបានហាមឃាត់មិនឱ្យអនុវត្តបណ្តឹងដោយមិនស្មោះត្រង់ និងដោយទុច្ចរិតចំពោះភាគីម្ខាងទៀតឡើយ។ ដែលសកម្មភាពបណ្តឹងដែលត្រូវចាត់ទុកថាមិនមានភាពស្មោះត្រង់នេះត្រូវបានកំណត់ទៅតាមករណីជាក់ស្តែងដែលកើតមានឡើង។ ឧបមាថាភាគីមានគំនិតទុច្ចរិតបានដាក់ពាក្យបណ្តឹងទៅតុលាការទាំងដែលខ្លួនគ្មានមូលហេតុច្បាស់លាស់ទេ តែដោយសារខ្លួនមានបំណងមិនស្មោះត្រង់ និងគោលបំណងធ្វើយ៉ាងណាក៏ដោយឱ្យតែអាចធ្វើការបង្អាក់ ឬពន្យារពេលក្នុងការអនុវត្តសាលក្រមជាដើម។ ទាំងនេះជាគំនិតដែលមិនមានភាពសុចរិតនិងស្មោះត្រង់របស់ភាគីដែលក្រមនីតិវិធីរដ្ឋប្បវេណីបានចែងទេ។

### ៣.២.៣. បញ្ហាច្បាប់

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ មិនបានចែងកម្រិតទៅលើការដាក់ពាក្យបណ្តឹងនោះឡើយ មានន័យថា ឱ្យតែមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីបានកើតមានឡើង ភាគីអាចដាក់ពាក្យបណ្តឹងទាមទារបាន ទោះបីជាសាលក្រម ឬសាលដីកានៃការជំនុំជម្រះសាជាថ្មីបានចូលជាស្ថាពរហើយក៏ដោយ ភាគីនៅតែអាចដាក់

[88] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦,មាត្រា៤។

ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដដែល។ ច្បាប់មិនគួរអនុញ្ញាតឱ្យភាគីដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយមិនកំណត់បាននោះទេ ដែលនេះជាការអនុញ្ញាតហួសហេតុ ហើយច្បាប់គួរតែកម្រិតទៅលើការដាក់ពាក្យបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី ត្រឹមចំនួនណាមួយជាក់លាក់ដើម្បីជៀសវាងកុំឱ្យភាគីធ្វើការទាមទារទៅលើសំណុំរឿងដដែលៗច្រើនលើកច្រើនសារ។

**៣.២.៣. ការពង្រឹងប្រព័ន្ធផ្សព្វផ្សាយ**

ដោយសារតែប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍ ការផ្សព្វផ្សាយស្ដីពីសិទ្ធិទទួលបានការជម្រះក្ដីដោយយុត្តិធម៌នៅពុំទាន់មានលក្ខណៈជឿនលឿន និងពេញលេញនៅឡើយទេ។ រាជរដ្ឋាភិបាលគួរយកចិត្តទុកដាក់ក្នុងការផ្សព្វផ្សាយបន្ថែមពីសិទ្ធិខាងលើឱ្យមានភាពទូលំទូលាយ ដោយបញ្ចូលឱ្យមានកម្មវិធីសិក្សាស្ដីពីសិទ្ធិជាមូលដ្ឋានរបស់បុគ្គល ឬបង្កើនការគាំទ្រតាមរយៈការផ្សព្វផ្សាយតាមបណ្ដាញសង្គមឌីជីថល វិទ្យុទស្សនាវដ្ដីអាចជាមធ្យោបាយមួយដើម្បីឱ្យពលរដ្ឋយល់ដឹងពីច្បាប់។ ការបង្កើតជាវីដេអូអប់រំស្ដីពីសិទ្ធិ ដូចជាការពិភាក្សាដេញដោលទៅលើគោលការណ៍អនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងបង្កើតមាតិកាអប់រំផ្សេងៗទៀតតាមរយៈបណ្ដាញសង្គមឌីជីថល ទូរទស្សន៍ ឬបញ្ចាំងលើផ្ទាំងប៉ាណូតាមដងផ្លូវជាដើម។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី រួចមក ក្រុមយើងខ្ញុំបានរកឃើញថា បណ្តឹងនេះមានលក្ខណៈពិសេស និងមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការពារ និងដោះស្រាយជម្លោះរបស់គូភាគីវិវាទ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីនេះ ដែលផ្តល់ឱ្យភាគីនៃវិវាទអាចការពារ សិទ្ធិរបស់ខ្លួនបានក្នុងករណីដែលមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដែលបានលើកឡើងដោយដើមចោទ ចំពោះបញ្ហាវិការៈនានានៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយ ដែលមានអានុភាពអាជ្ញាអស់ជំនុំ។ ទោះបីជាយ៉ាងណាក៏ដោយ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏មានបញ្ហាមួយចំនួនដែលជាផលវិបាកផង ដែរដូចជា៖

– ដំណើរការក៏ដូចជាលំហូរនៅក្នុងបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីទាំងមូល មានច្រើនដំណាក់កាលមុន នឹងឈានចូលទៅដល់ការសម្រេចសេចក្តី តាមការទាមទាររបស់ដើមចោទ ដូចជា ដំណាក់កាលនៃការពិនិត្យ ទៅលើមូលហេតុ និងដំណាក់កាលវិនិច្ឆ័យទៅលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី។ ហេតុនេះ មិនមានភាព ងាយស្រួលឡើយ ហើយវាអាចមានលទ្ធភាព អូសបន្លាយនីតិវិធី ក៏ដូចជាបង្កឱ្យមានភាពច្របូកច្របល់ និង មានភាពស្មុគស្មាញជាងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់មួយចំនួន ដោយសារតែបណ្តឹងនេះវាត្រូវបាន អនុញ្ញាតឱ្យភាគីដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ទៅលើគ្រប់លំដាប់ថ្នាក់នៃតុលាការ ទាំងតុលាការ ជាន់ទាប និងជាន់ខ្ពស់ ដែលជាហេតុធ្វើឱ្យមានភាពច្របូកច្របល់ និងការកក់ស្ទះសំណុំរឿងនៅក្នុងតុលាការ។

– បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បើប្រៀបធៀបជាមួយបណ្តឹងឧបាស្រ័យផ្សេងៗបណ្តឹងនេះមិនសូវមាន ការពេញនិយមក្នុងការយកមកអនុវត្តឡើយ មានន័យថាតុលាការកម្រនឹងទទួលបាននូវពាក្យបណ្តឹងទាមទារ ឱ្យជំនុំជម្រះសាជាថ្មីមកវិនិច្ឆ័យណាស់ បើតាមតថភាពជាក់ស្តែងនៅក្នុងបរិបទសង្គម ដែលទាំងនេះអាចមកពី កត្តាចំណេះដឹងរបស់ប្រជាពលរដ្ឋដោយយល់ឃើញថានៅពេលសាលក្រម ឬសាលដីកាស្ថាពរហើយ ខ្លួននឹងអស់ សិទ្ធិក្នុងការប្តឹងតវ៉ា និងដោយរួមផ្សំជាមួយបញ្ហានៃការផ្សព្វផ្សាយពាក់ព័ន្ធនឹងច្បាប់នៅមានកម្រិតទាបផង។

– ដោយសារតែបទប្បញ្ញត្តិនៃគន្ថី៤ ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី២០០៦ នៃព្រះរាជាណាចក្រកម្ពុជាដែល ចែងអំពីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ប៉ុន្តែមានចំណុចខ្លះច្បាប់ចែងមិនបានច្បាស់លាស់ ក៏ដូចជានៅ មានភាពស្រពិចស្រពិល មិនមានភាពគ្រប់ជ្រុងជ្រោយ ម្យ៉ាងទៀត ដោយសារតែបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី នេះ មិនមានអត្ថបទ បទដ្ឋានគតិយុត្តណាផ្សេងដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ឬក៏សេចក្តីណែនាំដែល ចែងបន្ថែមទៅលើបញ្ហាអ្វីដែលច្បាប់បានខ្វះខាតនោះទេ ជាហេតុនាំឱ្យបណ្តឹងនេះពុំមានភាពទូលំទូលាយ ដែលនាំឱ្យមានភាពស្មុគស្មាញ ជាពិសេសតុលាការមានភាពលំបាកក្នុងការអនុវត្ត។

# អនុសាសន៍

# អនុសាសន៍

តាមការសិក្សាស្រាវជ្រាវប្រធានបទលើ ក្រុមយើងខ្ញុំយល់ឃើញថាបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានទាំងចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានជាច្រើន។ ក្នុងគោលបំណងឱ្យការអនុវត្តបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីកាន់តែមានភាពល្អប្រសើរ និងកែតម្រូវនូវចំណុចខ្វះខាត ក្រុមយើងខ្ញុំសូមផ្តល់ជាអនុសាសន៍ដូចខាងក្រោម៖

– ចំពោះក្រសួងយុត្តិធម៌ ក៏ដូចជាក្រសួងជំនាញពាក់ព័ន្ធនានា អង្គការក្រៅរដ្ឋាភិបាល គួរគប្បីយកចិត្តទុកដាក់ បង្កើតលិខិតបទដ្ឋានគតិយុត្តបន្ថែមដូចជា ច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ ឬសេចក្តីណែនាំបន្ថែមក្នុងការជំរុញឱ្យការដោះស្រាយរឿងក្តីនៅតុលាការកាន់តែមានភាពល្អប្រសើរដែលអាចគ្រប់គ្រង និងដោះស្រាយបញ្ហានានាដែលបានកើតឡើងគ្រប់ស្ថានភាព ជាពិសេសចេញសេចក្តីណែនាំដល់ស្ថាប័នតុលាការបន្ថែមនូវអ្វីដែលច្បាប់មិនមានចែង ឬចែងមិនមានភាពច្បាស់លាស់ ប្រកបដោយយុត្តិធម៌ពាក់ព័ន្ធជាមួយបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីបន្ថែម។ ម្យ៉ាងវិញទៀត ដោយសារតែបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីកម្រនឹងមានភាគីនៃបណ្តឹងលើកយកមកប្តឹងណាស់អាចមកពីកត្តាចំណេះដឹងរបស់ប្រជាពលរដ្ឋដែលយល់ឃើញថានៅដែលពេល សាលក្រមឬសាលដីកាចូលជាស្ថាពរហើយខ្លួនអស់សិទ្ធិក្នុងការប្តឹងតវ៉ា ដោយខ្លួនពុំបានទទួលព័ត៌មានពាក់ព័ន្ធផ្នែកច្បាប់ដោយហេតុថាការផ្សព្វផ្សាយពីច្បាប់នៅមានកម្រិត។ ដូច្នេះ ក្រសួងយុត្តិធម៌ ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗគួរយកចិត្តទុកដាក់ ជាពិសេសធ្វើការសហការណ៍ជាមួយនឹងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនក្នុងការផ្សព្វផ្សាយច្បាប់បន្ថែម និងបង្កើតឯកសារពាក់ព័ន្ធនឹងបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីឱ្យបានទូលំទូលាយ។

– ចំណែកឯស្ថាប័នតុលាការវិញ សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ដែលមានចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីរដ្ឋបាលតុលាការគ្រប់រូប គួរតែបំពេញការងារដោយស្មោះត្រង់ ម៉ឺងម៉ាត់ និងប្រកបដោយស្មារតី និងការបំពេញការងារប្រកបដោយភាពសុចរិត ក្នុងនាមប្រជាពលរដ្ឋខ្មែរគិតអំពីផលប្រយោជន៍រួម ហើយដោះស្រាយរឿងក្តីឱ្យបានល្អប្រកបដោយទំនួលខុសត្រូវខ្ពស់។ ពិសេសជាងនេះទៀត តុលាការត្រូវពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយទៅលើបញ្ហានៅក្នុងសំណុំរឿងដោយការយកចិត្តទុកដាក់ឱ្យបានហ្មត់ចត់មុននឹងចេញសាលក្រម ឬសាលដីកាដើម្បីជៀសវាងបញ្ហាការកើតមានឡើងនូវវិការៈនៃសាលក្រម ឬសាលដីកាដែលនាំឱ្យមានភាពស្មុគស្មាញដូចក្នុងប្រធានបទនេះ លើសពីនេះគឺមិនត្រូវធ្វើសកម្មភាពទាំងឡាយដែលនាំឱ្យអាប់ឱនដល់ស្ថាប័នតុលាការទាំងមូលឡើយ ហើយម្យ៉ាងវិញទៀតតុលាការត្រូវធ្វើយ៉ាងណាឱ្យមានភាពប្រសើរឡើងនូវការផ្តល់សេវាយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋឱ្យបានលឿន និងឆាប់រហ័សដែលនេះជាសញ្ញាណមួយក្នុងការរីកចម្រើនយ៉ាងឆាប់រហ័សរបស់វិស័យយុត្តិធម៌ទាំងមូល ហើយក៏ជាផ្នែកមួយនៃការរីកចម្រើនរបស់ប្រទេសជាតិផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ១.លិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម ០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧។
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧។
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆកា ឆ្នាំ២០០៩។
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង និងសេចក្តីកំណត់ចំពោះមាត្រានីមួយៗ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈនស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០។


## ២.សៀវភៅ


- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី,២០០៧,សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី,ភ្នំពេញ,ក្រសួងយុត្តិធម៌។
- ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា,២០០៨,នីតិវិធីបណ្តឹង,ភាគ១ នៃសេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី,ភ្នំពេញ,ក្រសួងយុត្តិធម៌។
- ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា,និងនាំមកសិក្សាដោយ អៀង សំអាង,២០២០,នីតិជាតិឯកជន នីតិវិធីរដ្ឋប្បវេណីអំពីការជំនុំជម្រះសាជាថ្មី,ក្រសួងយុត្តិធម៌។
- មេធាវី អ៊ីវ ប៉ូលី.នីតិវិធីរដ្ឋប្បវេណី (ឯកសារជំនួយស្មារតី)។
- បណ្ឌិត ហាប់ផល្លី,២០១៦,វិធីសាស្ត្រ និងការសរសេរបែបសិក្សា,ភ្នំពេញ,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ហ៊ី សោភា,នីតិវិធីរដ្ឋប្បវេណី,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។


## ៣.វចនានុក្រម

- សន្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី,ដែលត្រូវបានរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះពុម្ពផ្សាយដោយទីស្ដីការគណៈរដ្ឋមន្ត្រី,២០០៧។
- វចនានុក្រម សម្ដេចសង្ឃ ជួន ណាត

## ៤.ឯកសារធ្វើបទបង្ហាញ

- Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama.បញ្ហានានានៅក្នុងរឿងរដ្ឋប្បវេណី ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅ អំពីកិច្ចការច្បាប់នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ។ (ប្រភព Website https:www.jica.go.jp) ចូលមើលនៅថ្ងៃទី១៣ខែមករា ឆ្នាំ២០២៤។
- ឧទ្ទេសនាមដោយលោកមេធាវី អ៊ីវ ប៉ូលី ,សិក្ខាសាលា វិភាគទាន និងក្រុមមេធាវីសហប្រតិបត្តិការអន្តរជាតិ ស្ដីអំពីការជំនុំជម្រះសាជាថ្មី,អនុស្សរណៈនៃការយោគយល់រវាងវិភាគទានច្បាប់ និងក្រុមហ៊ុនមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ(ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៤)។
- ក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ វគ្គបណ្ដុះបណ្ដាលបន្តសម្រាប់ចៅក្រម និងក្រឡាបញ្ជីរាជធានីខេត្ត ស្ដីពីបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី (ខែវិច្ឆកា ឆ្នាំ២០០៦ ដល់ខែកុម្ភៈ ឆ្នាំ២០០៧)។

## ៥.Website

- www.khsearch.com ,ចូលមើលថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៤។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១. លំហូរនៃនីតិវិធីជំនុំជម្រះសាជាថ្មី**

**ឧបសម្ព័ន្ធទី២. នីតិវិធីមុនពេលមានបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី**

- សាលក្រមស្ថាពរ
- លិខិតបញ្ជាក់សាលក្រមស្ថាពរ

**ឧបសម្ព័ន្ធទី៣. នីតិវិធីមុនចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី**

- លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ
- បង្កាន់ដៃបង់ប្រាក់
- ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី
- ដីកាបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹង
- ពាក្យសុំកែតម្រូវកម្មវត្ថុពាក្យបណ្តឹង
- រាយការណ៍អំពីការបញ្ជូន
- ពាក្យសុំជូនភស្តុតាងពិនិត្យ

**ឧបសម្ព័ន្ធទី៤. ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី**

- របាយការណ៍ពីការបញ្ជូន
- កំណត់សម្គាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន

**ឧបសម្ព័ន្ធទី៥.ការច្រានចោលការទា**

**ឧបសម្ព័ន្ធទី៦.ការប្តឹងតវ៉ាចំពោះដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី**

- លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ
- លិខិតតំណាងដោយអាណត្តិ
- ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង
- ពាក្យបណ្តឹងជំទាស់
- សេចក្តីចម្លងបណ្តឹងជំទាស់

**ឧបសម្ព័ន្ធទី៧. ដីកាសម្រេចនៃតុលាការបណ្តឹងជំទាស់**

- ដីកាសម្រេច

**ឧបសម្ព័ន្ធទី៨. ដីកាកោះ**

# ឧបសម្ព័ន្ធទី១. លំហូរនៃនីតិវិធីជំនុំជម្រះសាជាថ្មី

【លំហូរនៃនីតិវិធីជំនុំជម្រះសាជាថ្មី】



# ឧបសម្ព័ន្ធទី២.

## នីតិវិធីមុនពេលមានបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

- សាលក្រមស្ថាពរ
- លិខិតបញ្ជាក់សាលក្រមស្ថាពរ

**សាលក្រមស្តាពរ**

1

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី
លេខ: : ចុះថ្ងៃទី

សាលក្រមរដ្ឋប្បវេណីលេខ
ព.រ.រ ចុះថ្ងៃ
ទី១៦ ខែតុលា ឆ្នាំ

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ០៨ ខែតុលា ឆ្នាំ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជំរះ**

លោក អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទឈ្មោះ ភេទប្រុស កើតឆ្នាំ នទីលំនៅផ្ទះលេខ ផ្លូវលេខ ០ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ (រ) មានកូន០២ នាក់ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) មុខរបរ លក់ដូរ ។

ដោយមានលោក ជាមេធាវីតំណាងដោយអាណត្តិ ។

និងចុងចម្លើយឈ្មោះ ភេទស្រី កើតឆ្នាំ មានទីលំនៅផ្ទះលេខ ( រាជធានីភ្នំពេញ ប្តីឈ្មោះ (រ) មានកូន០២នាក់ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) មុខរបរ មេផ្ទះ ។

**ដែលមានកម្មវត្ថុបណ្តឹង** : ប្តឹងសុំលែងលះប្រពន្ធឈ្មោះ ។

**អង្គហេតុ និង ចំណុចវិវាទ**

១ - **ការទាមទាររបស់គូភាគី** :

១-១: **ការទាមទាររបស់ដើមចោទ** :

ប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ ។

**១-២:ការទាមទាររបស់ចុងចម្លើយ** : គ្មាន ។

២- **ការពន្យល់ផ្សេងៗអំពីរឿងក្តី** :

២-១ : ដើមចោទឈ្មោះ បានប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ ។

ដោយហេតុថា : ការរស់នៅជាមួយគ្នាចេះតែមានរឿងរកាំរកុះឈ្លោះប្រកែកគ្នាជាញឹកញាប់ដែលជាហេតុធ្វើឱ្យអស់មនោសញ្ចេតនានឹងគ្នា ក្នុងការរស់នៅជាប្តីប្រពន្ធតទៅទៀត ទ្រព្យសម្បត្តិរួមគ្មាន,បំណុលរួមគ្មាន ។

ដើមចោទបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ ដោយមានលិខិតទទួលស្គាល់រៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ ហើយការរួមរស់នៅជាមួយគ្នាមានកូនពីរនាក់គឺ ឈ្មោះ ភេទប្រុស កើតថ្ងៃទី និង កូនឈ្មោះ ភេទស្រី កើតថ្ងៃទី ខែកក្កដា

ឆ្នាំ ។

២-២: ចំណុចវិវាទ :គ្មាន ។

២-៣: ចំណុចគ្មានវិវាទ : ដើមចោទប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ ។

២-៤: ការអះអាងរបស់គូភាគី :

ក/- ការអះអាងរបស់ដើមចោទ :

ដើមចោទឈ្មោះ ដែលមានលោក ជាមេធាវីតំណាងដោយអាណត្តិ បានធ្វើសេចក្តីថ្លែងការណ៍ថា : ខ្លួនប្តឹងសុំលែងលះពីប្រពន្ធឈ្មោះ ។

ដោយមូលហេតុ : ការរស់នៅមិនចុះសំរុងគ្នា បែកលំនៅសង្វាសអស់រយៈពេល៤ឆ្នាំមកហើយ សព្វថ្ងៃមិនដឹងចុងចម្លើយរស់នៅឯណាទេ នៅពេលរស់នៅជាមួយគ្នាកន្លងមកចេះតែមានរឿងរកាំរកុះឈ្លោះប្រកែកគ្នាជាញឹកញាប់ ធ្វើឱ្យអស់មនោសញ្ចេតនាមិនអាចទ្រាំរួមរស់ជាមួយគ្នាតទៅទៀតបាន ។

ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ នៅឆ្នាំ ដោយមានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ គឺលិខិតទទួលស្គាល់អាពាហ៍ពិពាហ៍លេខ (

ការរួមរស់ជាមួយគ្នាមានកូនពីរនាក់គឺឈ្មោះ ភេទប្រុស កើតថ្ងៃទី និងឈ្មោះ ភេទស្រី កើតថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ។

ចំពោះកូនពីរនាក់សុទ្ធជានីតិជន ការសំរេចចិត្តទៅរស់នៅជាមួយភាគីណាមួយនោះ គឺ ជាសិទ្ធិរបស់កូន ខ្លួនពុំមានអ្វីជំទាស់ទេ ។

ការរួមរស់ជាមួយគ្នាទ្រព្យសម្បត្តិរួម គ្មាន ,បំណុលរួម គ្មាន ផ្ទះដែលស្នាក់នៅសព្វថ្ងៃគឺជារបស់ប្រពន្ធខ្លួន ។

សំណូមពរ : សុំឱ្យតុលាការសំរេចទៅតាមច្បាប់ ។

ខ/- ការអះអាងរបស់ចុងចម្លើយ :

ចុងចម្លើយឈ្មោះ បានទទួលដំណឹងពីការកោះហៅរបស់តុលាការត្រឹមត្រូវតាមច្បាប់ហើយ តែឈ្មោះនេះអវត្តមានដោយគ្មានមូលហេតុ ចាត់ទុកថាបានយល់ព្រមតាមការប្តឹងសុំលែងលះរបស់ដើមចោទ តាមចំណុចទី២នៃមាត្រា២០១នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា :

១-ពាក្យបណ្តឹងចុះថ្ងៃទី របស់ឈ្មោះ ដែលមានលោក ជាមេធាវីតំណាងដោយអាណត្តិ តុលាការអាចលើកយកមកចាត់ការបានតាមបញ្ញត្តិមាត្រា ១០,២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-ដើមចោទ និង ចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់នៅឆ្នាំ ដោយមានលិខិតទទួលស្គាល់អាពាហ៍ពិពាហ៍លេខ របស់គណៈកម្មាធិការប្រជាជនបដិវត្តន៍ខណ្ឌទួលគោកប្រាកដមែន ។

៣-ការដែលគូភាគីបានចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះ គឺមានន័យថា គូភាគីមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។

ការប្តឹងសុំរបស់ដើមចោទឈ្មោះ ត្រង់ចំណុចសុំលែងលះពីប្រពន្ធឈ្មោះ មាន...

លក្ខណៈសមស្របតាមផ្លូវច្បាប់ គប្បីតុលាការពិនិត្យ និង សំរេចទៅតាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

៤-គូភាគីបានបែកលំនៅសង្វាសអស់រយៈពេលបួនឆ្នាំមកហើយ ដូច្នេះតុលាការពុំមានការហាមឃាត់ដល់គូភាគីក្នុងការរៀបអាពាហ៍ពិពាហ៍ថ្មីទៀតឡើយ ។

៥-ការរួមរស់ជាមួយគ្នាគូភាគីមានកូនពីរនាក់គឺ : ឈ្មោះ ភេទប្រុស កើតថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ និងឈ្មោះ ភេទស្រី កើតថ្ងៃទី២១ ខែកក្កដា ឆ្នាំ ហើយមកទល់ពេលនេះកូនៗទាំងពីរនាក់នោះសុទ្ធតែមានវ័យនីតិភាព ការសំរេចចិត្តទៅរស់នៅជាមួយភាគីណាមួយនោះគឺជាសិទ្ធិរបស់កូន ។

៦-ការរួមរស់ជាមួយគ្នាទ្រព្យសម្បត្តិរួមគ្មាន ,បំណុលរួមគ្មាន ចំណុចនេះតុលាការពុំគប្បីលើកយកមកធ្វើការពិចារណាឡើយ ។

៧-ដើមចោទសុខចិត្តទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

<u>សេចក្តីសំរេចបញ្ចាប់</u>

១/-អោយឈ្មោ និង ឈ្មោះ ដាច់សមគ្គសង្វាសពីគ្នាចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ តាមបញ្ញត្តិមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះបានទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៨ ខែ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ១៦ ខែ ។

ហត្ថលេខា និង ត្រា :

---

បានឃើញ
ចៅក្រមជំនុំជំរះ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែ
ក្រឡាបញ្ជី

**លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខៈ ............ រ.វ.ស្ថា

## លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រម

យើង ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា២៦៤នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីបណ្តឹងលេខ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ពាក្យសុំចុះថ្ងៃទី របស់ឈ្មោះ ភេទប្រុស អាយុ៥០ឆ្នាំ ជនជាតិខ្មែរ មុខរបរៈបុគ្គលិកបច្ចេកទេសធនធានទឹក ទីលំនៅបច្ចុប្បន្នផ្ទះលេខ ផ្លូវលេខ រាជធានីភ្នំពេញ ដែលមានខ្លឹមសារស្នើសុំបញ្ជាក់ការចូលស្ថាពរនៃ សាលក្រមរដ្ឋប្បវេណីលេខ របស់សាលាដំបូងរាជធានីភ្នំពេញ ។

### សូមបញ្ជាក់ថា

១/-សាលក្រមរដ្ឋប្បវេណីលេខៈ របស់សាលាដំបូងរាជធានីភ្នំពេញ បានចូលស្ថាពរចាប់ពីថ្ងៃទី រួចហើយ ។

២/-លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមរដ្ឋប្បវេណីនេះ ចេញអោយសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី

ក្រឡាបញ្ជី

## ឧបសម្ព័ន្ធទី៣. នីតិវិធីមុនចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

- លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ
- បង្កាន់ដៃបង់ប្រាក់
- ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី
- ដីកាបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹង
- របាយការណ៍អំពីការបញ្ជូន
- ពាក្យសុំកែតម្រូវកម្មវត្ថុពាក្យបណ្តឹង
- ពាក្យសុំជូនភស្តុតាងពិនិត្យ

# លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ

នាងខ្ញុំឈ្មោះ កាន់លិខិតឆ្លងដែនព្រះរាជាណាចក្រកម្ពុជាលេខ ចុះថ្ងៃទី ខែមីនា ឆ្នាំ មានអាសយដ្ឋានផ្ទះលេខ សង្កាត់ រាជធានីភ្នំពេញ (អាណត្តិទាយក)។

**សូមប្រគល់សិទ្ធិមេធាវីជូន**

ការិយាល័យមេធាវី មានមេធាវីទទួលបន្ទុកលោកមេធាវី អត្តលេខ ជាប្រធាន មានអាសយដ្ឋាន អគារអេលីហ្សេលេខ ផ្លូវកោះពេជ្រ សង្កាត់មន រាជធានីភ្នំពេញ ដើម្បីធ្វើជាមេធាវីតំណាងរបស់ខ្ញុំដូចខាងក្រោម៖

១. ធ្វើជាតំណាងក្នុងនីតិវិធីបណ្តឹងលែងលះ និងបែងចែកទ្រព្យសម្បត្តិជាមួយឈ្មោះ

២. ធ្វើជាតំណាងក្នុងនីតិវិធីប្តឹងឈ្មោះ និងភាគីពាក់ព័ន្ធក្នុងបទព្រហ្មទណ្ឌ និងការទាមទារសំណង

៣. សិទ្ធិទាក់ទងនឹងសកម្មភាពខាងលើរួមបញ្ចូលទាំងការដាក់ពាក្យបណ្តឹង ការឆ្លើយដោះសារចំពោះបណ្តឹង ការប្តឹងតប ការចូលរួមអន្តរាគមន៍បណ្តឹង ការប្តឹងទៅតុលាការជាន់ខ្ពស់ ការផ្សះផ្សា ការលះបង់ការទាមទារ ការទទួលស្គាល់នូវការទាមទារ ការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការជ្រើសតាំងអនុតំណាង និង ការទទួលនូវការសង។ លោកមេធាវីមានសិទ្ធិអនុវត្តការងារតំណាងនៅចំពោះមុខស្ថាប័នពាក់ព័ន្ធនានា និងនៅចំពោះមុខសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

រាល់ថ្លៃចំណាយនានាទាក់ទងនឹងសកម្មភាពបណ្តឹងទាំងរដ្ឋប្បវេណី និងព្រហ្មទណ្ឌ ជាបន្ទុក និងជាការទទួលខុសត្រូវដោយផ្ទាល់របស់ យើងខ្ញុំជាអាណត្តិទាយក។

លិខិតប្រគល់សិទ្ធិនេះ មានអានុភាពចាប់ពីពេលចុះហត្ថលេខា ឬផ្តិតស្នាមមេដៃ ខាងក្រោមនេះតទៅ។

ធ្វើនៅ ថ្ងៃទី ខែ
ស្នាមមេដៃ និង ហត្ថលេខា (Signature)

ឯកភាពចំពោះការប្រគល់សិទ្ធិជាមេធាវីតំណាង
ដោយអាណត្តិ

មេធាវី

# បង្កាន់ដៃបង់ប្រាក់



ក្រសួងយុត្តិធម៌

បង្កាន់ដៃបង់ប្រាក់

អង្គភាព.................................................

ទទួលពី.................................................

ចំនួនទឹកប្រាក់ជាលេខ.................................................

ជាអក្សរ.................................................

អត្ថន័យចំណូល.................................................មាតិកាថវិកា

ថ្ងៃទី.........ខែ.........ឆ្នាំ

អ្នកប្រមូលចំណូល

បង្កាន់ដៃនេះត្រូវបានបោះពុម្ព និងគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្របតាមអនុក្រឹត្យលេខ៨២អនក្រ. ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨

# ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

សាលាដំបូងរាជធានីភ្នំពេញ
ថ្ងៃទី

25

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹង**

**ដើមចោទ៖**

ឈ្មោះ ភេទស្រី អាយុ ឆ្នាំ កាន់លិខិតឆ្លងដែនព្រះរាជាណាចក្រកម្ពុជាលេខ
ចុះថ្ងៃទី បច្ចុប្បន្នកំពុងស្នាក់នៅព្យាបាលជំងឺនៅផ្ទះលេខ
សង្កាត់ បារាំង។

មេធាវីតំណាងដោយអាណត្តិ៖ **មេធាវី** អត្តលេខ ជាមេធាវីនៃ**ការិយាល័យមេធាវី** មានទីតាំងស្ថិតនៅអគារអេលីហ្សេលេខ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (កន្លែងទទួលការបញ្ជូន)។

**ចុងចម្លើយ៖**

ឈ្មោះ ភេទប្រុស អាយុ៥៦ ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ
អាសយដ្ឋានផ្ទះលេខ ......
ជ័យ រាជធានីភ្នំពេញ។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ៖</u>**

១. សម្រេចមោឃភាពសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

<u>អង្គហេតុដែលជាមូលហេតុនៃការទាមទារ៖</u>

ដើមចោទ និងចុងចម្លើយ ជាប្ដីប្រពន្ធស្របច្បាប់នឹងគ្នា ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍លេខ សៀវភៅលេខ និងមានកូនចំនួនពីរនាក់កូនប្រុសឈ្មោះ កើតថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ និងកូនស្រីឈ្មោះ កើតថ្ងៃទី ។

ក្រោយមកនៅខួងឆ្នាំ លោកស្រី ជាដើមចោទបានចាប់ផ្ដើមមានជំងឺ និង បានទៅសម្រាកព្យាបាលជំងឺនៅប្រទេសវៀតណាមជាបន្តបន្ទាប់។ ប៉ុន្តែដោយសភាពជំងឺរបស់ ដើមចោទ មានសភាពធ្ងន់ធ្ងរ ហើយពេទ្យនៅប្រទេសវៀតណាម និង កម្ពុជាមិនមានលទ្ធភាពព្យាបាលបាន សាច់ញ្ញាតិរបស់ដើមចោទដែលរស់នៅប្រទេសបារាំង បានជួយធានាដើមចោទទៅប្រទេសបារាំង ដើម្បីសម្រាកព្យាបាលជំងឺនៅឆ្នាំ ។

បន្ទាប់ពីខ្លួនបានទៅព្យាបាលនៅប្រទេសបារាំង ដើមចោទ មិនទាន់មានឱកាសត្រឡប់មកប្រទេសខ្មែរវិញនៅឡើយទេមកដល់ពេលនេះ ដោយស្ថានភាពជំងឺរបស់ដើមចោទមានសភាពធ្ងន់ធ្ងរទាមទារពិនិត្យតាមដានជាប្រចាំ ហើយអាចនឹងមានគ្រោះថ្នាក់បានគ្រប់ពេលដែលនៅឆ្ងាយពីពេទ្យ។

ក្នុងអំឡុងពេលនៃការរស់នៅជាមួយចុងចម្លើយ និង មុនពេលទៅព្យាបាលនៅប្រទេសបារាំង ដើមចោទ និង ចុងចម្លើយ មិនមានបញ្ហាឈ្លោះគ្នាទេ ប៉ុន្តែក្រោយពេលដែលដើមចោទ ទៅព្យាបាលជំងឺនៅប្រទេសបារាំង ចុងចម្លើយ មិនបានជួយទំនុកបំរុងផ្ញើប្រាក់ជូនដើមចោទដែលកំពុងតែឈឺធ្ងន់ឡើយ។

ក្រោយមកគឺនៅពេលដែលដើមចោទ បានដឹងថាចុងចម្លើយ បានរៀបការប្រពន្ធថ្មី ទើបដើមចោទមិនសុខចិត្តបានដាក់ពាក្យប្ដឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទើបដឹងថា សាលាដំបូងរាជធានីភ្នំពេញធ្លាប់បានចេញសាលក្រមលេខ សម្រេចឲ្យដើមចោទ និងចុងចម្លើយ លែងលះគ្នារួចហើយដោយអវត្តមានដើមចោទនៅពេលនោះ និងបានចូលជាស្ថារពររួចថែមទៀតផងដោយលិខិតបញ្ជាក់ចូលជាស្ថាពរនៃសាលក្រមចុះថ្ងៃទី ។

ដើមចោទមិនបានដឹងពីនីតិវិធីនៃចេញសាលក្រមដែលសម្រេចឲ្យខ្លួនលែងលះជាមួយប្ដីខ្លួននោះទេ និងមិនដែលទទួលបានព័ត៌មានពីសាលាដំបូងរាជធានីភ្នំពេញថែមទៀតផង។ សូម្បីតែចុងចម្លើយខ្លួនឯងក៏មិនដែលប្រាប់មកដើមចោទថាខ្លួនសុំលែងលះ ឬ ប្ដឹងលែងលះនោះទេ។ ប្រសិនបើដើមចោទបានដឹងពីការប្ដឹងលែងលះនេះ នោះខ្លួនអាចនឹងមានមធ្យោបាយការពារដើម្បីការពារផលប្រយោជន៍របស់ខ្លួនទៅតាមនីតិវិធីច្បាប់។ ក្នុងចំណុចនេះ ចុងចម្លើយមិនចង់ឲ្យដើមចោទដឹងព្រោះមិនចង់ឲ្យដើមចោទមានឱកាសដើម្បីទាមទារបែងចែកទ្រព្យសម្បត្តិរួម។

យោងតាមមាត្រា២០២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងថា *"បើមានករណីណាមួយដូចខាងក្រោមនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខបានឡើយ៖ ក-ភាគីដែលមិនបានបង្ហាញខ្លួន មិនបានទទួលការកោះហៅស្របច្បាប់។"*

ដូច្នេះបើយោងតាមមាត្រា២០២ ខាងលើ ការចេញសាលក្រមលេខ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ មានលក្ខណៈផ្ទុយច្បាប់ពីព្រោះដើមចោទមិនបានទទួលការកោះហៅស្របច្បាប់នោះទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ដើមចោទសូមឲ្យតុលាការសម្រេចមោឃភាពសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ចោលពីព្រោះនីតិវិធីនៃការចេញសាលក្រមនេះមានលក្ខណៈផ្ទុយច្បាប់ និង ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ដើមចោទយ៉ាងធ្ងន់ធ្ងរ ដូចជាមិនបានធ្វើការបែងចែកនូវទ្រព្យរួមដែលខ្លួនខំរកក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ជាដើម។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ

មេធាវី

មេធាវីតំណាងដោយអាណត្តិឲ្យ

# ដីកាបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ: ... រ.រ

## ដីកាសម្រេច

## បង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្តឹង

យើង ... ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញ មាត្រា៧៥ , ៧៨ និងមាត្រាផ្សេងៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីនៃបណ្តឹងពិសេសលេខ: ... របស់សាលាដំបូងរាជធានីភ្នំពេញ ។

**ដើមចោទឈ្មោះ** ... ភេទស្រី អាយុ ... ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នកំពុងស្នាក់នៅព្យាបាលផ្ទះលេខ ... ក្រុង ... ប្រទេស ... ។

**មេធាវីតំណាងដោយអាណត្តិ ឈ្មោះ** ... អត្តលេខឈ្មោះ ... ។

ចុងចម្លើយឈ្មោះ ... ភេទប្រុស អាយុ ... ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅ(ឃ្លាំងលក់ ... ) ផ្លូវលេខ ... សង្កាត់ ... ខណ្ឌ ... រាជធានីភ្នំពេញ ។

កម្មវត្ថុបណ្តឹង៖ សម្រេចមោឃភាពសាលក្រមរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ។

## សំអាងហេតុ

តាមពាក្យបណ្តឹងចុះថ្ងៃទី ... ខែ ... ឆ្នាំ ... របស់ដើមចោទពុំមានលក្ខណៈត្រឹមត្រូវ តាមមាត្រា៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីឡើយ ហេតុនេះតុលាការគប្បីបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាត ដោយយោងតាមមាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យដើមចោទឈ្មោះ ... ភេទស្រី អាយុ ... ឆ្នាំ ដោយមានលោកមេធាវី ... ជាអ្នកតំណាងដោយអាណត្តិ ធ្វើការកែតម្រូវចំណុចខ្វះខាត នៃពាក្យបណ្តឹងចុះថ្ងៃទី ... ក្នុងរយៈពេលពីរសប្តាហ៍គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងពីដីកាសម្រេចនេះ ។

ថ្ងៃ ... ខែ ... ឆ្នាំ ... ព.ស ......

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ...

ចៅក្រម

# វាយការណ៍អំពីការបញ្ជូន

សាលាដំបូងរាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## វាយការណ៍អំពីការបញ្ជូន

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

កាលបរិច្ឆេទផ្ញើចេញ : ថ្ងៃទី...២៤...ខែ..........ឆ្នាំ..........
លេខសំណុំរឿង : .......ថ្ងៃទី...២៥...ខែ..........ឆ្នាំ..........
ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : ..........
..........
ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : លោក : មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនសាលាដំបូងរាជធានីភ្នំពេញ
អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សាលាដំបូងរាជធានីភ្នំពេញ
ឈ្មោះជនដែលត្រូវទទួលការបញ្ជូន : ..........

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កញ្ញាពិរុទ្ធលើណី អាជ្ញាសាលា ឬ ក្រឡាបញ្ជី)

ទីកន្លែងដែលបានធ្វើការបញ្ជូន : (..........)
ផ្ទះលេខ..........ផ្លូវលេខ..........ភូមិ..........ក្រុម..........សង្កាត់..........
ខណ្ឌ..........រាជធានីភ្នំពេញ។

កាលបរិច្ឆេទនៃការបញ្ជូន :
ថ្ងៃទី...២១...ខែ..........ឆ្នាំ..........វេលាម៉ោង..........ព្រឹក/រសៀល

**វិធីជាក់ស្តែងក្នុងការបញ្ជូន**

☐១ បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ
☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះជននោះមិនចេះអក្សរ

☑២ បានបានគល់ឯកសារទៅឱ្យអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃនៅទីកន្លែងដែលត្រូវបញ្ជូននោះទេ
☐ អ្នកបំរើ ☑ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ
ឈ្មោះ..........

☐៣ ឯកសារត្រូវបានទុកនៅកន្លែងដែលត្រូវធ្វើការបញ្ជូនដោយហេតុថាបុគ្គលខាងក្រោមនេះមិនទទួលការបញ្ជូនដោយគ្មានហេតុផល
☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ ☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ
ឈ្មោះ..........

☑ ខ្ញុំបានបញ្ជូនឯកសារតាមនីតិវិធីខាងលើ

☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើបានសំរេចទេ ពីព្រោះនៅកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបទេ ដែលត្រូវទទួលការបញ្ជូន ឬ ជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ

កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃ..........ខែ..........ឆ្នាំ..........ព.ស២
ត្រូវនឹងថ្ងៃទី...២១...ខែ..........ឆ្នាំ

ហត្ថលេខា ឬ ស្នាមម្រាមដៃអ្នកទទួលជាក់ស្តែង

ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍

# ពាក្យសុំកែតម្រូវកម្មវត្ថុបណ្ដឹង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំកែតម្រូវកម្មវត្ថុបណ្ដឹង**

ខ្ញុំបាទមេធាវី អត្តលេខ ជាមេធាវីនៃការិយាល័យមេធាវី មានអាសយដ្ឋានស្ថិតនៅអាគារ សង្កាត់ផ្សារ រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឱ្យលោកស្រី ។

**សូមគោរពជូន**

**ចៅក្រម ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ ៖** សុំកែតម្រូវកម្មវត្ថុបណ្ដឹងរដ្ឋប្បវេណីចុះថ្ងៃទី ត្រង់ចំណុចទី១ ។

**យោង ៖** -សំណុំរឿងរដ្ឋប្បវេណីលេខ៖ របស់សាលាដំបូងរាជធានីភ្នំពេញ

-ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតចំពោះពាក្យបណ្ដឹងលេខ៖ ខែមករា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមធ្វើការកែតម្រូវកម្មវត្ថុបណ្ដឹងចុះថ្ងៃទី ខែ ឆ្នាំ ត្រង់ចំណុចទី១ ពីការប្ដឹងទាមទារ៖ ១.សម្រេចមោឃភាពសាលក្រមរដ្ឋប្បវេណីលេខ ព.រ.វ ចុះថ្ងៃទី របស់សាលាដំបូងរាជធានីភ្នំពេញ មកជា ជំនុំជម្រះសារជាថ្មីលើសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញវិញ។ ចំពោះចំណុចទាមទារផ្សេងទៀតនៃកម្មវត្ថុបណ្ដឹងសូមរក្សានៅដដែល។

អាស្រ័យហេតុនេះ សូមលោកចៅក្រម មេត្តាអនុញ្ញាតទៅតាមការស្នើសុំដោយក្ដីអនុគ្រោះ ។

សូមលោកចៅក្រម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែមីនា ឆ្នាំ

**មេធាវី**

តំណាងដោយអាណត្តិឲ្យ

# ពាក្យសុំជូនភស្តុតាងពិនិត្យ

## ពាក្យសុំជូនភស្តុតាងពិនិត្យ

ខ្ញុំបាទមេធាវី អត្តលេខ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យមេធាវីឈ្មោះ អាគារអេលីហ្សេជាន់ទីបី ផ្លូវ ការមេន រាជធានីភ្នំពេញទូរស័ព្ទលេខ ជាមេធាវីការពារក្តីឱ្យឈ្មោះ

**សូមគោរពជូន**

**លោកស្រី ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

កម្មវត្ថុៈ សុំជូនភស្តុតាងពិនិត្យ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

យោងៈ សំណុំរឿងរដ្ឋប្បវេណីលេខៈ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសុំជូនភស្តុតាងដើម្បីពិនិត្យដូចខាងក្រោមៈ

**ភស្តុតាងជាឯកសារបកប្រែមកភាសាខ្មែរពីឯកសារដើមជាភាសាបារាំងៈ**

(១) លិខិតបញ្ជាក់ការព្យាបាល ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ

(២) លិខិតបញ្ជាក់ការព្យាបាល ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ

(៣) លិខិតបញ្ជាក់ការព្យាបាល ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ

(៤) លិខិតបញ្ជាក់ការតាមដានសុខភាព ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ

(៥) លិខិតបញ្ជាក់ការព្យាបាល ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ

(៦) លិខិតបញ្ជាក់ការការត្រួតពិនិត្យសុខភាព ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ

(៧) លិខិតបញ្ជាក់ការតាមដានសុខភាព ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ

(៨) លិខិតបញ្ជាក់ការព្យាបាល ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ

(៩) របាយការណ៍ពិនិត្យជំងឺ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ

(១០) លិខិតលិខិតពេទ្យ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ

ការពន្យល់អំពីភស្តុតាងៈ

តាមលិខិតបញ្ជាក់របស់វេជ្ជបណ្ឌិត និងពីមន្ទីរពេទ្យខាងលើ លោកស្រី បានទៅសម្រាក់ព្យាបាលជំងឺនៅមន្ទីរពេទ្យប្រទេសបារាំង តាំងពីដើមខែសីហា ឆ្នាំ រកម្លេះ។ វេជ្ជបណ្ឌិត បានតម្រូវឲ្យលោកស្រីបន្តព្យាបាលយ៉ាងទៀងទាត់ និងស្នាក់នៅតំបន់ក្បែរនឹងមន្ទីរពេទ្យ និងមិនអាចទៅណាឆ្ងាយបានទេ ដែលជាហេតុធ្វើឲ្យលោកស្រី មិនមានឱកាសមកប្រទេសកម្ពុជាវិញបាននៅឡើយ។

សូមលោកស្រីចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ

**មេធាវី**

# ឧបសម្ព័ន្ធទី៤.

- ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី
- ដីកាសម្រេចច្រាលចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី
- របាយការណ៍អំពីការបញ្ជូន
- កំណត់សម្គាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន

# ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ:..

ចុះថ្ងៃទី១៧..ខែ

## ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

យើង ចៅក្រមសាលាដំបូង រាជធានីភ្នំពេញ

-បានឃើញ មាត្រា ៣០៧ ,៣០៨ និងមាត្រា៣១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីនៃបណ្តឹងពិសេសលេខ: ចុះថ្ងៃទី ខែតុលា ឆ្នាំ ។

-បានឃើញ សាលក្រមលេខ ចុះថ្ងៃទី ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ពាក្យបណ្តឹងចុះថ្ងៃទី របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ ។

-បានឃើញ ពាក្យសុំកែតម្រូវកម្មវត្ថុបណ្តឹង ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ ។

-បានឃើញ ពាក្យសុំកែតម្រូវកម្មវត្ថុបណ្តឹងមកជំនុំជម្រះសារជាថ្មី ចុះថ្ងៃទី របស់មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ ។

រវាងដើមចោទឈ្មោះ ភេទស្រី ជនជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ សង្កាត់ ។

មេធាវីតំណាងដោយអាណត្តិឈ្មោះ ។

ចុងចម្លើយឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ (ឃ្លាំង ) រាជធានីភ្នំពេញ ។

ដែលមានកម្មវត្ថុបណ្តឹង:សុំជំនុំជម្រះសារជាថ្មីលើសាលក្រមរដ្ឋប្បវេណីលេខ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានី ភ្នំពេញ ,

### សំអាងហេតុ

-កាលពីថ្ងៃទី ចុងចម្លើយឈ្មោះ បានដាក់ពាក្យបណ្តឹងសុំលែងលះពីដើមចោទឈ្មោះ៖ ដែលមានសំណុំរឿងរដ្ឋប្បវេណីលេខ របស់សាលាដំបូងរាជ

ធានីភ្នំពេញ។ ក្រោយមកតុលាការបានចេញសាលក្រមរដ្ឋប្បវេណីលេខ ឆ្នាំ

តាមការអះអាងរបស់ចុងចម្លើយថា ការរស់នៅជាមួយគ្នាចេះ តែមានរឿងរកាំរកូស ឈ្លោះប្រកែកគ្នា ជាញឹកញ៉ាប់ ដែលជាហេតុធ្វើឱ្យអស់មនោសញ្ចេតនានឹងគ្នាតទៅទៀត ក្នុងការរស់ជាប្តី ប្រពន្ធ គ្មានទ្រព្យរួម គ្មានបំណុលរួម ប៉ុន្តែ មិនបានសម្រេរអំពីការបែងចែកទ្រព្យសម្បត្តិរួមរបស់គូភាគីឡើយ។

-តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ បានអះអាងថាខ្លួនទើបតែទទួលបានដំណឹងពីសាលក្រមនេះ នៅពេលដែលខ្លួនបានដាក់ពាក្យបណ្តឹងមកអយ្យការពេលដឹងថាចុងចម្លើយបានរៀបការជាមួយប្រពន្ធថ្មី ហើយនៅក្នុងសាលក្រមនោះមិនមានការបែងចែកទ្រព្យសម្បត្តិរួមឡើយ ។

-ទ្រព្យសម្បត្តិរួមដែលដើមចោទបានប្តឹងទាមទារជំនុំជម្រះសារជាថ្មីនោះមានដីទំហំ ម៉ែត្រការ៉េ មានក្បាលដីលេខ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ
មានទីតាំងស្ថិតនៅភូមិ រាជធានីភ្នំពេញ ។

-តាមមាត្រា៣០៧ កឋាខណ្ឌ១ វាក្យខណ្ឌ(ឈ) នៃក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ជាក់យ៉ាងច្បាស់ចំពោះការភ្លេចបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់ដែលអាចមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា ជាមូលហេតុនៃការជំនុំជម្រះសារជាថ្មី។

-ការដាក់ពាក្យបណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មីរបស់ឈ្មោះ មិនប៉ះពាល់ដល់នីតិវិធីរបស់តុលាការឡើយ ដើម្បីកុំឱ្យខូចផលប្រយោជន៍របស់ដើមចោទ គប្បីតុលាការសម្រេចទទួលយកពាក្យបណ្តឹងដាក់ជំនុំជម្រះសារជាថ្មីបាន ។

<u>**ហេតុដូច្នេះសម្រេច**</u>

១/ទទួលពាក្យបណ្តឹងទាមទារឲ្យជំនុំជម្រះសារជាថ្មីចុះថ្ងៃទី របស់ឈ្មោះ ។

២/ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ។

ថ្ងៃ. ......ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស

រាជធានីភ្នំពេញ ថ្ងៃទី

ចៅក្រម

ដីកាសម្រេចប្រានចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

78

(47)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងក្រុងភ្នំពេញ

លេខ :....................

## ដីកាសម្រេចប្រានចោលបណ្ដឹងទាមទារ
## ឱ្យជំនុំជំរះសាជាថ្មី

យើង........................................... ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជំរះ នៃសាលាដំបូងក្រុងភ្នំពេញ

បានឃើញមាត្រា៣១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/ រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ................. ចុះថ្ងៃទី......... ខែ............ឆ្នាំ......... របស់សាលាដំបូងក្រុងភ្នំពេញ។

បានឃើញសាលក្រមលេខ...................... ចុះថ្ងៃទី........ ខែ................ ឆ្នាំ............

បានឃើញពាក្យសុំ ចុះថ្ងៃទី......... ខែ................ ឆ្នាំ.......... របស់ឈ្មោះ......................

### សំអាងហេតុ

..........................................................................................................................

..........................................................................................................................

..........................................................................................................................

### ហេតុដូច្នេះសម្រេច

ប្រានចោលបណ្ដឹងទាមទារឱ្យជំនុំជំរះសាជាថ្មី ចុះថ្ងៃទី........ ខែ...................... ឆ្នាំ.................. របស់ឈ្មោះ......................................

ធ្វើនៅក្រុងភ្នំពេញ, ថ្ងៃទី.......... ខែ............ឆ្នាំ...........

ចៅក្រម, ក្រុមប្រឹក្សាជំនុំជំរះ

**របាយការណ៍អំពីការបញ្ជូន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

**របាយការណ៍អំពីការបញ្ជូន**

ប្រអប់ខាងក្រោមត្រូវបំពេញដោយក្រឡាបញ្ជី

កាលបរិច្ឆេទផ្ញើចេញ : ថ្ងៃទី..........១៧..........ខែ..........ឧសភា..........ឆ្នាំ. ..........

លេខសំណុំរឿង : .......... ..........ថ្ងៃទី.....២៧.....ខែ.....តុលា.....ឆ្នាំ ..........

ឈ្មោះឯកសារដែលត្រូវបានបញ្ជូន : [illegible] ....

......[illegible]......

ឈ្មោះអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : លោក មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនសាលាដំបូងរាជធានីភ្នំពេញ

អាសយដ្ឋានអ្នកទទួលបន្ទុកកិច្ចការបញ្ជូន : សាលាដំបូងរាជធានីភ្នំពេញ

ឈ្មោះជនដែលត្រូវទទួលការបញ្ជូន : ..........

ប្រអប់ខាងក្រោមត្រូវបំពេញដោយអ្នកប្រតិបត្តិការបញ្ជូន (កត្តាប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី)

ទីកន្លែងដែលបានធ្វើការបញ្ជូន : ([illegible])

ផ្ទះលេខ..........ផ្លូវលេខ..........ភូមិ..........ក្រុម..........សង្កាត់..........

ខណ្ឌ..........រាជធានីភ្នំពេញ។

កាលបរិច្ឆេទនៃការបញ្ជូន :

ថ្ងៃទី.....[illegible].....ខែ.....[illegible].....ឆ្នាំ ..........វេលាម៉ោង.....[illegible].....ព្រឹក/រសៀល

**វិធីជាក់ស្តែងក្នុងការបញ្ជូន**

☐ ១ បានប្រគល់ជូនជនដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃ

☐ ខ្ញុំបានពន្យល់ជូនជនដែលត្រូវទទួលការបញ្ជូននូវខ្លឹមសារសង្ខេបនៃឯកសារដែលបានបញ្ជូនពីព្រោះជននោះមិនចេះអក្សរ

☑ ២ បានបានគល់ឯកសារទៅឱ្យអ្នកដែលមានការយល់ដឹងសមរម្យចំពោះការទទួលឯកសារនេះ
ពីព្រោះខ្ញុំមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនដោយផ្ទាល់ដៃនៅទីកន្លែងដែលត្រូវបញ្ជូននោះទេ

☐ អ្នកបំរើ ☑ អ្នកផ្សេងដែលធ្វើការនៅទីនោះ ☐ អ្នកនៅជាមួយ

ឈ្មោះ..........

☐ ៣ ឯកសារត្រូវបានទុកនៅកន្លែងដែលត្រូវធ្វើការបញ្ជូនដោយហេតុថាបុគ្គលខាងក្រោមនេះមិនទទួលការបញ្ជូនដោយគ្មានហេតុផល

☐ ជនដែលត្រូវទទួលការបញ្ជូន ☐ អ្នកបំរើ ☐ អ្នកនៅជាមួយ ☐ អ្នកផ្សេងដែលធ្វើការនៅទីនោះ

ឈ្មោះ..........

☑ ខ្ញុំបានបញ្ជូនឯកសារតាមនីតិវិធីខាងលើ

☐ ខ្ញុំមិនអាចធ្វើការបញ្ជូនឯកសារខាងលើបានសំរេចទេ ពីព្រោះនៅកន្លែងដែលត្រូវបញ្ជូនខ្ញុំមិនបានជួបទេ ដែលត្រូវទទួលការបញ្ជូន ឬ ជនដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ

កាលបរិច្ឆេទធ្វើរបាយការណ៍ : ថ្ងៃ[illegible]ខែ.....[illegible].....ឆ្នាំ.....[illegible].....ព.ស
ត្រូវនឹងថ្ងៃទី.....[illegible].....ខែ.....[illegible].....ឆ្នាំ.

ហត្ថលេខា ឬ ស្នាមមេដៃអ្នកទទួលជាក់ស្តែង ឈ្មោះ និងហត្ថលេខាអ្នកធ្វើរបាយការណ៍

[illegible]

# កំណត់សម្គាល់សម្រាប់អ្នកប្រតិបត្តិការបញ្ជូន

## កំណត់សំគាល់សំរាប់អ្នកប្រតិបត្តិការបញ្ជូន

១- ប្រសិបបើជនដែលទទួលឯកសារជាក់ស្តែង (ជនដែលត្រូវទទួលការបញ្ជូន ឬ បុគ្គលផ្សេង) មិនចេះអក្សរ ឬចុះហត្ថលេខា ឬមិនអាចផ្តិតម្រាមដៃបានទេ អ្នកប្រតិបត្តិការបញ្ជូនត្រូវចុះនិទ្ទេសពីការនោះនៅកន្លែង "ហត្ថលេខា ឬស្នាមម្រាមដៃអ្នកទទួលឯកសារជាក់ស្តែង"។

២-ទីកន្លែងដែលបានធ្វើការបញ្ជូន "ត្រូវសរសេរឱ្យបានច្បាស់ៗ និងត្រឹមត្រូវ"។

៣-ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចទី១ អ្នកបញ្ជូនត្រូវគូស ☑ ហើយប្រសិនបើបានពន្យល់ជូនអំពីខ្លឹមសារសង្ខេបត្រូវគូស ☑ នៅក្នុងប្រអប់ដែរ។ ប្រសិនបើការបញ្ជូនបានធ្វើឡើងតាមចំណុចលេខ២ ឬលេខ៣ អ្នកបញ្ជូនត្រូវគូស ☑ នៅក្នុងប្រអប់លេខ២ ឬលេខ៣ នោះ ហើយត្រូវបញ្ជាក់បុគ្គលទទួលដោយគូស ☑ នៅក្នុងប្រអប់កំណត់បុគ្គលទទួលនោះ និងសរសេរឈ្មោះ

## ឧបសម្ព័ន្ធទី៥.ការប្តឹងទំទាស់ចំពោះដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី

- លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ
- លិខិតតំណាងដោយអាណត្តិ
- ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង
- ពាក្យបណ្តឹងជំទាស់
- សេចក្តីចម្លងបណ្តឹងជំទាស់

លិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**លិខិតប្រគល់សិទ្ធិ**
**ជាមេធាវីតំណាងដោយអាណត្តិ**

**អ្នកប្រគល់សិទ្ធិ៖** ខ្ញុំបាទឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅភូមិ

រាជធានីភ្នំពេញ ។

**សូមធ្វើការប្រគល់សិទ្ធិ ជាមេធាវីតំណាងដោយអាណត្តិជូនទៅ**

លោកមេធាវី អត្តលេខ៖ ជាសមាជិកគណៈមេធាវីកម្ពុជា និងជាប្រធាន មាន ការិយាល័យស្ថិតនៅផ្ទះលេខ៖ រាជធានីភ្នំពេញ ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិអោយខ្ញុំបាទនៅក្នុងសំណុំរឿង...រដ្ឋប្បវេណី.....លេខ៖... ... ចុះថ្ងៃទី២៧..... ខែ..តុលា... ឆ្នាំ របស់...សាលាដំបូងរាជធានីភ្នំពេញ........។

ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ លោកមេធាវី នឹងទទួលសិទ្ធដាក់ពាក្យសុំ ពាក្យបណ្តឹង ពាក្យបណ្តឹងតប ធ្វើការចរចា ការផ្សះផ្សា ទទួលស្គាល់ការទាមទារ ការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការលះបង់ការទាមទារ ការប្តឹងតវ៉ា ការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ បង្កើតឯកសារចាំបាច់ ចុះហត្ថលេខាលើសំណុំរឿងដាក់ ឬ ដកសំណុំឯកសារណាមួយ និងគ្រប់សកម្មភាពចាំបាច់សម្រាប់ការការពារក្តី ដោយគោរពផលប្រយោជន៍ស្របច្បាប់ និងមានសិទ្ធិតំណាងដោះស្រាយបញ្ហានេះជាមួយអាជ្ញាធរ និងតុលាការគ្រប់ជាន់ថ្នាក់។

លិខិតប្រគល់សិទ្ធិនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ ។

ថ្ងៃ.អង្គារ...៨កើត. ខែ...ផល្គុន... ឆ្នាំខាល ចត្វាស័ក ព.ស

រាជធានីភ្នំពេញ, ថ្ងៃទី..០៧... ខែ ឆ្នាំ

**បានទទួល និងយល់ព្រម**

ធ្វើជាមេធាវីតំណាងឲ្យឈ្មោះ តាមនីតិវិធីច្បាប់។

ថ្ងៃ. ឆ្នាំខាល ចត្វាស័ក

រាជធានីភ្នំពេញ, ថ្ងៃទី..០៧.. ខែ.មីនា.. ឆ្នាំ

**ហត្ថលេខា-ត្រាមេធាវី**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**មេធាវី**

**ស្នាមមេដៃស្តាំ/ហត្ថលេខា**
**អ្នកប្រគល់សិទ្ធិ**

លិខិតតំណាងដោយអាណត្តិ

ជាតិ សាសនា ព្រះមហាក្សត្រ

**<u>លិខិតតំណាងដោយអាណត្តិ</u>**

ខ្ញុំមេធាវី ជាសមាជិកគណៈមេធាវីកម្ពុជា និងជាប្រធាន មាន

ការិយាល័យស្ថិតនៅផ្ទះលេខ៖ រាជធានីភ្នំពេញ ។

ទូរស័ព្ទទំនាក់ទំនងលេខៈ ។

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*<u>សូមទានជ្រាប!</u>*

**<u>កម្មវត្ថុ:</u>** ស្តីពីការតំណាងដោយអាណត្តិឲ្យឈ្មោះ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីនៃបណ្តឹងពិសេសលេខៈ របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>យោង:</u>**
- មាត្រា២ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថាៈ ឈ្មោះ បានប្រគល់សិទ្ធិឲ្យខ្ញុំបាទ ធ្វើជាមេធាវីតំណាងដោយអាណត្តិ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីដូចមានចែងក្នុងកម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលយកនូវការគោរពរាប់អាន អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស

រាជធានីភ្នំពេញ, ថ្ងៃទី

**ហត្ថលេខា និង ត្រា**

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**មេធាវី**

# ពាក្យសុំពិនិត្យ និងថតចម្លងសំណុំរឿង

ព្រះរាជាណាចក្រកម្ពុជា
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំពិនិត្យ និងថតចម្លងសំណុំរឿង

ខ្ញុំមេធាវី អត្តលេខៈ ជាសមាជិកគណៈមេធាវីកម្ពុជា និងជាប្រធាន មាន
ការិយាល័យស្ថិតនៅផ្ទះលេខៈ រាជធានីភ្នំពេញ
ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីនៃបណ្តឹងពិសេសលេខ
ចុះថ្ងៃទី របស់សាលាដំបូងខេត្តកណ្តាល។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*សូមមានជ្រាប!*

**កម្មវត្ថុ:** ស្នើសុំពិនិត្យ និងថតចម្លងសំណុំរឿងរដ្ឋប្បវេណីនៃបណ្តឹងពិសេសលេខ: ខែ
តុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង:** - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ឆ្នាំ
។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមការអនុញ្ញាតអំពី **ឯកឧត្តមប្រធាន** ធ្វើការពិនិត្យ និងថតចម្លងសំណុំរឿងដូចបានជម្រាបជូនខាងលើ ដើម្បីឲ្យខ្ញុំបាទ មានលទ្ធភាពបានសិក្សាស្រាវជ្រាវ ការពារផលប្រយោជន៍ស្របច្បាប់ឲ្យកូនក្តីខ្ញុំបាទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាតតាមការស្នើសុំដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រ អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ៨កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស
រាជធានីភ្នំពេញ, ថ្ងៃទី

**ហត្ថលេខា និង ត្រា**

មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី

# ពាក្យបណ្ដឹងជំទាស់

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្ដឹងជំទាស់**

ខ្ញុំមេធាវី អត្តលេខ៖ ជាសមាជិកគណៈមេធាវីកម្ពុជា និងជាប្រធាន មាន

ការិយាល័យស្ថិតនៅផ្ទះលេខ៖ រាជធានីភ្នំពេញ ជាមេធាវី

ការពារដោយអាណត្តិឲ្យលោក ។

សាលាដំបូងរាជធានីភ្នំពេញ
ថ្ងៃទី...10...

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ
លេខ
ថ្ងៃទី
ម៉ោង

**កម្មវត្ថុ:** ប្ដឹងជំទាស់នឹងដីកាសម្រេចចាប់ផ្ដើបជំនុំជម្រះសាជាថ្មីលេខ: .រ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**យោង:** -សំណុំរឿងរដ្ឋប្បវេណីនៃបណ្ដឹងពិសេសលេខ: :ថ្ងៃទី២៧ ខែតុលា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមលេខ: របស់សាលាដំបូងរាជធានីភ្នំពេញ។

-លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលក្រមលេខ: របស់សាលាដំបូងរាជធានីភ្នំពេញ។

-ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មីលេខ: របស់សាលាដំបូងរាជធានីភ្នំពេញ ។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ។

-លិខិតធានាអះអាងអំពីប្រភេទទ្រព្យ របស់ឈ្មោះ ទទួលស្គាល់ដោយចៅសង្កាត់ឃ្មួញ។

-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: កាលពីថ្ងៃទី សាលាដំបូងរាជធានីភ្នំពេញបានចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មីលេខ: រ ដោយសម្រេចទទួលយកពាក្យបណ្ដឹងជំនុំជម្រះសារជាថ្មីរបស់ឈ្មោះ ដែលបានប្ដឹងទាមទារជំនុំជម្រះសាជាថ្មីដោយស្នើសុំបែងចែកទ្រព្យរួមដីមួយកន្លែងដែលមានទំហំ ការ៉េ) ក្បាលដីលេខ: មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ: ចុះថ្ងៃទី០១ ខែ មានទីតាំងស្ថិតនៅភូមិ រាជធានីភ្នំពេញ ។ ការដែលសាលា

ដំបូងរាជធានីភ្នំពេញចេញដីកាសម្រេចទទួលយកពាក្យបណ្តឹងជំនុំជម្រះសាជាថ្មីបែបនេះគឺពិតជាពុំមានយុត្តិធម៌ សម្រាប់កូនក្តីរបស់ខ្ញុំឡើយ ហើយព្រមទាំងប៉ះពាល់យ៉ាងធ្ងរធ្ងន់ដល់ប្រយោជន៍កូនក្តីរបស់ខ្ញុំផងដែរ។

ចំពោះដីដែលដែលមានទំហំ ម៉ែត្រការ៉េ) មានក្បាលដីលេខៈ

មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខៈ

គឺមិនជាប់ពាក់ព័ន្ធជាមួយឈ្មោះ នោះទេ ដោយក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុបានបញ្ជាក់យ៉ាងច្បាស់ថា ជាទ្រព្យខាងប្តី ដែលជាកម្មសិទ្ធិរបស់កូនក្តីខ្ញុំតែម្នាក់ឯងគត់។ សូម្បីនៅក្នុងសាលក្រមរដ្ឋប្បវេណីលេខៈ ត្រង់ចំណុច៦ នៃសំអាងហេតុក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរថាការរួមរស់ជាមួយគ្នាទ្រព្យសម្បត្តិរួមគ្មាន, បំណុលរួមគ្មាន ចំណុចនេះតុលាការពុំគប្បីលើកយកមកធ្វើការពិចារណាឡើយ។ មួយវិញទៀត ឈ្មោះ ក៏បានផ្តិតមេដៃអះអាងបញ្ជាក់យ៉ាងច្បាស់ផងដែរថាដីនេះ គឺជាទ្រព្យដោយឡែករបស់កូនក្តីខ្ញុំឈ្មោះ ដូចដែលមានលិខិតអះអាងអំពីប្រភេទទ្រព្យលេខៈ ឆ្នាំ

ទទួលស្គាល់ដោយចៅសង្កាត់ឃ្មួញ ជាភស្តុតាងស្រាប់។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យលទ្ធភាព និងសម្រេចលុបចោលដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីលេខៈ របស់សាលាដំបូងរាជធានីភ្នំពេញ ចោលជាអាសាបង់ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ។

ថ្ងៃសុក្រ ១១ កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស

រាជធានីភ្នំពេញ, ថ្ងៃទី

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**មេធាវី**

សេចក្តីចម្លងបណ្តឹងជំទាស់

សាលាដំបូងរាជធានីភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សេចក្តីចម្លងបណ្តឹងជំទាស់**

លេខ

ខែ មិថុនា ឆ្នាំ

សំណុំរឿង រដ្ឋប្បវេណី

នៃបណ្តឹងពិសេស

លេខ

ខែ

ឆ្នាំ ថ្ងៃទីដប់ វេលាម៉ោងដប់ប្រាំមួយនិងសែសិបនាទី ។

យើង ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញពាក្យបណ្តឹង **ជំទាស់** ចុះថ្ងៃទី របស់ឈ្មោះ

មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ។

ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។

ហើយសុំប្តឹង **ជំទាស់** នឹងដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មី លេខ

ចុះថ្ងៃទី ត្រង់ចំណុច **លើដីកាសម្រេចទាំងមូល** ។

| **អ្នកប្តឹង** | **ក្រឡាបញ្ជី** |
| --- | --- |
| ហត្ថលេខា ឬ ផ្តិតមេដៃ | ហត្ថលេខា |

---

| **បានឃើញ** | **បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម** |
| --- | --- |
| ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. | ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. |
| ភ្នំពេញ ថ្ងៃទី | ភ្នំពេញ ថ្ងៃទី |
| ជ.ប្រធានសាលាដំបូង | ក្រឡាបញ្ជី |
| អនុប្រធាន | |

**សេចក្តីចម្លងបណ្តឹងជំទាស់**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

<u>សេចក្តីចម្លងបណ្តឹងជំទាស់</u>

*លេខ*

*ខែ មិថុនា ឆ្នាំ*

***សំណុំរឿង រដ្ឋប្បវេណី*** ឆ្នាំ ថ្ងៃទីដប់ វេលាម៉ោងដប់ប្រាំមួយនិងសែសិបនាទី ។

***នៃបណ្តឹងពិសេស*** យើង ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ ។

*លេខ* បានឃើញពាក្យបណ្តឹង **ជំទាស់** ចុះថ្ងៃទី របស់ឈ្មោះ

*ខែ* មេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ។

ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។
ហើយសុំប្តឹង **ជំទាស់** នឹងដីកាសម្រេចចាប់ផ្តើមការជំនុំជម្រះសាជាថ្មី លេខ
ចុះថ្ងៃទី ត្រង់ចំណុច **លើដីកាសម្រេចទាំងមូល** ។

| **អ្នកប្តឹង** | **ក្រឡាបញ្ជី** |
|---|---|
| ហត្ថលេខា ឬ ផ្តិតមេដៃ | ហត្ថលេខា |

---

| បានឃើញ | បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. | ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. |
| ភ្នំពេញ ថ្ងៃទី | ភ្នំពេញ ថ្ងៃទី |
| **ជ.ប្រធានសាលាដំបូង** | **ក្រឡាបញ្ជី** |
| **អនុប្រធាន** | |

# ឧបសម្ព័ន្ធទី៦.ដីកាសម្រេចនៃតុលាការបណ្តឹងជំនាស់

– ដីកាសម្រេច

ដីកាសម្រេច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

## ដីកាសម្រេច

**សំណុំរឿងដីកាសម្រេច**
លេខ

**ដីកាសម្រេច**
លេខ
ចុះថ្ងៃទី

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នា ថ្ងៃទីប្រាំមួយ
ខែ ដោយមាន៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

**ឯកឧត្តម** **ប្រធានក្រុមប្រឹក្សា**
**ឯកឧត្តម** **ចៅក្រមប្រឹក្សា**
**លោក** **ចៅក្រមប្រឹក្សា**

**ក្រឡាបញ្ជី**

**លោកស្រី**

**ដើមចោទ** ៖ ឈ្មោះ ភេទស្រី ជាតិខ្មែរ មានអាសយដ្ឋាននៅផ្ទះលេខ ។

អ្នកតំណាងដោយអាណត្តិឲ្យមេធាវី ។

**ចុងចម្លើយ (ភាគីប្តឹងជំទាស់)** ៖ ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ មានអាសយដ្ឋាននៅផ្ទះលេខ ( ) ផ្លូវ រាជធានីភ្នំពេញ ។

អ្នកតំណាងដោយអាណត្តិមេធាវី អត្តលេខ ជាប្រធាន ការិយាល័យមេធាវី វិនិ រាជធានីភ្នំពេញ ។

**១-ខ្លឹមសារនៃដីកាសម្រេចដែលភាគីដើមចោទទាមទារ៖**

សុំជំនុំជម្រះសាជាថ្មីលើសាលក្រមរដ្ឋប្បវេណីលេខ
របស់សាលាដំបូងរាជធានីភ្នំពេញ ។

**ខ្ញានឃើញ** ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីលេខ .វ ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ
របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីដូចខាងក្រោម៖

១.ទទួលពាក្យបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី របស់ឈ្មោះ ។

២- ដីកាសម្រេចនេះអាចប្តឹងជំទាស់បាន ។

**ខ្ញានឃើញ** ពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី និងសេចក្តីបំភ្លឺបណ្តឹងជំទាស់ លេខ ចុះថ្ងៃទី របស់ឈ្មោះ មេធាវីតំណាងដោយអាណត្តិ ឱ្យឈ្មោះ សុំប្តឹងជំទាស់នឹងដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីលេខ ចុះថ្ងៃទី ១៧...

ខែឧសភា ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ លើដីកាសម្រេចទាំងមូល ។

**២-អំពីសេចក្តីថ្លែងការណ៍**

មេធាវី តំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ ធ្វើសេចក្តីថ្លែងការណ៍ ៖ ចំពោះការស្នើសុំពន្យាពេលរបស់មេធាវីតំណាងដោយអាណត្តិឱ្យភាគីចុងចម្លើយ ខ្លួនសូមស្នើសុំក្រុមប្រឹក្សាបន្តនីតិវិធី ។ ក្នុងនាមខ្លួនជាមេធាវីតំណាងដោយអាណត្តិអោយដើមចោទ សូមធ្វើសេចក្តីថ្លែងការណ៍ដូចតទៅ៖

កាលពីថ្ងៃទី សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីលេខ: និងបានបញ្ជូនដីកាសម្រេចនេះទៅអាសយដ្ឋានរបស់ចុងចម្លើយឈ្មោះ ហើយតាមរយៈរបាយការណ៍អំពីការបញ្ជូន ដែលបានចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកការបញ្ជូន ចុងចម្លើយបានទទួលដីកានេះនៅថ្ងៃទី ។ ប៉ុន្តែចុងចម្លើយបានដាក់ពាក្យបណ្តឹងជំទាស់ទៅនឹងដីកាខាងលើនៅថ្ងៃទី វេលាម៉ោង ០៤ និង៤០ នាទីរសៀល ដែលផុតរយៈពេលដែលខ្លួនមានសិទ្ធិប្តឹងជំទាស់ ទៅតាមកំណត់ច្បាប់ ។

យោងតាមមាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឈ្មោះ មានសិទ្ធិក្នុងការប្តឹងជំទាស់ក្នុងរយៈពេល ១(មួយ)សប្តាហ៍ ហើយរយៈពេលនេះមិនអាចពន្យារបានឡើយ បានន័យថាចុងចម្លើយមានសិទ្ធិប្តឹងជំទាស់យ៉ាងយូរត្រឹមថ្ងៃទី ) ប៉ុណ្ណោះ ។

យោងតាមមាត្រា ៣០៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី៖ "បញ្ញត្តិស្តីពីបណ្តឹងឧទ្ធរណ៍ និងនីតិវិធីនៃការជំនុំជម្រះសាជាថ្មីលើបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាចំពោះបណ្តឹងជំទាស់លើដីកាសម្រេចរបស់សាលាដំបូង និងនីតិវិធីនៃតុលាការនៃបណ្តឹងជំទាស់នោះ" ។ ដូច្នេះយោងតាមមាត្រា ២៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលចែងថាក្នុងករណីដែលបណ្តឹងឧទ្ធរណ៍មានលក្ខណៈផ្ទុយនឹងច្បាប់ ហើយចំណុចខ្វះខាតនោះមិនអាចកែតម្រូវបានទេ តុលាការនៃបណ្តឹងឧទ្ធរណ៍អាចលើកចោលបណ្តឹងឧទ្ធរណ៍នោះបានដោយមិនឆ្លងកាត់តាមការទាញហេតុផលផ្ទាល់មាត់ ដោយសារសាលដីកានោះពាក្យបណ្តឹងជំទាស់នេះធ្វើឡើងផុតរយៈពេលនៃការធ្វើបណ្តឹងជំទាស់ ដែលចែងក្នុងមាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ម្យ៉ាងវិញទៀតកាលពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ តាមរយៈខ្លួនជាមេធាវីតំណាងអោយលោកស្រី បានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទាក់ទងទៅនឹងការប្រើលិខិតអះអាងអំពីប្រភពទ្រព្យ ចុះថ្ងៃទី ដែលមេធាវីរបស់ដើមបណ្តឹងជំទាស់បានដាក់ភស្តុតាងដើម្បីជាមូលដ្ឋានតែមួយគត់ក្នុងការធ្វើបណ្តឹងជំទាស់របស់ខ្លួន ដែលលោកស្រី បានអះអាងថាជាលិខិតក្លែងស្នាមមេដៃរបស់លោកស្រី ។ លោកស្រីក៏បានផ្តិតមេដៃរបស់ខ្លួនជាគម្រូសម្រាប់ជាភស្តុតាងក្នុងការផ្ទៀងផ្ទាត់ពីភាពពិតប្រាកដនៃស្នាមមេដៃរបស់លោកស្រីថែមទៀតផង ។ ប្រសិនបើរកឃើញថាលោក បានក្លែងឯកសារនោះមែន មិនត្រឹមតែលិខិតអះអាងអំពីប្រភពទ្រព្យ ចុះថ្ងៃទី មិនមានសុពលភាពប៉ុណ្ណោះទេ ចំណែកឯលោក ក៏ត្រូវទទួលទោសព្រហ្មទណ្ឌថែមទៀតផង ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធានក្រុមប្រឹក្សា មេត្តាលើកចោលពាក្យបណ្តឹងជំទាស់ ចុះថ្ងៃទី១០ ខែ

មិថុនា ឆ្នាំ របស់មេធាវីតំណាងដោយអាណត្តិអោយឈ្មោះ ដោយក្តីអនុគ្រោះ ពីព្រោះពាក្យបណ្តឹងនេះធ្វើឡើងដោយផ្ទុយនឹងច្បាប់ គឺផុតរយៈពេលប្តឹង ហើយភស្តុតាងជាលិខិតដែលយកមកប្រើនោះ ជាលិខិតដែលកូនក្តីខ្លួនអះអាងថាជាលិខិតក្លែងស្នាមមេដៃរបស់កូនក្តីខ្លួនទៀតផង ។

## សំអាងហេតុ

១-បណ្តឹងជំទាស់លេខ របស់ឈ្មោះ មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ សុំប្តឹងជំទាស់នឹងដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មីលេខ ចុះថ្ងៃទី របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ តាមបញ្ញត្តិមាត្រា ៣១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី សភារដ្ឋប្បវេណីអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-សភារដ្ឋប្បវេណីពិនិត្យឃើញថាបណ្តឹងជំទាស់នេះធ្វើឡើងមិនត្រឹមត្រូវឡើយ ព្រោះសាលាដំបូងបានបញ្ជូនដីកាសម្រេចនេះតាមរបាយការណ៍បញ្ជូន ចុះថ្ងៃទី ហើយបានបញ្ជូនទៅអោយឈ្មោះ តាមអាសយដ្ឋានហើយត្រូវបានបុគ្គលិកទទួលនៅថ្ងៃទី រហូតដល់ថ្ងៃទី ទើបឈ្មោះ ជាមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ ធ្វើបណ្តឹងជំទាស់នេះ ។ ដូច្នេះតាមមាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីសភារដ្ឋប្បវេណីលើកបណ្តឹងជំទាស់ចោល ។

-ចំពោះប្រាក់ពន្ធដាក់ពាក្យសុំជាបន្ទុករបស់ភាគីប្តឹងជំទាស់ ។

## សេចក្តីសម្រេចបញ្ចប់

១-លើកបណ្តឹងជំទាស់លេខ របស់ឈ្មោះ មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ ចោល ។

២-ប្រាក់ពន្ធដាក់ពាក្យសុំជាបន្ទុករបស់ភាគីប្តឹងជំទាស់ ។

-ដីកាសម្រេចនេះ ធ្វើនៅថ្ងៃ សុក្រ ១៤ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស ត្រូវនឹងថ្ងៃទី ០៩ ខែ ឆ្នាំ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ១៤ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស

សាលាឧទ្ធរណ៍ភ្នំពេញ ថ្ងៃទី ឆ្នាំ

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

# ឧបសម្ព័ន្ធទី៧. ដីភាគោះ

ដីកាកោះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

[redacted]

សំណុំរឿងរដ្ឋប្បវេណីនៃបណ្ដឹងពិសេស

លេខ: [redacted]

## ដីកាកោះ

យើង [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

អញ្ជើញឈ្មោះ [redacted] ភេទប្រុស អាយុ៥៦ ឆ្នាំ ជនជាតិខ្មែរ ជាចុងចម្លើយ

ទីលំនៅសព្វថ្ងៃផ្ទះលក់ និង [redacted]

ជ័យ រាជធានី ភ្នំពេញ ។

អោយចូលទៅកាន់ សាលាដំបូងរាជធានី ភ្នំពេញ បន្ទប់ [redacted]

នៅថ្ងៃទី...២៥... ខែ.[redacted] វេលាម៉ោង ៩ និង ៣០ នាទី ព្រឹក

ដើម្បី: នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ពីដំណើររឿង:សុំជំនុំជម្រះសាជាថ្មី(បែងចែកទ្រព្យ, ទាមទារអាហារកាតព្វកិច្ច និងជម្ងឺចិត្ត)

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះនេះអោយបានទាន់ពេលវេលា និង យកលិខិត ផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ថ្ងៃចន្ទ ០៨រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស [redacted]

ធ្វើនៅរាជធានីភ្នំ ពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ [redacted]

ចៅក្រម

[redacted]

[illegible] [redacted]

[redacted]

[redacted] (ជំនួយការ)

Tel: [redacted]